រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

# សៀវភៅណែនាំ

# ស្តីពី

# ការតាមដានត្រួតពិនិត្យ និងវាយតំលៃ

# របស់ឃុំ សង្កាត់លើការងារអភិវឌ្ឍន៍មូលដ្ឋាន

354.968
MoE-COM

sh: training

ខែ វិច្ឆិកា ឆ្នាំ ២០០៤

NCDD Library
001135

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

លេខ : ១០០ សសរ / គ.ឃ.ស

# សេចក្តីសំរេច

## ស្តីពី

## ការដាក់អោយប្រើប្រាស់សៀវភៅណែនាំស្តីពីការតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់លើការងារអភិវឌ្ឍន៍មូលដ្ឋាន

## សហប្រធានគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។

-បានឃើញព្រះរាជក្រមលេខ នស /រកម / ០៣០១ / ០៥ ចុះថ្ងៃ ទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលបានប្រកាសអោយប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ។

-បានឃើញប្រកាសអន្តរក្រសួងលេខ ០៩៨ ប្រក ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

-បានឃើញសេចក្តីណែនាំលេខ ០០៥ សណន. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការជ្រើសរើសជនបង្គោលរបស់ឃុំ សង្កាត់ សំរាប់ការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ៣.

# ស ំ រ េ ច

**ប្រការ១.-**

ដាក់អោយប្រើប្រាស់នូវ " សៀវភៅណែនាំស្តីពី ការតាមដាន ត្រួតពិនិត្យ និង វាយតំលៃរបស់ឃុំ សង្កាត់លើការងារអភិវឌ្ឍន៍មូលដ្ឋាន " សំរាប់គំរោងអភិវឌ្ឍន៍ទាំងឡាយ ដែលអនុវត្តនៅក្នុងឃុំ សង្កាត់ ។

**ប្រការ២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ និង អ្នកពាក់ពន្ធ័ទាំងអស់ នៅក្នុងដំណើរការតាមដាន ត្រួតពិនិត្យ និង វាយតំលៃរបស់ឃុំ សង្កាត់លើការងារអភិវឌ្ឍន៍មូលដ្ឋាន ត្រូវអនុវត្តតាមការណែនាំ និង នីតិវិធីដែលបានកំណត់ក្នុងសៀវភៅណែនាំនេះ ។

**ប្រការ៣.-**

សេចក្តីសំរេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៕

*រាជធានីភ្នំពេញ ថ្ងៃទី.១៧.ខែ.[illegible].ឆ្នាំ២០០៤*

**ជ.គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

**សហប្រធាន**

**ស ខេង      នរោត្តម.សិរីវុឌ្ឍ**

**ចម្លងជូន**

- *សមាជិក " គ.ឃ.ស. "*
- *ក្រសួងស្ថាប័នពាក់ព័ន្ធ*
- *សាលាខេត្ត ក្រុង*
  *" ដើម្បីអនុវត្ត "*
- *ឯកសារ-កាលប្បវត្តិ៣.*

# បុព្វកថា

ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០២ គឺជាថ្ងៃប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ដែលប្រជាពលរដ្ឋកម្ពុជាបានទៅបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១១២៦១ នាក់ ដែលនៅក្នុងនោះមានស្ត្រីចំនួន ៩៥៤ នាក់ និងបុរសចំនួន ១០៣០៧ នាក់ ត្រូវបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅគ្រប់ឃុំ សង្កាត់ចំនួន ១៦២១ នៅក្នុងប្រទេសកម្ពុជា ដើម្បីចាត់ចែង គ្រប់គ្រង និងអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

នេះជាការងារដ៏លំបាកស្មុគស្មាញមួយ សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នោះ ។ ដើម្បីជួយគាំទ្រដល់ដំណើការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នេះ រដ្ឋាភិបាលក៏ដូចជាគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (គ.ឃ.ស) បានរៀបចំសកម្មភាពបណ្តុះបណ្តាលលើប្រធានបទទូទៅ និងជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយវិមជ្ឈការ និង បន្តកំពុងរៀបចំសកម្មភាពបណ្តុះបណ្តាលទាំងនេះតទៅទៀត ។

សៀវភៅមេរៀននេះ ពន្យល់ និងផ្តល់ការណែនាំអំពីការងារសំខាន់មួយចំនួន ដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុង <u>ការតាមដានត្រួតពិនិត្យ និង ការវាយតំលៃ</u> ដោយមានការប្រើប្រាស់នូវភាសាសាមញ្ញងាយយល់ និងភ្ជាប់ជាមួយនូវឧទាហរណ៍ជាក់ស្តែងផងដែរ ។ សៀវភៅមេរៀននេះ នឹងធ្វើការណែនាំជាជំហានៗ នូវអ្វីដែលជាសេចក្តីត្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ណែនាំអំពីរបៀប ឬ វិធីសាស្ត្រ ដើម្បីអោយឃុំ សង្កាត់អាចចាត់ចែង គ្រប់គ្រងសកម្មភាពទាំងឡាយ ក្នុងការតាមដានត្រួតពិនិត្យ និង វាយតំលៃការងាររបស់ខ្លួនអោយបានសមស្របទៅនឹងគោលការណ៍ច្បាប់ ។

សៀវភៅមេរៀននេះ ជាសៀវភៅដំបូង ដែលផ្តល់ការណែនាំតែអំពីបច្ចេកទេសងាយៗ សំរាប់ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ ដោយផ្តោតទៅលើការងារអភិវឌ្ឍន៍មូលដ្ឋានរបស់ឃុំ សង្កាត់ប៉ុណ្ណោះ។ នៅពេលដែលប្រជាពលរដ្ឋបានចូលរួម និងមានជំនាញកាន់តែប្រសើរក្នុងការគ្រប់គ្រង និងចាត់ចែងការងាររបស់ឃុំ សង្កាត់ ឬ នៅពេលដែលរដ្ឋាភិបាលតម្រូវអោយឃុំ សង្កាត់ទទួលការងារជាក់លាក់លើសពីនេះទៅទៀត នោះពិតជាមានការណែនាំលំអិតបន្ថែមទៀតអំពីវិធីសាស្ត្រ និងបច្ចេកទេសនានា សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។

# មាតិកាអត្ថបទ


**១. និយមន័យ** **១**

១.១. ការតាមដានត្រួតពិនិត្យ ១

១.២. ការវាយតំលៃ ២

១.៣. ភាពខុសគ្នា រវាងការតាមដានត្រួតពិនិត្យ និងការវាយតំលៃ ៣

១.៤. ការតាមដានត្រួតពិនិត្យ និងវាយតំលៃផ្ទៃក្នុង និងដោយអ្នកពីខាងក្រៅ ៥

**២. គោលបំណងរបស់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ** **៧**

២.១. គោលបំណងនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃលើការអភិវឌ្ឍន៍មូលដ្ឋាន ៧

២.២. មូលដ្ឋានច្បាប់សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ៩

**៣. គំរោង និងសមាសភាគដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ** **១៣**

៣.១. គំរោងអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មនៅក្នុងឃុំ សង្កាត់ ១៣

៣.២. សមាសភាគរបស់គំរោងដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ១៥

៣.២.១. ធនធាន និងទុន (Inputs) ១៦

៣.២.២. សកម្មភាព ១៧

៣.២.៣. លទ្ធផល ១៧

៣.២.៤. ផលប៉ះពាល់ ១៧

**៤. ពេលវេលាដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ** **១៩**

**៥. អ្នកពាក់ព័ន្ធនឹងការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ** **២១**

៥.១. ក្រុមប្រឹក្សាឃុំ សង្កាត់ ២១

៥.២. ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃឃុំ សង្កាត់ ២១

៥.៣. គណៈកម្មាធិការ និងគណៈកម្មការនានា ២៣

៥.៤. ប្រជាពលរដ្ឋមូលដ្ឋាន និងក្រុមអ្នកប្រើប្រាស់ ២៤

៥.៥. មន្ត្រីគាំទ្រថ្នាក់ខេត្ត ក្រុង និង ស្រុក ខណ្ឌ ២៥

**៦. នីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ ២៩**

៦.១. ការត្រៀមរៀបចំ ៣០

៦.១.១. ការកំណត់គោលបំណង សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ៣១

៦.១.២. ការជ្រើសរើសសូចនាករ ៣៦

៦.១.៣. ការកំណត់សំណួរគន្លឹះ ៣៨

៦.១.៤. ការកំណត់វិធីសាស្រ្តសំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ៤១

៦.១.៥. ការរៀបចំផែនការសកម្មភាព ៤៤

៦.២. ការប្រមូលពតិមាន ៤៧

៦.២.១. ប្រភពនៃពតិមាន ៤៧

៦.២.២. ឧបករណ៍សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ៤៨

៦.៣. ការវិភាគពតិមាន ៦៥

៦.៤. ការប្រើប្រាស់សេចក្តីសន្និដ្ឋាន ៦៧

**៧. ការប្រើប្រាស់លទ្ធផលតាមដានត្រួតពិនិត្យ និងវាយតំលៃ ៦៩**

៧.១. សំរាប់ការរៀបចំរបាយការណ៍ឃុំ សង្កាត់ ៦៩

៧.២. ជាមូលដ្ឋានមួយសំរាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ៧០

**៨. ការរៀបចំ និងការចាត់ចែងការតាមដានត្រួតពិនិត្យ និងវាយតំលៃ ៧២**

**៩. ការងារបន្ត ៧៥**

**បញ្ជីសៀវភៅយោង ៧៦**

# អ្វីទៅជាការតាមដានត្រួតពិនិត្យ និងវាយតំលៃ?

## ១. និយមន័យ

### ១.១. ការតាមដានត្រួតពិនិត្យ

ការតាមដានត្រួតពិនិត្យនៅថ្នាក់ឃុំ សង្កាត់ គឺជាសកម្មភាពនានាដែលជួយអោយក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកពាក់ព័ន្ធ និងអ្នកមានចំណាប់អារម្មណ៍លើការងារគ្រប់គ្រង និងការងារអភិវឌ្ឍន៍មូលដ្ឋានរបស់ឃុំ សង្កាត់ ដឹងថាតើអ្វីៗទាំងអស់បានអនុវត្តទៅតាមផែនការដែរឬទេ និងបញ្ជាក់ថាតើអ្វីទាំងនោះបានទទួលលទ្ធផលកំរិតណាដែរ ។

**ឧទាហរណ៍ :**

នៅក្នុងផ្នែកមួយនៃគំរោងអភិវឌ្ឍន៍សំរាប់ឆ្នាំក្រោយ ឃុំសំរេចនឹងសាងសង់បង្គន់ថ្មី **ចំនួន៣** នៅសាលារៀនមួយ ។ គំរោងសាងសង់បង្គន់នេះ បានដាក់អោយដេញថ្លៃ ហើយអ្នកឈ្នះក្នុងការដេញថ្លៃនឹងធ្វើការសាងសង់បង្គន់ទាំងនេះក្នុងតម្លៃ ១.៥00.000រៀល ក្នុងរយៈពេល **៦សប្តាហ៍** ។ *នៅក្នុងកិច្ចសន្យាសាងសង់ការងារនេះ នឹងចាប់ផ្តើមនៅ* ***ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៤*** *។ តាមរយៈការតាមដានត្រួតពិនិត្យ ក្រុមប្រឹក្សាឃុំបានកត់សំគាល់ឃើញថា រហូតមកដល់ពាក់កណ្តាលខែ ឧសភា ឆ្នាំ ២០០៤ ការសាងសង់នៅមិនទាន់បានចាប់ផ្តើមនៅឡើយទេ គឺខុសពីអ្វីដែលមានចែងនៅក្នុងកិច្ចសន្យា ។*

**ឧទាហរណ៍ :**

នៅក្នុងផ្នែកមួយនៃយុទ្ធនាការសំអាតតំបន់ជុំវិញផ្សារ សង្កាត់បានសំរេចចំណាយប្រាក់បន្ថែមឱ្យកម្មករសង្កាត់ **២នាក់** ដើម្បីប្រមូលសំរាម និងកាកសំណល់ផ្សេងៗ អោយបានប្រសើរជាងមុន ។ *នៅអំឡុងពេល* ***៤ខែដំបូង*** *ការរៀបចំនេះហាក់ដូចជាធ្វើទៅបានល្អ ។ តែនៅ****ខែទី៥*** *នៅល្ងាចថ្ងៃមួយពេលដែលចៅសង្កាត់ត្រលប់មកផ្ទះវិញ គាត់សំគាល់ឃើញថា មានក្លិនមិនល្អនៅតាមផ្លូវក្បែរផ្សារ ដោយសារតែមានសំរាមយ៉ាងច្រើននៅចំហៀងផ្លូវម្ខាង និងថែមទាំងមានកណ្តុរកំពុងរត់ចុះរត់ឡើងទៀតផង ។*

ផ្អែកតាមលទ្ធផលនៃការតាមដានត្រួតពិនិត្យ ក្រុមប្រឹក្សាឃុំ សង្កាត់បានដឹងថា មិនមែនគ្រប់អ្វីៗទាំងអស់សុទ្ធតែបានអនុវត្តទៅតាមផែនការនោះទេ ។ ប្រសិនបើសកម្មភាពណាមួយ មិនត្រូវបានអនុវត្តទៅតាមការគ្រោងទុក ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរកអោយឃើញថា តើមូលហេតុអ្វីបានជាសកម្មភាពនោះមិនត្រូវបានអនុវត្ត ហើយត្រូវចាត់វិធានការកែតំរូវជាបន្ទាន់តាមដែលអាចធ្វើទៅបាន ។

ការតាមដានត្រួតពិនិត្យ គឺជាដំណើរការប្រមូលពត៌មានអំពីការរីកចំរើនរបស់គំរោង ។ ពត៌មានទាំងនេះត្រូវប្រមូលជាប្រចាំ ក្នុងអំឡុងពេលអនុវត្តការងារ ។ គោលបំណងនៃការប្រមូលពត៌មាន គឺដើម្បីជួយកំណត់ថាតើសកម្មភាពណាខ្លះកំពុងត្រូវបានអនុវត្តទៅតាមផែនការ ឬទៅតាមការរំពឹងទុក ។ ពត៌មានទាំងនេះ ត្រូវបានប្រើប្រាស់សំរាប់ធ្វើសេចក្តីសំរេចចិត្តកែលំអការគ្រប់គ្រង និងការអនុវត្តការងារ ។

ដូច្នេះ ការតាមដានត្រួតពិនិត្យនឹងជួយ ÷

- អោយដឹងពីការរីកចំរើននៃការអនុវត្តគំរោង
- កំណត់បញ្ហានានា
- ធ្វើការសំរេចចិត្តក្នុងការកែលំអអោយទាន់ពេលវេលា បើសិនជាមានបញ្ហា
- ប្រើប្រាស់ធនធានអោយអស់លទ្ធភាព និងចំទិសដៅ
- រក្សាបាននូវគុណភាពការងារល្អ ។

## ១.២. ការវាយតំលៃ

ការវាយតំលៃខុសគ្នាពីការតាមដានត្រួតពិនិត្យ ។ ការវាយតំលៃ ជាការប្រមើលមើលនូវអ្វីដែលបានធ្វើ និងដើម្បីកំណត់ថាតើការអនុវត្តគំរោងមានប្រសិទ្ធភាព និងផលប៉ះពាល់យ៉ាងណាដែរ ។ ការវាយតំលៃ ក៏ត្រូវពិនិត្យផងដែរ ថាតើផលប៉ះពាល់ទាំងនោះ បណ្តាលអោយមានបញ្ហាអ្វីខ្លះ និងថាតើត្រូវធ្វើអ្វីខ្លះ ដើម្បីកែលំអគំរោង ។

**ឧទាហរណ៍ :**

៦ខែបន្ទាប់ពីសាងសង់រួចមក បង្គន់២នៃបង្គន់ទាំង៣នៅសាលារៀន ប្រើការបានយ៉ាងល្អ ។ ជារៀងរាល់ថ្ងៃ បន្ទាប់ពីចប់ម៉ោងសិក្សា អ្នកសំអាតនៅសាលាតែងតែសំអាតបង្គន់ទាំងនោះ ។ បន្ទាប់ពីបង្គន់ទាំងនេះត្រូវបានដាក់អោយប្រើប្រាស់ យើងឃើញថាក្មេងៗបានទៅសាលាច្រើនជាងមុន ដោយសារមិនសូវឆ្លងជំងឺដូចមុន ។ សិស្ស និងគ្រូពេញចិត្តមកសាលារៀនជាងមុន ព្រោះពុំមានក្លិនស្អុយដូចកាលពីពុំទាន់មានបង្គន់ ។ តែទោះជាយ៉ាងណា ក៏នៅមានបញ្ហាចំពោះបង្គន់មួយដែរ ជាពិសេសនៅពេលមានភ្លៀងធ្លាក់ខ្លាំង ។

**ឧទាហរណ៍ :**

នៅពេលពិភាក្សាគ្នាអំពីគំរោងថវិកាសំរាប់ឆ្នាំក្រោយ ក្រុមប្រឹក្សាសង្កាត់ត្រូវតែធ្វើការសំរេច ថាតើខ្លួនចង់បន្តផ្តល់ប្រាក់បន្ថែមដល់កម្មករសង្កាត់២នាក់នោះ ដើម្បីសំអាតផ្សារទៀតឬយ៉ាងណា ។ មុនធ្វើការសំរេចចិត្ត

ចៅសង្កាត់សំណូមពរអោយក្រុមប្រឹក្សាសង្កាត់ទាំងអស់ ធ្វើការពិភាក្សាជាមួយប្រជាពលរដ្ឋរស់នៅក្បែរផ្សារ និងប្រជាពលរដ្ឋលក់ដូរក្នុងផ្សារ ថាតើពួកគេពេញចិត្តនឹងអ្វីដែលយើងបានធ្វើកាលពីឆ្នាំទៅដែរឬទេ ។

☞ ការវាយតំលៃ គឺជាដំណើរការនៃការវាស់ស្ទង់ទៅលើប្រសិទ្ធភាព និងផលប៉ះពាល់របស់គំរោង ដើម្បីចង់ដឹងថា :

- តើគំរោងបានចូលរួមធ្វើអោយមានបំរែបំរួលអ្វីខ្លះលើប្រជាពលរដ្ឋគោលដៅ ហើយថាតើបំរែបំរួលទាំងនោះ ដូចអ្វីដែលយើងរំពឹងទុកដែរឬទេ?
- តើចាំបាច់ដែរឬទេ ក្នុងការអនុវត្តគំរោងណាមួយនោះ?
- តើការអនុវត្តគំរោងត្រូវបានធ្វើឡើងត្រឹមត្រូវដែរឬទេ? អាចធ្វើបានត្រឹមត្រូវ និងល្អជាងនេះដោយចំណាយតិចជាងមុន?
- តើលទ្ធផលរបស់គំរោងនេះមាននិរន្តភាពដែរឬទេ? ឬតើត្រូវធ្វើអ្វីខ្លះទៀត ដើម្បីថែរក្សាសមិទ្ធផលរបស់គំរោង?

តាមរយៈការវាយតំលៃ យើងអាចរៀនសូត្របានជាច្រើន ដើម្បីទុកជាបទពិសោធន៍សំរាប់ការអនុវត្តគំរោងនាពេលអនាគត ។ ការវាយតំលៃគឺត្រូវបានធ្វើឡើងដើម្បីចង់ដឹងថាតើការអនុវត្តគំរោងសំរេចបានគោលបំណងរបស់វាក៏រិតណា ។ ការវាយតំលៃគំរោងគឺជាសកម្មភាពដែលត្រូវធ្វើនៅពេលជាក់លាក់ណាមួយ ដូចជាពាក់កណ្តាលគំរោង ជិតបញ្ចប់គំរោង ចុងបញ្ចប់គំរោង ឬរយៈពេលប៉ុន្មានខែ ឬ ប៉ុន្មានឆ្នាំបន្ទាប់ពីគំរោងបានបញ្ចប់ ក្រោយពីគំរោងត្រូវបានដាក់អោយប្រើប្រាស់មួយកំឡុងពេលមក ។

## ១.៣. ភាពខុសគ្នារវាងការតាមដានត្រួតពិនិត្យ និងការវាយតំលៃ

ការតាមដានត្រួតពិនិត្យ និងការវាយតំលៃមិនមែនដូចគ្នាទេ តែវិធីសាស្រ្ត និងបច្ចេកទេសរបស់វា គឺមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ពេលធ្វើការតាមដានត្រួតពិនិត្យ គេក៏ត្រូវធ្វើការពិចារណាផងដែរអំពីបញ្ហាមួយចំនួនដែលជាធម្មតាត្រូវបានវាយតំលៃ ។ ដូចនេះជាទូទៅ គេតែងតែហៅថា "ការតាមដានត្រួតពិនិត្យ និងវាយតំលៃ" ដោយសារសកម្មភាពរបស់វាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ។ តែក្នុងការអនុវត្តជាក់ស្តែង ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដានត្រួតពិនិត្យ ច្រើនជាងការវាយតំលៃ ។ ដូច្នេះ សៀវភៅមេរៀននេះ នឹងផ្តោតលើការតាមដានត្រួតពិនិត្យ ច្រើនជាងការវាយតំលៃ ។

ខាងក្រោមនេះ គឺជាចំណុចខុសគ្នាខ្លះៗរវាងការតាមដានត្រួតពិនិត្យ និងការវាយតំលៃ :

| ចំណុចសំខាន់ៗ | ការតាមដានត្រួតពិនិត្យ | ការវាយតំលៃ |
|---|---|---|
| គោលបំណង | ដើម្បីពិនិត្យថាតើសកម្មភាពនានាត្រូវបាន អនុវត្តទៅតាមការគ្រោងទុកដែរឬទេ ។ | ដើម្បីពិនិត្យថាតើគំរោងសំរេចបាន តាមគោលបំណងដែរឬទេ ។ |
| តើត្រូវធ្វើនៅពេលណា? | នៅគ្រប់ពេលទាំងអស់ក្នុងអំឡុងពេល អនុវត្តសកម្មភាពគំរោង ឬការផ្តល់សេវាកម្មនានា ។ | នៅពេលកំណត់ ( ពាក់កណ្តាល ជិតបញ្ចប់ ពេលបញ្ចប់ ឬក្រោយ ពេលបញ្ចប់គំរោង) ។ |
| តើត្រូវប្រមូលពត៌មានអ្វីខ្លះ? | ពត៌មានអំពីសកម្មភាពនៃការអនុវត្តគំរោង ព្រមទាំងលទ្ធផលនៃសកម្មភាព និងធនធាន ដែលបានប្រើ ដើម្បីពិនិត្យថាតើសកម្មភាព ត្រូវបានអនុវត្តស្របទៅនឹងការគ្រោងទុក ដែរឬទេ ។ | ពត៌មានលំអិតបន្ថែម ដើម្បីមើល ថាតើសំរេចបានគោលបំណងរបស់ គំរោងយ៉ាងដូចម្តេច ។ |
| តើនរណាខ្លះជាអ្នកធ្វើ ? | ក្រុមប្រឹក្សាឃុំ សង្កាត់ ឬអ្នកដែលរស់នៅ ក្នុងឃុំ សង្កាត់ ហើយមានចំណាប់អារម្មណ៍ លើការគ្រប់គ្រង និងអភិវឌ្ឍឃុំ សង្កាត់ ។ | ក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយនឹង ប្រជាពលរដ្ឋរស់នៅទីនោះ ហើយ ប្រហែលជាមានជំនួយពីមន្ត្រីថ្នាក់ ខេត្ត ឬអ្នកខាងក្រៅណាមួយ ។ ការវាយតំលៃ ក៏អាចធ្វើឡើង ដោយអ្នកខាងក្រៅផងដែរ ។ |
| តើពត៌មាននោះនឹងត្រូវប្រើប្រាស់យ៉ាងដូចម្តេច ? | ដោះស្រាយបញ្ហានានា ដែលកំពុងកើតឡើង ដើម្បីកែលំអការអនុវត្តគំរោង និងទុកជាទុនសំរាប់ការវាយតំលៃ ។ | ដើម្បីវិនិច្ឆ័យអំពីផលប៉ះពាល់នៃ គំរោង ឬសេវាកម្មដែលបានផ្តល់ ដល់ក្រុមគោលដៅ និងជាជំនួយ ក្នុងការរៀបចំគំរោង នាពេល អនាគត ។ |

## ១.៤. ការតាមដានត្រួតពិនិត្យ និងវាយតំលៃផ្ទៃក្នុង និងដោយអ្នកពីខាងក្រៅ

ការតាមដានត្រួតពិនិត្យ និងការវាយតំលៃដែលបានលើកឡើងខាងដើម គឺជាការតាមដានត្រួតពិនិត្យ និងវាយតំលៃ ដោយ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬដោយសមាជិកផ្សេងទៀតរបស់ឃុំ សង្កាត់ ។ ការតាមដាន ត្រួតពិនិត្យ និងវាយតំលៃប្រភេទនេះ ហៅថាការតាមដានត្រួតពិនិត្យ និងវាយតំលៃផ្ទៃក្នុង ។ ចំណែកការតាមដានត្រួតពិនិត្យ និងវាយតំលៃប្រភេទមួយទៀត គឺការតាមដានត្រួតពិនិត្យ និងវាយតំលៃទៅលើ ឃុំ សង្កាត់។ ការតាមដានត្រួតពិនិត្យ និងវាយតំលៃប្រភេទនេះ ត្រូវបានធ្វើឡើងដោយភ្នាក់ងាររាជរដ្ឋាភិបាល (ថ្នាក់ជាតិ ខេត្ត ក្រុង និងស្រុក ខណ្ឌ និងស្ថាប័ននានា) ដើម្បីពិនិត្យមើលនូវអ្វីដែលឃុំ សង្កាត់បានអនុវត្ត និងអ្វីដែលឃុំ សង្កាត់មិនបានអនុវត្ត និងថាតើការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្របទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួនដែរឬទេ។ ការតាមដានត្រួតពិនិត្យ និងវាយតំលៃប្រភេទនេះ ហៅថាការតាមដាន ត្រួតពិនិត្យ និងវាយតំលៃ ដោយអ្នកពីខាងក្រៅ ។

ការតាមដានត្រួតពិនិត្យ និងវាយតំលៃទាំងពីរប្រភេទនេះ គឺមានសារៈសំខាន់ណាស់ ហើយវាក៏បំពេញគ្នាទៅវិញទៅមកដែរ ។ តារាងខាងក្រោមនេះ នឹងបង្ហាញពីអ្នកពាក់ព័ន្ធក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ។

| | ការអភិវឌ្ឍន៍មូលដ្ឋាន និងការផ្តល់សេវាកម្ម | ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុឃុំ សង្កាត់ |
|---|---|---|
| ការតាមដានត្រួតពិនិត្យ និងវាយតំលៃផ្ទៃក្នុង | - ក្រុមប្រឹក្សាឃុំ សង្កាត់<br>- ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃឃុំ សង្កាត់<br>- គណៈកម្មការគ្រប់គ្រងគំរោង<br>- ក្រុមអ្នកប្រើប្រាស់ | **ផ្នែករដ្ឋបាល**<br>- ក្រុមប្រឹក្សាឃុំ សង្កាត់<br>- ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃឃុំ សង្កាត់<br>- ប្រជាពលរដ្ឋមូលដ្ឋាន<br>**ផ្នែកហិរញ្ញវត្ថុ**<br>- ក្រុមប្រឹក្សាឃុំ សង្កាត់<br>- ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃឃុំ សង្កាត់<br>- ប្រជាពលរដ្ឋមូលដ្ឋាន<br>- បេឡាករ និងគណនេយ្យករឃុំ សង្កាត់ |

| | | |
|---|---|---|
| ការតាមដានត្រួតពិនិត្យ និងវាយតម្លៃដោយអ្នកពីខាងក្រៅ | - ក្រុមអ្នកសំរបសំរួលខេត្ត ក្រុង ស្រុក ខណ្ឌ<br>- មន្ត្រីគាំទ្របច្ចេកទេស<br>- ការិយាល័យជំនាញជុំវិញស្រុក ខណ្ឌ<br>- មន្ទីរជំនាញ ជុំវិញខេត្ត ក្រុង<br>- សាលាខេត្ត ក្រុង ស្រុក ខណ្ឌ<br>- ក្រសួងជំនាញ<br>- អង្គការជាតិ និងអង្គការអន្តរជាតិផ្សេងៗ ទៀត ដែលអនុវត្តគំរោង ឬផ្តល់សេវាកម្ម ក្នុងឃុំ សង្កាត់ | **ផ្នែករដ្ឋបាល**<br>- ក្រសួងមហាផ្ទៃ<br>- អាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ<br>- ក្រុមអ្នកសំរបសំរួលខេត្ត ក្រុង ស្រុក ខណ្ឌ<br>**ផ្នែកហិរញ្ញវត្ថុ**<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- អាជ្ញាធរសវនកម្មជាតិ<br>- រតនាគារជាតិ<br>- រតនាគារខេត្ត ក្រុង |

សៀវភៅមេរៀននេះ ពាក់ព័ន្ធតែលើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ដែលធ្វើឡើង <u>ដោយ</u> ឃុំ សង្កាត់ខ្លួនឯងតែប៉ុណ្ណោះ មិនមែនការតាមដានត្រួតពិនិត្យ និងវាយតំលៃដោយអ្នកមកពីខាងក្រៅឃុំ សង្កាត់នោះទេ ។ សៀវភៅមេរៀននេះ នឹងផ្តល់នូវការណែនាំមួយចំនួន ពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យ និងវាយតំលៃផ្ទៃក្នុង លើការងារអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មនៅមូលដ្ឋាន ( ដូចដែលមានបញ្ជាក់នៅក្នុងប្រអប់ខាងលើ ) ។ តែទោះជាយ៉ាងណាក៏ដោយ សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃដោយអ្នកពីខាងក្រៅ ក៏មានវិធីសាស្ត្រ និងឧបករណ៍មួយចំនួនត្រូវបានលើកឡើងហើយដែរនៅក្នុងសេចក្តីណែនាំ និងបទបញ្ញត្តិមួយចំនួន ( ដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យឃុំ សង្កាត់ សៀវភៅណែនាំសំរាប់ការអនុវត្តគំរោងឃុំ សង្កាត់ និងទំរង់របាយការណ៍របស់អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងជាដើម ) ។

## ២. គោលបំណងរបស់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ

## ២.១. គោលបំណងនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ លើការអភិវឌ្ឍន៍មូលដ្ឋាន

☞ ការតាមដានត្រួតពិនិត្យ និងវាយតំលៃលើការងារអភិវឌ្ឍន៍មូលដ្ឋាន មានគោលបំណងសំខាន់ៗចំនួន ៤ គឺ ៖

**១. ជួយពង្រឹងគណនេយ្យភាព ( ការទទួលខុសត្រូវ ) :** តាមរយៈការតាមដានត្រួតពិនិត្យ និងវាយតំលៃ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចពន្យល់បំភ្លឺ និងបង្ហាញដល់ប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់ និងរាជរដ្ឋាភិបាល ពីការប្រើប្រាស់ធនធានរបស់ខ្លួន ថាតើស្របទៅតាមការគ្រោងទុកដែរឬទេ (ដូចដែលមាននៅក្នុងគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ដែលបានអនុម័ត) ហើយថាតើការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ដែរឬទេ ។

*ឧទាហរណ៍ : នៅឆ្នាំ ២០០៣ អណ្តូងទឹកចំនួន ៥ ត្រូវបានសាងសង់នៅក្នុងភូមិចំនួន៥ ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ ។ <u>តាមរយៈលទ្ធផលនៃការតាមដានត្រួតពិនិត្យក្នុងដំណាក់កាលសាងសង់ ក្រុមប្រឹក្សាឃុំត្រូវបង្ហាញឱ្យប្រជាពលរដ្ឋបានដឹងថា អណ្តូងទាំងនេះត្រូវបានសាងសង់ត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេសហើយ ។ យោងតាមការវាយតំលៃមួយ ដែលបានធ្វើឡើងរយៈពេល ៦ ខែ បន្ទាប់ពីគំរោងសាងសង់អណ្តូងបានបញ្ចប់រួចរាល់មក ក្រុមប្រឹក្សាឃុំអាចនិយាយបានថា អ្នកភូមិទាំងអស់មានសិទ្ធិប្រើប្រាស់អណ្តូងទាំងនោះ ហើយប្រជាជនមានលទ្ធភាពប្រើប្រាស់ទឹកស្អាតបានស្រួលជាងមុន ។</u>*

**២. ជួយកែលំអការគ្រប់គ្រង និងការធ្វើសេចក្តីសំរេចចិត្ត :** យើងអាចដឹងពីបញ្ហានានា ដែលកើតមានឡើងនៅក្នុងការអនុវត្ត និងការគ្រប់គ្រងគំរោង តាមរយៈការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ បើសិនជាគ្មានការតាមដានត្រួតពិនិត្យ និងវាយតំលៃទេនោះ យើងមិនអាចដឹងពីបញ្ហា ហើយក៏មិនអាចដោះស្រាយបញ្ហាទាំងនោះអោយបានទាន់ពេលវេលាដែរ លើសពីនេះទៅទៀត បញ្ហាទាំងនេះនឹងអាចកាន់តែអាក្រក់ខ្លាំងឡើងៗ និងទាមទារអោយមានចំណាយកាន់តែខ្ពស់សំរាប់ដំណោះស្រាយនាពេលក្រោយ ។

*ឧទាហរណ៍ : ឃុំ " **ក** " បានធ្វើការជួសជុលកែលំអផ្លូវលំមួយខ្សែ ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ ។ មានពាក្យចចាមអារ៉ាមថា អ្នកទទួលការធ្វើការជួសជុលផ្លូវនោះមិនបានល្អទេ ក្នុងការជួសជុលផ្លូវនោះ ។ សមាជិកក្រុមប្រឹក្សាមួយចំនួនបានចុះទៅពិនិត្យដល់ការដ្ឋានជួសជុលផ្លូវ ហើយបានរកឃើញថា មានកំណាត់ផ្លូវ*

*ដែលបានសាងសង់រួចប្រវែង ១០០ម៉ែត្រ ពុំត្រូវបានសាងសង់ទៅតាមបច្ចេកទេស ដូចដែលបានព្រមព្រៀងគ្នាពីមុនមកឡើយ ។ ក្រុមប្រឹក្សាឃុំបានទាមទារអោយអ្នកទទួលការ ធ្វើការកែលំអត្រង់កន្លែង ដែលអនុវត្តមិនបានតាមប្លង់បច្ចេកទេសនោះ ។ ក្រុមប្រឹក្សាឃុំក៏បានផ្តល់ដំណឹងពីបញ្ហានេះ ទៅអោយអ្នកត្រួតពិនិត្យបច្ចេកទេស ហើយពួកគាត់បានស្នើសុំឱ្យអ្នកត្រួតពិនិត្យបច្ចេកទេសនោះ ចុះពិនិត្យគំរោងឱ្យបានទៀងទាត់ជាងមុន (ច្រើនជាងមុន) ហើយអោយគាត់ធ្វើការទាក់ទងផ្តល់ដំណឹង និងពិភាក្សាជាមួយពួកគាត់ ស្តីពីបញ្ហាដែលពាក់ព័ន្ធនិងការអនុវត្តគំរោងនេះ អោយបានញឹកញាប់ ។*

**៣. ជំរុញអោយមានការរៀនសូត្រ :** ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ជួយក្រុមប្រឹក្សាឃុំ សង្កាត់ អោយយល់ដឹងពីអ្វីដែលធ្វើទៅល្អ និង អ្វីដែលធ្វើទៅមិនបានល្អ ។ តាមរយៈបទពិសោធន៍នេះ ក្រុមប្រឹក្សាឃុំអាចរៀបចំការអនុវត្តសកម្មភាពជាក់លាក់មួយចំនួនរបស់គំរោងណាមួយកាន់តែប្រសើរឡើងនាពេលអនាគត ។

*ឧទាហរណ៏ : នៅក្នុងសង្កាត់មួយ ក្រុមប្រឹក្សាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់មីក្រូហិរញ្ញវត្ថុសំរាប់កិច្ចអភិវឌ្ឍន៏សហគ្រាសខ្នាតតូច ។ ការវាយតំលៃគំរោងនៅចុងឆ្នាំទី១ បានអោយដឹងថា សហគ្រិនចំនួន ៣០% ជួបការខាតបង់ ដោយសារបញ្ហាមួយចំនួន ( ដូចជាកង្វះខាតការគាំទ្រផ្នែកបច្ចេកទេស ហើយមានស្ត្រីប្រមាណតែ ១៥% ប៉ុណ្ណោះដែលបានខ្ចីប្រាក់ពីគំរោងនេះ ) ។ ផ្អែកតាមបទពិសោធន៏នេះ អង្គការមិនមែនរដ្ឋាភិបាល និងសង្កាត់បានឯកភាពបន្តកិច្ចសហការណ៏សំរាប់ឆ្នាំបន្ទាប់ទៀត ប៉ុន្តែពួកគាត់បានឯកភាពលើការកែលំអមួយចំនួន ដើម្បីធានាអោយសហគ្រិនខ្នាតតូច អាចមានលទ្ធភាពរក្សានិរន្តរភាពមុខរបបររបស់ពួកគេបាន តាមរយៈការយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន លើការផ្តល់ឥណទានដល់ពួកគេ ។ លើសពីនេះត្រូវរកយុទ្ធសាស្ត្របង្កើនការផ្តល់ប្រាក់កំចីដល់ស្ត្រី ។*

**៤. ធានាគុណភាព និរន្តរភាព និងប្រសិទ្ធភាពនៃគំរោង :** ការតាមដានត្រួតពិនិត្យ និងវាយតំលៃ នឹងអាចធ្វើអោយការអនុវត្តគំរោងទទួលបានគុណភាពកាន់តែល្អ ហើយឃុំ សង្កាត់អាចទទួលបានផលប្រយោជន៏ពីគំរោងក្នុងរយៈពេលយូរអង្វែង ។

*ឧទាហរណ៏ : តាមរយៈការតាមដានចុងបញ្ចប់គំរោងនៅក្នុងឃុំមួយ ក្រុមប្រឹក្សាឃុំបានកត់សំគាល់ឃើញថា មានអណ្តូងមួយចំនួនមិនត្រូវបានគេថែទាំបានល្អឡើយ ។ ហេតុនេះក្រុមប្រឹក្សាឃុំបានរៀបចំការប្រជុំជាមួយក្រុមអ្នកប្រើប្រាស់អណ្តូងទាំងនេះ ដើម្បីជជែកពិភាក្សា ថាតើពួកគាត់មានបញ្ហាអ្វីខ្លះ និងធ្វើយ៉ាងណា ដើម្បីទទួលបានការប្តេជ្ញាចិត្តខ្ពស់ពីប្រជាជន ក្នុងភូមិក្នុងការថែទាំអណ្តូងទាំងនេះ ។*

## ២.២. មូលដ្ឋានច្បាប់សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ

ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ គឺជាកាតព្វកិច្ចផ្លូវច្បាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ កាតព្វកិច្ចនេះមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបទបញ្ញត្តិផ្សេងៗទៀត ។

### 🕮 ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃកំរិតអាទិភាពនៃការអភិវឌ្ឍន៍ និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលសេចក្តីត្រូវការក្នុងឃុំ សង្កាត់ និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវាកម្ម និង ការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវា និងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យតាមដាន និងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍ពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋ របស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតំលៃ ទៅលើការអនុវត្តផែនការ កម្មវិធី គំរោង និងការផ្តល់សេវាកម្មនានា អោយមានតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ។

## មាត្រា ៦៧.-

ក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតំលៃផែនការ កម្មវិធី និងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយ ដែលខ្លួនបានជ្រើសរើស ។

## 🕮 អនុក្រឹត្យស្តីពីការរៀបចំប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់

## មាត្រា ២៤.-

ប្រព័ន្ធគណនេយ្យឃុំ សង្កាត់ ត្រូវបំរើនូវគោលបំណងទាំងឡាយដូចខាងក្រោម :

១. បញ្ជីការរាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

២. ធ្វើរបាយការណ៍ហិរញ្ញវត្ថុជាក់ស្តែងឱ្យទាន់ពេលវេលា ដែលអាចជាកម្មវត្ថុសំរាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

៣. ផ្តល់មូលដ្ឋានសំរាប់ការតាមដានការអនុវត្តថវិការបស់ឃុំ សង្កាត់ ។

គណនេយ្យឃុំ សង្កាត់ រួមមាន :

ក. គណនេយ្យហិរញ្ញវត្ថុ : គណនា ចុះបញ្ជី និងធ្វើរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរបស់ឃុំ សង្កាត់

ខ. គណនេយ្យថវិកា : តាមដាន និងធ្វើរបាយការណ៍ ស្តីពីការអនុវត្តថវិកាដែលបានអនុម័ត ។

## មាត្រា ៣៤.-

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបំរើនូវគោលបំណងដូចខាងក្រោម :

១). តាមដានត្រួតពិនិត្យកិច្ចប្រតិបត្តិការចំណូល និងចំណាយរបស់ឃុំ សង្កាត់ ដោយប្រៀបធៀបជាមួយនឹងការព្យាករណ៍ថវិកា

២). វាយតំលៃស្ថានភាពហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ដោយផ្តល់នូវពត៌មានអំពីប្រភព និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ

៣). បង្កលក្ខណៈដល់មេឃុំ ចៅសង្កាត់ក្នុងការទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់លើ

៤). ឆ្លុះបញ្ចាំងអោយឃើញថា កិច្ចប្រតិបត្តិការឆ្លើយតបបានទៅនឹងថវិកាដែលបានអនុម័ត និងបទបញ្ញត្តិគតិយុត្តិផ្សេងទៀត ។

## មាត្រា ៣៦.-

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវភ្ជាប់ជាមួយនូវរបាយការណ៍លំអិត ស្តីពីសកម្មភាពរបស់ឃុំ សង្កាត់ ។ របាយការណ៍សកម្មភាពប្រចាំឆ្នាំត្រូវពិពណ៌នា និងវាយតំលៃ :

- ការអនុវត្តការងាររបស់ឃុំ សង្កាត់ ក្នុងការប្រមូលចំណូល និងចំណាយ
- សមិទ្ធផលរបស់ឃុំ សង្កាត់ក្នុងការផ្តល់សេវាសាធារណៈ ប្រៀបធៀបជាមួយនឹងទិសដៅ ផែនការ
- ស្ថានភាពសេដ្ឋកិច្ចរបស់ឃុំ សង្កាត់ និង ផលប៉ះពាល់ពីប្រតិបត្តិការរបស់ឃុំ សង្កាត់ លើសុខមាលភាពរបស់ប្រជាជន ។

របាយការណ៍សកម្មភាព ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ ។

របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាព ជាឯកសារជំនួយក្នុងការបិទបញ្ជីគណនីឃុំ សង្កាត់ តាមការកំណត់ ។

## មាត្រា ៥៩.-

ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យ តាមដានការអនុវត្តរបស់ក្រុមប្រឹក្សា និងរដ្ឋបាលឃុំ សង្កាត់ ។ មេឃុំ ចៅសង្កាត់ត្រូវធានាថា :

១). រាល់ពត៌មានស្តីពីសកម្មភាព និងគណនីរបស់ឃុំ សង្កាត់ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ

២). ការទទួលមតិសាធារណៈ និង ការពិគ្រោះយោបល់ ត្រូវបានប្រព្រឹត្តទៅក្នុងដំណើរការរៀបចំថវិកា

៣). ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត និង អញ្ជើញអោយចូលរួម ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## 🕮 ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

## ប្រការ ២១.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតយន្តការសមស្របនានា ដើម្បីសំរបសំរួលរាល់ការចូលរួមពាក់ព័ន្ធរបស់អ្នកទទួលផលផ្ទាល់នៅក្នុងគំរោងលំអិតនានា និងត្រួតពិនិត្យ · ណែនាំការអនុវត្តគំរោងទាំងអស់ ដែលមានក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

## ប្រការ ២៤.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដានការវិវឌ្ឍន៍ ភាពរីកចំរើននៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ ប្រការនេះ រួមបញ្ចូលសកម្មភាពទាំងឡាយណាដែលបានអនុវត្ត នៅក្នុងដែនដីឃុំ សង្កាត់ ដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និង ផ្នែកឯកជន ។

ការតាមដានអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ មិនត្រូវបង្ករការរាំងស្ទះ ដល់សិទ្ធិរបស់អង្គភាពពាក់ព័ន្ធ ដែលត្រូវធ្វើការតាមដាន និង វាយតំលៃលើសកម្មភាពនានា ទាក់ទងនឹងគំរោងដែលពួកគេកំពុងគាំទ្រដល់ឃុំ សង្កាត់ឡើយ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាអោយមានអន្តរាគមន៍ឆាប់រហ័ស ដើម្បីដោះស្រាយការលំបាក ឬបញ្ហា នានា ដែលកើតមានឡើងជាយថាហេតុ ក្នុងអំឡុងពេលអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

## ប្រការ ២៥.-

ការវាយតំលៃគ្រប់ជ្រុងជ្រោយទៅលើលទ្ធផល និងផលប៉ះពាល់នៃការអនុវត្តគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំធ្វើឡើងក្នុងអំឡុងពេល ៦ខែ មុនផុតអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ត្រូវរួមគ្នារៀបចំចេញសេចក្តីណែនាំលំអិត ស្តីពីវិសាលភាព និងទំរង់ បែបបទសំរាប់ការងារវាយតំលៃនេះ ។

## ៣. គំរោង និងសមាសភាគដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ

ក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ ជាបឋមយើងត្រូវពិនិត្យលើចំណុចនានាដែលមានទំនាក់ទំនងជាមួយនឹងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ និងផែនការថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។ ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវផ្តោតទៅលើ :

### ៣.១. គំរោងអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មនៅក្នុងឃុំ សង្កាត់

ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អង្គការ និងភ្នាក់ងារផ្សេងៗជាតួអង្គដែលសកម្មក្នុងការអនុវត្តគំរោងអភិវឌ្ឍន៍នានានៅក្នុងឃុំ សង្កាត់ ។ គោលដៅនៃការអនុវត្តគំរោង រួមជាមួយនឹងសកម្មភាពអភិបាលកិច្ចរបស់ឃុំ សង្កាត់ គឺដើម្បីជួយជំរុញ និងគ្រប់គ្រងផលប្រយោជន៍ឃុំ សង្កាត់ ព្រមទាំងធ្វើអោយប្រសើរឡើងនូវការរស់នៅរបស់ប្រជាជននៅក្នុងឃុំ សង្កាត់ ។




☞ ការអនុវត្តគំរោងអភិវឌ្ឍន៍ និងការផ្តល់សេវាកម្ម គឺដើម្បីកែលំអ ស្ថានភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សង្កាត់ ។

☞ ដូចនេះ ការតាមដានត្រួតពិនិត្យ និងវាយតំលៃឃុំ សង្កាត់ នឹងផ្តោតទៅលើ :

- ថាតើគំរោងត្រូវបានអនុវត្តយ៉ាងដូចម្តេច (ដើម្បីទទួលបានពត៌មានពីស្ថានភាពទូទៅ និងរបៀបចាត់ចែងធនធាននៅក្នុងឃុំ សង្កាត់របស់ខ្លួន) ។
- ថាតើក្រុមប្រឹក្សាឃុំ សង្កាត់បានអនុវត្តភារកិច្ចជារដ្ឋាភិបាលមូលដ្ឋានយ៉ាងដូចម្តេច ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ដោយយកចិត្តទុកដាក់ជាចំបងទៅលើសកម្មភាព និងគំរោងនានាដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និង គំរោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។ គំរោងទាំងនោះអាចជា :

- គំរោងមួយ ឬច្រើនដែលអនុវត្តដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងប្រភពធនធានដ៏ទៃទៀតដែលឃុំ សង្កាត់មាន (ធនធានដែលឃុំ សង្កាត់អាចកៀងគរបានដោយខ្លួនឯង) ។
- ការបំរើសេវាកម្មរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដល់ប្រជាពលរដ្ឋរបស់ខ្លួន ដោយប្រើថវិការបស់ឃុំ សង្កាត់ ឬធនធានផ្សេងៗទៀត ។

ដើម្បីធ្វើការសំរេចចិត្ត ថាតើត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃលើអ្វីខ្លះ គេត្រូវពិនិត្យលើគោលបំណងរបស់គំរោងនីមួយៗ ដែលបាននឹងកំពុងអនុវត្ត និងថាតើគំរោងនោះត្រូវបានអនុវត្តយ៉ាងដូចម្តេច ។ ការតាមដានត្រួតពិនិត្យ ត្រូវផ្តោតទៅលើអ្វីដែលបានកើតឡើងក្នុងអំឡុងពេលអនុវត្តគំរោង ហើយការវាយតំលៃក៏ត្រូវផ្តោតជាសំខាន់ទៅលើលទ្ធផលចុងក្រោយ (ផលប៉ះពាល់ ឬបំរែបំរួលលើប្រជាពលរដ្ឋគោលដៅ) របស់គំរោង ។

ដូចនេះ ការតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់ត្រូវធ្វើទៅលើ :

- ការងារ ទំនិញ និងសេវាកម្មនានា (រួមទាំងការថែទាំ និងសកម្មភាពសង្គម) ដែលអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងធនធានផ្សេងៗទៀតដែលឃុំ សង្កាត់មាន (ដូចជាការឧបត្ថម្ភពីសប្បុរសជននានា)
- ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការអនុវត្តមុខងារជាភ្នាក់ងារផ្សេងៗទៀតរបស់ឃុំ សង្កាត់
- ការអនុវត្តតួនាទីទូទៅរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលជារដ្ឋាភិបាលមូលដ្ឋានស្របទៅនឹងច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។ នេះមានន័យថា ការតាមដានត្រួតពិនិត្យ នឹងផ្តោតទៅលើការអនុវត្តភារកិច្ចរដ្ឋបាល ដូចជា តើក្រុមប្រឹក្សាធ្វើការប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយខែឬ? ការអនុវត្តបទបញ្ជាផ្ទៃក្នុង របាយការណ៍ ទំនាក់ទំនងជាមួយប្រជាពលរដ្ឋមូលដ្ឋាន និងការគ្រប់គ្រងហិរញ្ញវត្ថុ...។ល។

ដូចដែលបានបង្ហាញក្នុងរូបភាពខាងលើ គំរោងអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មនានា ដែលផ្តល់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ គឺបានគ្រប់ដណ្តប់តែមួយផ្នែកប៉ុណ្ណោះ លើការអភិវឌ្ឍន៍ជាទូទៅនៅក្នុងឃុំ សង្កាត់ ។

ដូចនេះ ការតាមដានត្រួតពិនិត្យ និងវាយតំលៃ មិនគួរពិនិត្យតែគំរោងអភិវឌ្ឍន៏ និងសេវាកម្មដែលផ្តល់ដោយឃុំ សង្កាត់នោះទេ គឺត្រូវពិនិត្យផងដែរលើសកម្មភាព ឬគំរោងនានាដែលអនុវត្តដោយភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជននៅក្នុងឃុំ សង្កាត់របស់ខ្លួន ។ ទោះបីជាក្រុមប្រឹក្សាឃុំ សង្កាត់ មិនមែនជាអ្នកអនុវត្តគំរោងទាំងនោះក៏ដោយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់ទៅលើរបៀបអនុវត្ត និងផ្តល់យោបល់ខ្លះៗ ស្តីពីសារៈប្រយោជន៏ និងផលប៉ះពាល់របស់សកម្មភាពទាំងនោះផងដែរ ដល់ម្ចាស់គំរោង និងអ្នកពាក់ព័ន្ធ ។

## ៣.២. សមាសភាគរបស់គំរោងដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ

ដើម្បីជាជំនួយក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ ជាការសំខាន់ដែលយើងត្រូវយល់អោយបានច្បាស់ពីតក្កភាពរបស់គំរោង (Logic) ។ ហេតុអ្វីបានជាយើងយល់ថា គំរោងអាចធ្វើអោយជីវភាពរស់នៅរបស់យើងបានល្អប្រសើរជាងមុន? ហើយតើគំរោងត្រូវអនុវត្តយ៉ាងដូចម្តេច ដើម្បីសំរេចបានគោលបំណងនេះ? តើមានហេតុផលអ្វីខ្លះ ដែលត្រូវជ្រើសរើសអនុវត្តគំរោងណាមួយនោះ?

វិធីសាស្ត្រមួយដែលយើងអាចបង្ហាញពីតក្កភាពនេះបាន គឺពិនិត្យលើសង្វាក់នៃសកម្មភាព ឬដំណាក់កាលទាំង៤របស់គំរោង ។ ការតាមដានត្រួតពិនិត្យ និងការវាយតំលៃលើកំរិតទាំង៤នេះ មានលក្ខណៈខុសគ្នាតិចតួច ។




<u>ឧទាហរណ៍</u>

ប្រជាពលរដ្ឋនៅក្នុងឃុំក្រវាញ បានសំរេចចិត្តប្រើប្រាស់មូលនិធិឃុំរបស់ខ្លួន ដើម្បីទិញម៉ាស៊ីនបូមទឹកចំនួន ៥ ដែលម៉ាស៊ីនទាំងអស់នេះ អាចអោយប្រជាពលរដ្ឋបូមទឹកពីទន្លេ បញ្ចូលស្រែ ។ ម៉ាស៊ីនបូមទឹកនេះនឹងត្រូវដាក់អោយប្រជាពលរដ្ឋប្រើប្រាស់ ដោយផ្លាស់ប្តូរវេនគ្នា ដោយត្រូវបង់ថ្លៃក្នុងចំនួនមួយកំណត់ សំរាប់ថ្លៃប្រេង និងការថែទាំ ។

| | |
|---|---|
| ធនធាន និងទុន | • ម៉ាស៊ីនបូមទឹកចំនួន៥ ដែលមានភ្ជាប់ទុយយ៉ូស្រាប់<br>• ក្រុមអ្នកប្រើប្រាស់ ដែលជួយចាត់ចែងការប្រើប្រាស់ទឹកយ៉ាងត្រឹមត្រូវ នឹងធានាអោយមានការបង់ថ្លៃប្រើប្រាស់ទឹក និងធានាការថែទាំម៉ាស៊ីននោះ ។ |
| សកម្មភាព | • អោយកសិករក្នុងឃុំខ្ចីម៉ាស៊ីនបូមទឹកនេះ ដោយប្តូរវេណគ្នា ។ ធ្វើដូចនេះ ពួកគេអាចបូមទឹកពីទន្លេ ហើយបញ្ចូលទឹកទៅក្នុងស្រែរបស់ពួកគេបានគ្រប់ៗគ្នា ។<br>• ការប្រជុំជាទៀងទាត់របស់ក្រុមអ្នកប្រើប្រាស់ទឹក ដើម្បីធានាអោយការប្រើប្រាស់ និងការថែទាំបានល្អ ។ |
| លទ្ធផល | • ផលិតផលកសិកម្មកើនឡើង<br>• ដំណើរការដ៏ល្អរបស់ក្រុមអ្នកប្រើប្រាស់ទឹក ដែលអាចចាត់ចែងការប្រើប្រាស់ទឹកបានល្អ និងមាននីរន្តភាព ។ |
| ផលប៉ះពាល់ | • ជីវភាពរបស់កសិករបានប្រសើរឡើង ហើយទទួលបានចំណូលច្រើនជាងមុន ដើម្បីដោះស្រាយតំរូវការគ្រួសារ ដែលទាំងអស់នេះ ធ្វើអោយគ្រួសារជាច្រើនក្នុងឃុំកាន់តែធូធារ<br>• សមត្ថភាពរបស់ក្រុមអ្នកប្រើប្រាស់ទឹកកាន់តែប្រសើរឡើង ដើម្បីជួយធ្វើអោយប្រសើរនូវប្រតិបត្តិការ និងការគ្រប់គ្រងក្រុមផ្សេងៗទៀត ក្នុងឃុំរបស់ខ្លួន ។ |

### ៣.២.១. ធនធាន និងទុន (Inputs)

ធនធាន គឺជាអ្វីដែលឃុំ សង្កាត់មាន និង អ្វីដែលបានកៀងគរសំរាប់អនុវត្តគំរោង ឬ សេវាកម្មអ្វីមួយ ។ ជាធម្មតា ធនធានទាំងនេះ រួមមាន÷

- ថវិកាគំរោង ( ដើម្បីចំណាយទៅលើសំភារៈ និងថ្លៃពលកម្ម ) ឬក៏មូលនិធិ ដើម្បីផ្តល់សេវាកម្មនានា
- ពេលវេលា សំភារៈ ឧបករណ៍ និងទុនចូលរួមរបស់សហគមន៍
- ធនធានជាស្ថាប័ន ដូចជា គណៈកម្មាធិការកសាងផែនការនិងថវិកា គណៈកម្មាធិការគ្រប់គ្រងគំរោង និងក្រុមអ្នកប្រើប្រាស់... ។ល។

ការតាមដានត្រួតពិនិត្យទៅលើការប្រើប្រាស់ធនធាន នឹងប្រាប់អោយយើងដឹងថា តើមានធនធានអ្វីខ្លះក្នុងបរិមាណប៉ុន្មានដែលបានប្រើប្រាស់សំរាប់អនុវត្តសកម្មភាព ។

### ៣.២.២. សកម្មភាព

សកម្មភាព គឺជាការអនុវត្តផែនការការងារដែលបានរៀបចំ ដោយប្រើប្រាស់ធនធានទាំងឡាយដែលឃុំ សង្កាត់មាន និងដែលបានកៀងគរ ដើម្បីទទួលបានលទ្ធផលជាក់លាក់ណាមួយ ។

☞ ការតាមដានត្រួតពិនិត្យលើសកម្មភាព នឹងអាចប្រាប់យើងអោយដឹងពីការអនុវត្តសកម្មភាពដែលគ្រោងទុក និងការរីកចំរើនរបស់វា :

- តើមានសកម្មភាពអ្វីខ្លះដែលកំពុងអនុវត្ត ? តើសកម្មភាពទាំងនោះត្រូវបានអនុវត្ត ដោយមានការប្រើប្រាស់ធនធានសមស្របដែរឬទេ ?
- តើគំរោងនោះត្រូវបានអនុវត្តស្របទៅតាមផែនការ ឬ តាមការរំពឹងទុកដែរឬទេ (កាលវិភាគ និង ទីកន្លែង) ?
- តើមានបញ្ហា និងការលំបាកអ្វីខ្លះ ក្នុងការអនុវត្តសកម្មភាពណាមួយ ? តើត្រូវដោះស្រាយបែបណាចំពោះបញ្ហា និងការលំបាកទាំងនេះ ?

### ៣.២.៣. លទ្ធផល

លទ្ធផល គឺជាផលដោយផ្ទាល់ចេញពីការអនុវត្តសកម្មភាព ។ វាអាចជាផលដែលមានរូបរាង (រូបវ័ន្ត) ដូចជា ស្ពានថ្មី ផ្លូវ ឧបករណ៍ថ្មីសំរាប់ផលិតផលកសិកម្មជាដើម ឬផលដែលគ្មានរូបរាង (មិនរូបវ័ន្ត) ដូចជា ជំនាញក្នុងការកំចាត់សត្វល្អិត ជំនាញក្នុងការដាំដុះ និង ជំនាញតម្បាញ... ។ល។

☞ ការតាមដានត្រួតពិនិត្យលើលទ្ធផល នឹងប្រាប់អោយយើងដឹងពីលទ្ធផលនៃសកម្មភាព :

- តើការអនុវត្តសកម្មភាព ទទួលបានលទ្ធផល ដូចដែលយើងរំពឹងទុកដែរឬទេ ?
- តើប្រជាពលរដ្ឋមានការសង្កេត និងចំណាប់អារម្មណ៍យ៉ាងដូចម្តេច ទៅលើលទ្ធផលនោះ ?

### ៣.២.៤. ផលប៉ះពាល់

ផលប៉ះពាល់ គឺជាលទ្ធផលចុងក្រោយរបស់គំរោង ដែលធ្វើអោយស្ថានភាពរស់នៅរបស់ក្រុមគោលដៅមានការប្រែប្រួល ។ ផលប៉ះពាល់អាចជាផលវិជ្ជមាន (ជាអ្វីដែលយើងចង់បាន) ឬអវិជ្ជមាន (ជាអ្វីដែលយើងមិនចង់អោយកើតឡើង ឬអ្វីដែលយើងមិនបានគិត តែបានកើតឡើង)។ ផលប៉ះពាល់របស់គំរោង អាចជាការប្រែប្រួលរបស់មនុស្ស ដូចជា ចំណេះដឹង របៀបរបបរស់នៅ និងការប្រើប្រាស់លទ្ធផលគំរោងរបស់ប្រជាពលរដ្ឋគោលដៅ ។ ជួនកាលយើងអាចទទួលបានផលប៉ះពាល់ភ្លាមៗ ក្រោយពេលគំរោងបានបញ្ចប់ (ដូចជាការកើនឡើងនៃការធ្វើចរាចរលើផ្លូវដែលទើបជួសជុលរួច) តែក្នុងករណីខ្លះ ផលប៉ះពាល់អាចចេញជារូបរាងក្នុងរយៈពេល

ជាច្រើនឆ្នាំ ក្រោយពីគំរោងបានបញ្ចប់ ( ឧទាហរណ៍ : ការដាំដើមឈើឡើងវិញ) ដើម្បីកាត់បន្ថយការច្រោះដី និង បង្កើនបរិមាណទឹកលើផ្ទៃដី ជាដើម ។

ជាទូទៅ មានគំរោងជាច្រើនដែលរួមចំណែក ធ្វើអោយមានផលប៉ះពាល់អ្វីមួយក្នុងរយៈពេលជាច្រើនឆ្នាំ ។ ឧទាហរណ៍: ការកាត់បន្ថយភាពក្រីក្រក្នុងឃុំមួយ ជាទូទៅគឺមិនមែនជាលទ្ធផលរបស់គំរោងណាមួយតែឯងនោះទេ ( ដូចជាគំរោងសាងសង់ផ្លូវថ្មីមួយ គំរោងអប់រំ ឬគំរោងផ្តល់សេវាសុខភាព ) តែគំរោងទាំងអស់នេះ រួមផ្សំជាមួយនឹងកត្តាផ្សេងៗទៀត ( ដូចជាឱកាសរកការងារបានល្អប្រសើរជាងមុន ) បានចូលរួមចំណែកធ្វើអោយមានផលប៉ះពាល់លើការកាត់បន្ថយភាពក្រីក្រក្នុងឃុំនោះ ។

☞ ការវាយតំលៃផលប៉ះពាល់ នឹងប្រាប់អោយយើងដឹងថា តើគំរោងទទួលបានជោគជ័យដែរឬទេ ហើយតើគំរោងនោះបានធ្វើអោយមានការប្រែប្រួលអ្វីខ្លះ និងក្នុងកំរិតណា ។

☞ បើសិនជាយើងពិនិត្យលើផលប៉ះពាល់នៅពេលបញ្ចប់សកម្មភាពណាមួយ យើងត្រូវផ្តោតលើ :

- ការប្រើប្រាស់លទ្ធផលរបស់គំរោង
- ការអនុវត្តចំណេះដឹង និងជំនាញដែលទើបទទួលបាន

☞ បើសិនជាយើងចង់ដឹងពីផលប៉ះពាល់រយៈពេលយូរ បន្ទាប់ពីគំរោងបានបញ្ចប់ យើងត្រូវផ្តោតទៅលើ :

- ការផ្លាស់ប្តូរឥរិយាបថ ( ការប្រព្រឹត្ត)
- ស្ថានភាពសុខុមាលភាពបុរស និងស្ត្រី ដែលរស់នៅក្នុងឃុំ សង្កាត់
- កំរិតនៃការពេញចិត្តលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

## ៤. ពេលវេលាដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ

ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ ត្រូវបានធ្វើក្នុងអំឡុងពេលពេញមួយឆ្នាំ ។ គំរោងណាមួយត្រូវបានតាមដានត្រួតពិនិត្យ ឬវាយតំលៃ គឺអាស្រ័យទៅតាមដំណាក់កាលនីមួយៗនៃដំណើរការអនុវត្ត ។

- ការតាមដានត្រួតពិនិត្យត្រូវបានធ្វើជាប្រចាំ និង ទៀងទាត់ក្នុងអំឡុងពេលនៃការអនុវត្តគំរោង ( ប្រចាំ សប្តាហ៍ ប្រចាំខែ ឬប្រចាំត្រីមាស អាស្រ័យទៅតាមទំហំសកម្មភាពរបស់គំរោង ) ។
- ការវាយតំលៃត្រូវបានធ្វើឡើងនៅពេលវេលាជាក់លាក់ណាមួយ ដូចជា ពាក់កណ្តាលគំរោង ជិតបញ្ចប់គំរោង និងពេលបញ្ចប់គំរោង ឬក្រោយពីគំរោងបានបញ្ចប់ ។

នៅពេលអនុវត្តគំរោង គេត្រូវធ្វើការតាមដានត្រួតពិនិត្យ ឱ្យបានញឹកញាប់ រហូតដល់គំរោងបានបញ្ចប់ ។ ចំពោះគំរោងសេវាកម្មដែលផ្តល់សេវាជាប្រចាំ គេត្រូវធ្វើការតាមដានត្រួតពិនិត្យជាប្រចាំដែរ ។

សំរាប់គំរោង ឬសេវាកម្មដែលមានសកម្មភាពតែមួយ ដូចជាការផ្តល់ធនធាន ឬទុន (Inputs) ផ្នែកកសិកម្ម ឬសកម្មភាពបណ្តុះបណ្តាលរយៈពេលមួយថ្ងៃ នោះការតាមដានត្រួតពិនិត្យ ត្រូវកំរិតមកនៅត្រឹមការចុះទៅពិនិត្យមើលជាក់ស្តែងតែម្តង ដើម្បីមើលថា តើសកម្មភាពបានអនុវត្តតាមការគ្រោងទុកដែរឬទេ ។ រយៈពេល ២ ឬ ៣ខែក្រោយមកគួរចុះពិនិត្យមើល ដើម្បីចង់ដឹងថាតើសកម្មភាពដែលបានធ្វើរួចហើយនោះ ទទួលលទ្ធផលតាមការគិតទុកដែរឬទេ ( តើធនធានផ្នែកកសិកម្មបានត្រូវប្រើប្រាស់សមស្របដែរឬទេ ? តើការបណ្តុះបណ្តាលនោះបាន ធ្វើអោយមានការផ្លាស់ប្តូរអ្វីខ្លះ ? ) ។

ចំពោះគំរោងណាមួយ ដែលមានសកម្មភាពច្រើន គួរតែមានការចុះទៅតាមដានត្រួតពិនិត្យ និងវាយតំលៃជាទៀងទាត់ក្នុងអំឡុងពេលអនុវត្តគំរោង និងក្រោយពេលបញ្ចប់គំរោង ដូចជា ៖

- ការចុះពិនិត្យបន្តិចនៅពេលចាប់ផ្តើមគំរោង និងកំពុងដំណើរការគំរោង ដើម្បីចង់ដឹងថា តើគំរោងបានចាប់ផ្តើមហើយឬនៅ និង ថាតើការអនុវត្តគំរោងមានលក្ខណៈត្រឹមត្រូវ អាចទទួលយកបានដែរឬទេ ?
- ការចុះទៅពិនិត្យនៅពេលគំរោងបញ្ចប់ ដើម្បីពិនិត្យមើលថា តើលទ្ធផលរបស់គំរោងតាមការរំពឹងទុកដែរឬទេ ។
- បន្តការចុះពិនិត្យ ២ឬ៣ខែក្រោយមក ដើម្បីមើលថា តើគំរោងមានផលប៉ះពាល់អ្វីខ្លះហើយ និង ដើម្បីពិនិត្យមើលលក្ខខណ្ឌនៃលទ្ធផលរបស់គំរោង ។

ករណីនេះមិនមានន័យថាឃុំ សង្កាត់ មានសិទ្ធិធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃតែ ៣លើកនេះទេ គឺមានសិទ្ធិចុះតាមដានត្រួតពិនិត្យ និងវាយតំលៃក្នុងពេលផ្សេងៗទៀត ។ បើសិនជាការចុះតាមដានត្រួតពិនិត្យ និងវាយតំលៃនេះ អាចឱ្យអ្នកទទួលការដឹងជាមុន អ្នកទទួលការដែលខិលខូចនឹងមានការសប្បាយរីករាយ ដោយសារឃុំ សង្កាត់មានឱកាសតិចតួចណាស់ដែលអាចចាប់កំហុសគេបាន ។ ពេលគំរោងកំពុងតែអនុវត្ត ឃុំ សង្កាត់ត្រូវចាត់ទុកការតាមដានត្រួតពិនិត្យការអនុវត្តគំរោងជាអាទិភាព ដើម្បីអោយប្រាកដថា អ្វីៗទាំងអស់កំពុងតែធ្វើទៅតាមផែនការ ។

គ្រប់គំរោងតូចៗទាំងអស់ ការចុះតាមដានត្រួតពិនិត្យ និងវាយតំលៃ គួរធ្វើតែ ២ឬ៣ដង គឺអាចគ្រប់គ្រាន់ហើយ ។ ប៉ុន្តែសំរាប់គំរោងភាគច្រើន ជាពិសេសគំរោងដែលមានរយៈពេលយូរ និងគំរោងដែលមានលក្ខណៈបច្ចេកទេសពិបាកៗ ឬ ត្រូវការធនធានច្រើននោះ ចាំបាច់ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃអោយបានញឹកញាប់ ព្រោះថាការតាមដាន ត្រួតពិនិត្យ និងវាយតំលៃ អាចចង្អុលបង្ហាញពីបញ្ហា និង ឧបសគ្គនានាដែលអាចនឹងនាំទៅរកផ្លូវខុស ឬ បរាជ័យ ។

គេអាចធ្វើការតាមដានត្រួតពិនិត្យជាញឹកញាប់ ឬមិនសូវញឹកញាប់ គឺអាស្រ័យលើប្រភេទនៃសកម្មភាព និង ភាពងាយស្រួលក្នុងការធ្វើដំណើរទៅដល់ការដ្ឋាននោះ ។ បើសកម្មភាពធ្វើនៅក្បែរផ្ទះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នោះការតាមដានត្រួតពិនិត្យអាចធ្វើឡើងបានរាល់ថ្ងៃ ។ ចំពោះសកម្មភាពដែលអនុវត្តនៅទីឆ្ងាយ ហើយប្រហែលជាមិនសូវមានកំហុសធំដុំទេនោះ គេអាចធ្វើការតាមដានត្រួតពិនិត្យម្តងក្នុងមួយខែ គឺអាចគ្រប់គ្រាន់ ។ ជាគោលការណ៍ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់មនុស្សម្នាក់ឱ្យចុះធ្វើការតាមដានត្រួតពិនិត្យ យ៉ាងហោចណាស់អោយបានម្តងក្នុងមួយខែទៅលើការអនុវត្តគំរោងនីមួយៗ ។

ក្នុងការកំណត់ពេលចុះតាមដានត្រួតពិនិត្យ និងវាយតំលៃ គេត្រូវតែពិចារណាថាតើដំណាក់កាលណាដែលសំខាន់ក្នុងការអនុវត្តគំរោង ។ ឧទាហរណ៍ គំរោងសាងសង់ដែលត្រូវសាងសង់ដោយបេតុង ជានិច្ចកាលត្រូវចុះតាមដានត្រួតពិនិត្យដល់ទីកន្លែងមុនពេលចាក់បេតុង ដើម្បីធ្វើអោយប្រាកដថា អ្នកទទួលការបានដាក់ដែកសរសៃត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសឬទេ ។ ចំពោះគំរោងសាងសង់ធារាសាស្ត្រវិញ ជាការចាំបាច់ដែលត្រូវធ្វើការតាមដានត្រួតពិនិត្យអោយបានច្បាស់លាស់មុនពេលដាក់អោយប្រើប្រាស់ ។ ចំណែកសកម្មភាពផ្សេងទៀត ការកំណត់ពេលវេលា សំរាប់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃមិនសូវលំបាកទេ ។

## ៥. អ្នកពាក់ព័ន្ធនឹងការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ

### ៥.១. ក្រុមប្រឹក្សាឃុំ សង្កាត់

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺជាការទទួលខុសត្រូវរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូច្នេះជាការសំខាន់ណាស់ដែលក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវយល់ដឹងអំពីគោលការណ៍ជាមូលដ្ឋានក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចទទួលបាននូវការជួយគាំទ្រលើការតាមដានត្រួតពិនិត្យ និង វាយតំលៃពីអ្នកផ្សេងៗ ប៉ុន្តែការទទួលខុសត្រូវចុងក្រោយលើការតាមដានត្រួតពិនិត្យ និងវាយតំលៃនេះ មិនអាចផ្ទេរទៅអោយអ្នកផ្សេងទៀតបានឡើយ ។

☞ ក្រុមប្រឹក្សាឃុំ សង្កាត់អាចទទួលបានជំនួយ ឬ ការជួយគាំទ្រលើការតាមដានត្រួតពិនិត្យ និងវាយតំលៃពី :

### ៥.២. ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់

ឆ្លងតាមបទពិសោធន៍កន្លងមកបានបង្ហាញថា នៅក្នុងក្រុមមួយដែលសមាជិកទាំងអស់សុទ្ធតែមានភារកិច្ចទទួលខុសត្រូវ នៅទីបញ្ចប់ អ្នកទាំងអស់នោះនឹងមិនមានអារម្មណ៍ថា ខ្លួនមានការទទួលខុសត្រូវឡើយ ពីព្រោះម្នាក់ៗគិតថា អ្នកផ្សេងទៀតដែលជាសមាជិកក្នុងក្រុមនឹងធ្វើកិច្ចការនោះ ដូចពាក្យចាស់លោកថា " ក្អាច្រើនអន្សមខ្លោច " ។ ហេតុដូច្នេះហើយ ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ទើបក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំ (លេខ ០០៥ សណន. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការជ្រើសរើសជនបង្គោលរបស់ឃុំ សង្កាត់សំរាប់ការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ) សំរាប់អោយឃុំ សង្កាត់ទាំងអស់ ធ្វើការជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ០១ នាក់ និងសមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកា ០១ នាក់ ជាជនបង្គោលសំរាប់ការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ ដែលក្នុងចំណោមអ្នកទាំង ០២ នាក់នេះ ត្រូវតែមានស្ត្រី ០១ នាក់ ។

☞ ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃឃុំ សង្កាត់ មានភារកិច្ចដូចខាងក្រោម :

- សំរបសំរួលរាល់សកម្មភាពពាក់ព័ន្ធនឹងការងារតាមដានត្រួតពិនិត្យ និងវាយតំលៃនៅក្នុងឃុំ សង្កាត់
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើការបណ្តុះបណ្តាលអំពីការងារតាមដានត្រួតពិនិត្យ និង វាយតំលៃ ដល់សមាជិកក្រុមប្រឹក្សា និងសមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកា

- ចូលរួមប្រជុំជាមួយមន្ត្រីត្រួតពិនិត្យបច្ចេកទេស អំពីដំណើរការអនុវត្តគំរោងនៅក្នុងឃុំ សង្កាត់
- ចុះត្រួតពិនិត្យជាប្រចាំលើដំណើរការអនុវត្តគំរោងក្នុងឃុំ សង្កាត់
- ជំរុញប្រជាពលរដ្ឋទាំងស្ត្រី និងបុរសដែលរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន អោយចូលរួមចំណែកក្នុងសកម្មភាពការងារតាមដានត្រួតពិនិត្យ និងវាយតំលៃកិច្ចការរបស់ឃុំ សង្កាត់
- ត្រូវរាយការណ៍អំពីដំណើរការអនុវត្តគំរោង និងបញ្ហាជួបប្រទះ ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការកសាងផែនការ និងថវិកា នៅក្នុងកិច្ចប្រជុំទៀងទាត់
- តាមដានត្រួតពិនិត្យ និងវាយតំលៃសកម្មភាពចាំបាច់ផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃមិនត្រូវទទួលបានប្រាក់លើកទឹកចិត្ត ក្នុងការចូលរួមបំពេញការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់អាចពិចារណាផ្តល់ប្រាក់ឧបត្ថម្ភខ្លះៗ សំរាប់ជាការទូទាត់ការចំណាយដែលបានធ្វើឡើង ដូចជាចំណាយលើការធ្វើដំណើរទៅកាន់ទីតាំងគំរោងជាដើម តែទោះជាយ៉ាងណាក៏ដោយ ការឧបត្ថម្ភបែបនេះអាចធ្វើទៅបានតែក្នុងលក្ខណៈសមស្របប៉ុណ្ណោះ គឺអាស្រ័យទៅលើកាលៈទេសៈនៅក្នុងមូលដ្ឋាននីមួយៗ ។

ការជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ម្នាក់ជាជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ ពុំមែនមានន័យថា សមាជិកក្រុមប្រឹក្សាដ៏ទៃទៀតលែងមានតួនាទី ឬថាពួកគេលែងមានការពាក់ព័ន្ធនឹងដំណើរការតាមដានត្រួតពិនិត្យ និងវាយតំលៃនោះទេ ។ តួនាទីរបស់ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺជា **អ្នកសំរបសំរួល** ក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ មិនមែនធ្វើកិច្ចការនេះតែម្នាក់ឯងនោះទេ ។

ដូចបានរៀបរាប់ខាងលើ ការទទួលខុសត្រូវធំបំផុតក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ នៅក្នុងឃុំ សង្កាត់ គឺធ្លាក់ទៅលើក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសសមាជិករបស់ខ្លួនម្នាក់ជាជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃនៅក្នុងឃុំ សង្កាត់ ហើយជនបង្គោលម្នាក់ទៀតត្រូវបានជ្រើសរើសចេញពីគណៈកម្មាធិការកសាងផែនការ និងថវិកា ឱ្យធ្វើជាជនបង្គោលទី២ក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃនៅក្នុងឃុំ សង្កាត់ ។ បើសិនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានជ្រើសរើស ជាជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃនោះជាបុរស គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវជ្រើសរើសសមាជិករបស់ខ្លួនជាស្ត្រី ។ បើសិនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានជ្រើសរើសជាជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃជាស្ត្រី គណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវជ្រើសរើសសមាជិករបស់ខ្លួនជាបុរសវិញ ។

ការតាមដានត្រួតពិនិត្យ និងវាយតំលៃ មិនមែនផ្តោតសំខាន់តែទៅលើការគិតអំពី "ប្រជាពលរដ្ឋ" ជាទូទៅនោះទេ ប៉ុន្តែគួរតែវិភាគអោយបានស៊ីជំរៅទៅលើ បុរស និងស្ត្រីផងដែរ ។ នេះដោយសារតែលទ្ធផលនៃការអភិវឌ្ឍន៍ តែងតែមិនទទួលបានដូចគ្នារវាងបុរស និងស្ត្រី ។ បើសិនជាការតាមដានត្រួតពិនិត្យ និងវាយតំលៃ នៅក្នុងឃុំ សង្កាត់ ត្រូវបានសំរបសំរួលដោយក្រុមដែលមានបុរសនិងស្ត្រី នៅពេលនោះ គឺជាឱកាសដ៏ប្រសើរដែលលទ្ធផលនៃភាពខុសគ្នាដែលអាចកើតមានរវាងបុរស និងស្ត្រី នឹងទទួលបាននូវការយកចិត្តទុកដាក់ថែមទៀត ។

## ៥.៣. គណៈកម្មាធិការ និងគណៈកម្មការនានា

មានគណៈកម្មាធិការ និងគណៈកម្មការ ជាច្រើនដែលត្រូវបានបង្កើតឡើង ដើម្បីជួយនិងផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ចំពោះការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងការរៀបចំគំរោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ គឺយើងមាន គណៈកម្មាធិការកសាងផែនការ និងថវិកា (គ.ផ.ថ) ។ គណៈកម្មាធិការនេះ បានដើរតួយ៉ាងសំខាន់ក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ ពីព្រោះថាជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាឃុំ សង្កាត់នឹងធ្វើការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន ។ ការពិនិត្យឡើងវិញនេះ មានន័យថាត្រូវតែមានការតាមដានត្រួតពិនិត្យ និងវាយតំលៃទៅលើរបៀបនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ។

ខាងក្រោមនេះ គឺជាកិច្ចការមួយចំនួនដែលរំពឹងទុកថា គណៈកម្មាធិការកសាងផែនការ និងថវិកា នឹងជួយបំពេញ ពាក់ព័ន្ធនឹងការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ :

- ជួយជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ ក្នុងការរៀបចំផែនការលំអិតសំរាប់តាមដានត្រួតពិនិត្យ និងវាយតំលៃ
- ជួយក្នុងការអនុវត្តសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃ ជាពិសេសនៅតាមបណ្តាភូមិរបស់ពួកគេ
- ចូលរួមនៅក្នុងការប្រជុំ ដើម្បីធ្វើការវិភាគពត៌មាន ដែលទទួលបានលើការតាមដានត្រួតពិនិត្យ និងវាយតំលៃ និងធ្វើសេចក្តីសន្និដ្ឋាន និងលើកជាអនុសាសន៍ផ្សេងៗ
- ជួយផ្សព្វផ្សាយលទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ នៅតាមបណ្តាភូមិរបស់ពួកគេរៀងៗខ្លួន ។

ឃុំ សង្កាត់ត្រូវបង្កើត គណៈកម្មការគ្រប់គ្រងគំរោង សំរាប់គំរោងទាំងអស់ដែលប្រើប្រាស់មូលនិធិឃុំ សង្កាត់ ។ គណៈកម្មការនេះ យ៉ាងហោចណាស់ត្រូវមានសមាជិក ០១ នាក់ មកពីគ្រប់ភូមិនៅក្នុងឃុំ សង្កាត់ ។

គណៈកម្មការគ្រប់គ្រងគំរោងមានភារកិច្ចតាមដានត្រួតពិនិត្យការងារក្នុងដំណាក់កាល នៃការអនុវត្តគំរោង និងរៀបចំការប្រជុំម្តង ឬច្រើន ដើម្បីទទួលយោបល់ត្រឡប់ពីបណ្តាភូមិ អំពីគុណភាពការងារ នៅពេលដែលអ្នកទទួលការបញ្ចប់ការងារ មុនពេលធ្វើការទូទាត់ចុងក្រោយ ។

## ៥.៤. ប្រជាពលរដ្ឋមូលដ្ឋាន និងក្រុមអ្នកប្រើប្រាស់

យោងតាមប្រកាសស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ចែងថា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែរៀបចំយន្តការសមស្រប ដើម្បីសំរបសំរួលអោយមានការចូលរួមពីអ្នកទទួលផលផ្ទាល់ពីគំរោង ក្នុងការរៀបចំ និងត្រួតពិនិត្យការអនុវត្តគំរោង ដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគំរោងមូលនិធិឃុំ សង្កាត់ក៏បានបញ្ជាក់ដែរថា គណៈកម្មការឬក្រុមអ្នកប្រើប្រាស់គួរត្រូវបានបង្កើតឡើង ដើម្បីថែទាំហេដ្ឋារចនាសម្ព័ន្ធដែលបានសាងសង់ ក្នុងគោលបំណងធានាឱ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់អាចប្រើប្រាស់លទ្ធផលរបស់គំរោង (ដូចជា ផ្លូវ ប្រឡាយ សាលារៀន អណ្តូង...) បានយូរអង្វែង ។

☞ ការចូលរួមរបស់អ្នកទទួលផលគំរោងក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺមានសារៈសំខាន់ណាស់ពីព្រោះ :

- ប្រជាពលរដ្ឋតែងតែចង់ដឹងអំពីអ្វីដែលជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន
- ប្រជាពលរដ្ឋមានឆន្ទៈខ្ពស់ ចំពោះគំរោងរបស់សហគមន៍ខ្លួន ហើយការផ្តល់យោបល់របស់ពួកគេ គឺ មានសារៈសំខាន់ណាស់
- ជាទូទៅ ប្រជាពលរដ្ឋមានបំណងចង់រៀនសូត្រអំពីរបៀបធ្វើអ្វីៗអោយបានល្អប្រសើរ
- ប្រជាពលរដ្ឋហាក់មានអារម្មណ៍ថាខ្លួនគេមានភាពម្ចាស់ការ និងស្រួលក្នុងចិត្ត បើសិនជាពួកគេអាចធ្វើការវាយតំលៃអំពីការងារផ្ទាល់របស់ពួកគេ ជាជាងមានការវិនិច្ឆ័យពីអ្នកខាងក្រៅ ។

☞ នៅពេលមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន ជាការសំខាន់ណាស់ គឺ :

- ត្រូវមានភាពច្បាស់លាស់ថា តើត្រូវធ្វើការតាមដានត្រួតពិនិត្យអំពីអ្វី និងអ្វីខ្លះជាមូលហេតុ ដែលតំរូវអោយមានការតាមដានត្រួតពិនិត្យ
- វិធីសាស្ត្រសំរាប់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវតែធ្វើយ៉ាងណាឱ្យមានលក្ខណៈសាមញ្ញ តាមលទ្ធភាពដែលអាចធ្វើទៅបាន
- ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវធ្វើឡើងអោយបានលឿន និងមានភាពងាយស្រួល
- ត្រូវមានការផ្តល់យោបល់ត្រលប់អោយបានទៀងទាត់ដល់សហគមន៍ អំពីលទ្ធផល
- លទ្ធផលត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអោយបានទូលំទូលាយ តាមមធ្យោបាយផ្សេងៗ ។

## ៥.៥. មន្ត្រីគាំទ្រថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ

មន្ត្រីសំរបសំរួលថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ (PFT និង DFT) និងមន្ត្រីគាំទ្របច្ចេកទេស (TSO ) ក៏ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃខ្លះៗ លើសកម្មភាពរបស់ឃុំ សង្កាត់ផងដែរ ។

មន្ត្រីគាំទ្របច្ចេកទេស ផ្តោតជាសំខាន់លើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ផ្នែកបច្ចេកទេស ( ដូចជាការលើកគំនូសប្លង់ តំលៃប៉ាន់ស្មាន រយៈពេលសាងសង់ និងគុណភាព ) របស់គំរោង ដែលប្រើប្រាស់មូលនិធិឃុំ សង្កាត់ ។ ក្នុងការតាមដានត្រួតពិនិត្យផ្នែកបច្ចេកទេស មន្ត្រីគាំទ្របច្ចេកទេសត្រូវប្រើប្រាស់ទំរង់របាយការណ៍ជាស្តង់ដារនានាដែលបានបង្កើតឡើង ។ ទំរង់របាយការណ៍ទាំងនោះរួមមាន : ទំរង់របាយការណ៍រីកចំរើនរបស់គំរោង និង ទំរង់របាយការណ៍បញ្ចប់គំរោង ។ ទំរង់របាយការណ៍ទាំងនេះ គួរតែធ្វើការកែលំអដោយបន្ថែមចំណុចខាងក្រោមនេះ ។

| យោបល់របស់គណៈកម្មការគ្រប់គ្រងគំរោង (PMC) | |
|---|---|
| ហត្ថលេខារបស់គណៈកម្មការគ្រប់គ្រងគំរោង | កាលបរិច្ឆេទ : |

ការបន្ថែមចំណុចនេះ នឹងអាចជួយធ្វើអោយអ្នកពាក់ព័ន្ធនានាមានឱកាសចូលរួមផ្តល់យោបល់ និងទស្សនៈរបស់ខ្លួន តែអ្នកប្រើទំរង់នេះ ក៏មិនតំរូវអោយប្រើប្រាស់វាដែរ ហើយវាក៏មិនមែនជាលក្ខខណ្ឌដែលត្រូវតែបំពេញដើម្បីធ្វើការទូទាត់ ឬបើកប្រាក់ សំរាប់ការអនុវត្តគំរោងនោះទេ ។

មុនពេលពិនិត្យលើទំរង់ទាំងពីរនេះ ជាការសំខាន់ យើងត្រូវសិក្សាស្វែងយល់អោយបានច្បាស់ពីវា និងផលប្រយោជន៏របស់វាក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ពតិមានបន្ថែមស្តីពីទំរង់ទាំងពីរនេះ គឺមាននៅក្នុងប្រអប់ខាងក្រោមនេះ :

> ការប្រើប្រាស់ទំរង់របាយការណ៍ សំរាប់ការតាមដានត្រួតពិនិត និងវាយតំលៃ
>
> យើងតែងតែប្រើប្រាស់ទំរង់មួយចំនួន សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ទំរង់របាយការណ៏ទាំងនេះ គឺជាឯកសារមួយដែលបង្ហាញពីពតិមានដែលត្រូវប្រមូល និងចន្លោះដែលត្រូវសរសេរពតិមានចូល ។
>
> យើងនឹងអាចធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃកាន់តែបានល្អ បើសិនជាយើងយល់ច្បាស់គ្រប់ទំរង់របាយការណ៏ទាំងអស់ដែលមាន និងសារៈប្រយោជន៏របស់វា ។

យើងមានទំរង់របាយការណ៍ចំនួន ០៣ គឺ :

- ទំរង់ប្រមូលពតិមាន : យើងអាចប្រើទំរង់នេះ ដើម្បីប្រមូលពតិមាន ដោយមិនចាំបាច់ចំណាយពេលវេលាច្រើន ហើយយើងនឹងអាចប្រមូលបានពតិមានគ្រប់ជ្រុងជ្រោយ ។
- ទំរង់បូកសរុបពតិមាន : ទំរង់នេះគឺជាតារាងមួយសំរាប់បូកសរុបពតិមានដែលបានប្រមូល ។
- ទំរង់របាយការណ៍ : យើងប្រើទំរង់នេះ ដើម្បីផ្សព្វផ្សាយពតិមានដល់ អ្នកដទៃ (ដូចជាប្រជាពលរដ្ឋមូលដ្ឋាន និងអាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ) ។

## កិច្ចសន្យាការងារអភិវឌ្ឍន៍របស់ឃុំ សង្កាត់
## របាយការណ៍រីកចំរើន

| | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |

| | |
|---|---|
| ឈ្មោះគំរោង | |
| លេខកិច្ចសន្យា | |
| ឈ្មោះអ្នកទទួលការ | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | |

១. ការពិពណ៌នាអំពីការរីកចំរើននៃការងារ :

| | |
|---|---|
| ២. ភាគរយ (%) នៃការបញ្ចប់ | |
| ៣. តើសំភារៈទាំងនោះមានគុណភាពដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ? | |
| ៤. តើទឹកដៃការងារមានគុណភាព ដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ ? | |
| ៥. តើសំណង់នោះដូចគ្នាទៅនឹងគំនូសប្លង់ដែរឬទេ ? | |

៦. យោបល់ផ្សេងៗ :

| | |
|---|---|
| ហត្ថលេខាអ្នកត្រួតពិនិត្យបច្ចេកទេស : | កាលបរិច្ឆេទ : |

យោបល់របស់គណៈកម្មការគ្រប់គ្រងគំរោង (PMC)

| | |
|---|---|
| ហត្ថលេខារបស់គណៈកម្មការគ្រប់គ្រងគំរោង | កាលបរិច្ឆេទ : |

## កិច្ចសន្យាការងារអភិវឌ្ឍន៍របស់ឃុំ សង្កាត់

## របាយការណ៍បញ្ចប់កិច្ចសន្យា (ក្រោយពេលគំរោងបានប្រើប្រាស់មួយរយៈពេលកន្លងមក)

| | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |
| ឈ្មោះគំរោង | | |
| លេខកិច្ចសន្យា | | |
| ឈ្មោះអ្នកទទួលការ | | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | | |
| កាលបរិច្ឆេទបញ្ចប់ការងារ : | កាលបរិច្ឆេទចុះត្រួតពិនិត្យ : | |

១. ពិពណ៌នាលក្ខខណ្ឌបច្ចុប្បន្ននៃការងារ :

ជ្រើសរើសការពិពណ៌នារួមមួយ :

| | | |
|---|---|---|
| ល័ក្ខខ័ណ្ឌល្អ ☐ | អាចទទួលយកបាន ☐ | អន់ ☐ |

២. តើអ្នកទទួលការបានអនុវត្តការងាររបស់ខ្លួនក្នុងអំឡុងពេលធានាដែរឬទេ ?

៣. តើមានការងារអ្វីថែមទៀតដែលអ្នកទទួលការត្រូវធ្វើ មុនពេលគាត់អាចទទួលបាននូវការទូទាត់ចុងក្រោយ?

៤. តើមានការខូចខាតអ្វីខ្លះចំពោះការងារដោយហេតុផលផ្សេងៗ ដែលអ្នកទទួលការមិនទទួលខុសត្រូវ?

៥. វាយតំលៃអ្នកទទួលការលើជំនាញបច្ចេកទេស ភាពស្មោះត្រង់ និងកិច្ចសហការល្អ ជាមួយម្ចាស់គំរោង និងប្រជាពលរដ្ឋនៅមូលដ្ឋាន

| | | | |
|---|---|---|---|
| ជំនាញបច្ចេកទេស | ល្អ ☐ | មធ្យម ☐ | ខ្សោយ ☐ |
| ភាពស្មោះត្រង់ | ល្អ ☐ | មធ្យម ☐ | ខ្សោយ ☐ |
| កិច្ចសហការល្អជាមួយម្ចាស់គំរោង និងប្រជាពលរដ្ឋមូលដ្ឋាន | ល្អ ☐ | មធ្យម ☐ | ខ្សោយ ☐ |

| | |
|---|---|
| ហត្ថលេខាអ្នកត្រួតពិនិត្យបច្ចេកទេស : | កាលបរិច្ឆេទ : |

យោបល់របស់គណៈកម្មការគ្រប់គ្រងគំរោង (PMC)

| | |
|---|---|
| ហត្ថលេខារបស់គណៈកម្មការគ្រប់គ្រងគំរោង | កាលបរិច្ឆេទ : |

## ៦. នីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ

យើងអាចធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ក្នុងរូបភាពផ្សេងៗគ្នាជាច្រើន ហើយវិធីសាស្ត្រ និងបច្ចេកទេសដែលប្រើប្រាស់សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺអាស្រ័យទៅលើ :

- អ្វីដែលយើងចង់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ
- ធនធានដែលមានសំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ (លុយ មនុស្ស មធ្យោបាយធ្វើដំណើរ...)
- បទពិសោធន៍ផ្ទាល់ខ្លួនរបស់យើង លើការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ

ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ជាទូទៅត្រូវបានរៀបចំឡើង តាមលំដាប់លំដោយចំនួន៤ជំហានដូចខាងក្រោម :

១. ការត្រៀមរៀបចំ

២. ការប្រមូលពតិមាន

៣. ការវិភាគពតិមាន

៤. ការប្រើប្រាស់សេចក្តីសន្និដ្ឋាន

*<u>ឧទាហរណ៍</u>*

១- ការត្រៀមរៀបចំ : ក្រុមប្រឹក្សាបានសំរេចចិត្តធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ទៅលើការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការងារគ្រប់គ្រង និងអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។ សូចនាករមួយដែលអាចបញ្ជាក់ពីគោលបំណងនេះគឺថា តើប្រជាពលរដ្ឋមូលដ្ឋានបានចូលរួមប្រជុំនៅថ្នាក់ភូមិ ឬថ្នាក់ឃុំ ដែរឬទេ ។ បន្ទាប់ពីការពិភាក្សា ក្រុមប្រឹក្សាឃុំ សង្កាត់បានសំរេចចិត្តប្រមូលពតិមានស្តីពី :

- ចំនួនបុរស និងស្ត្រីដែលបានចូលរួមក្នុងការប្រជុំ
- ចំនួនពួកគេដែលមានអាយុក្រោម ៣០ឆ្នាំ
- ភូមិដែលពួកគេរស់នៅ និង
- ចំនួនប្រជាពលរដ្ឋក្រីក្រដែលបានចូលរួមក្នុងការប្រជុំ ។

២- ការប្រមូលពត៌មាន : ក្រុមប្រឹក្សាឃុំ សង្កាត់បានសំរេចចិត្តសូមអោយគ្រូបង្រៀនបឋមសិក្សា ជួយប្រមូលពត៌មានទាំងនេះ ។ គ្រូបង្រៀនរូបនោះបានរៀបចំជាទំរង់មួយ សំរាប់កត់ត្រាពីចំនួនស្ត្រី និងបុរសដែលបានចូលរួមប្រជុំ អាយុ ភូមិដែលពួកគេរស់នៅ និងស្ថានភាពជីវភាពរស់នៅ(មាន-ក្រ) របស់ពួកគេ ។ គ្រូបង្រៀនរូបនោះនឹងប្រមូលពត៌មាន ពីការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន នៅក្នុងការប្រជុំទៀងទាត់ របស់ក្រុមប្រឹក្សាឃុំ សង្កាត់រយៈពេល៦ខែ ។

៣- ការវិភាគពត៌មាន : ពិនិត្យលើពត៌មានដែលបានប្រមូល ក្រុមប្រឹក្សាឃុំ សង្កាត់យល់ឃើញថា មានបុរសមួយក្រុមតូចដែលមានអាយុច្រើនជាង៣០ឆ្នាំ និងដែលមានការយល់ដឹងច្រើន តែងតែបានចូលរួមប្រជុំ ។ ពួកគេទាំងអស់សុទ្ធតែអញ្ជើញមកពីភូមិដែលនៅក្បែរនឹងសាលាឃុំ សង្កាត់ ។ តាមឯកសារស្តីពីប្រជាពលរដ្ឋ បានបង្ហាញថា ក្នុងចំណោមភូមិទាំង០៧នៃឃុំនេះ គឺមានចំនួនស្ត្រីច្រើនជាងបុរសហើយឃុំនេះក្រជាងគេ ។ ពត៌មានដែលប្រមូលបានមកនេះ បង្ហាញថាមានមនុស្សតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានចូលរួមក្នុងការងារគ្រប់គ្រង និងអភិវឌ្ឍន៍របស់ឃុំ សង្កាត់ ហើយអ្នកទាំងនេះមិនមែនជាមនុស្សដែលក្រីក្រនោះទេ ។

៤- សេចក្តីសន្និដ្ឋាន : ក្រុមប្រឹក្សាឃុំ សង្កាត់អាចពិចារណាថា តើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីលើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋជាស្ត្រី ក្មេងៗ និងអ្នកក្រីក្រឱ្យចូលរួមប្រជុំ ដើម្បីធានាថាសេចក្តីសំរេចដែលបានធ្វើឡើងនៅក្នុងការប្រជុំនេះ បានបំរើផលប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន ។ វាហាក់បីដូចជាការលំបាក ក្នុងការកៀងគរប្រជាពលរដ្ឋមូលដ្ឋានអោយចូលរួមប្រជុំនេះ ឃុំ សង្កាត់គួរតែធ្វើយ៉ាងណាដើម្បីផ្សព្វផ្សាយពត៌មាន អោយបានទូលំទូលាយដល់ប្រជាពលរដ្ឋមូលដ្ឋាន ។

## ៦.១. ការត្រៀមរៀបចំ

ជំហានដំបូងនេះ ជាជំហានសំខាន់ ព្រោះថាវាមានឥទ្ធិពលយ៉ាងខ្លាំង លើលទ្ធផលរបស់ការតាមដានត្រួតពិនិត្យ និងវាយតំលៃដែលយើងត្រូវធ្វើ ។ បើសិនជាយើងមិនច្បាស់ពីអ្វីដែលត្រូវតាមដានត្រួតពិនិត្យ និងវាយតំលៃអោយបានជាក់លាក់ ឬមិនមានគំនិតល្អៗ អំពីវិធីសាស្ត្រក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃទេ យើងនឹងខ្ជះខ្ជាយពេលវេលាយ៉ាងច្រើន ដោយគ្មានលទ្ធផលគួរជាទីគាប់ចិត្តនៅចុងបញ្ចប់ ។

ការត្រៀមរៀបចំការតាមដានត្រួតពិនិត្យ និងការវាយតំលៃ គឺជាឱកាសដ៏ល្អមួយផងដែរ ដើម្បីធ្វើអោយមានការពិគ្រោះយោបល់ ។ ជនបង្គោលតាមដានត្រួតពិនត្យ និងវាយតំលៃឃុំ សង្កាត់ នឹងរៀបចំផែនការតាមដានត្រួតពិនិត្យ និងវាយតំលៃ ហើយបន្ទាប់មកដាក់ជូនមេឃុំ ចៅសង្កាត់ សំរាប់ពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធនានារបស់ឃុំ សង្កាត់ និងអនុម័ត ។

☞ ដើម្បីធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃមួយ ជាពិសេសសំរាប់ការវាយតំលៃ គេត្រូវមានការរៀបចំផែនការយ៉ាងហ្មត់ចត់ជាមុន ដោយត្រូវអនុវត្តទៅតាម ០៥ជំហាន ដូចខាងក្រោម ÷

១. ការកំណត់គោលបំណង

២. ការកំណត់សូចនាករ

៣. ការកំណត់សំណួរគន្លឹះ

៤. ការកំណត់វិធីសាស្ត្រ

៥. ការរៀបចំផែនការសកម្មភាព

## ៦.១.១. ការកំណត់គោលបំណងសំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ

☞ តើត្រូវតាមដានត្រួតពិនិត្យ និងវាយតំលៃលើអ្វីខ្លះ ?

ដូចដែលបានលើកឡើងនៅក្នុងផ្នែកទី៣ខាងដើម ការតាមដានត្រួតពិនិត្យ និងវាយតំលៃដែលឃុំ សង្កាត់ធ្វើឡើងត្រូវផ្តោតទៅលើការអនុវត្តផែនការអភិវឌ្ឍន៍ និងថវិកាប្រចាំឆ្នាំ ដើម្បីទទួលបានពត៌មានស្តីពីស្ថានភាពអភិវឌ្ឍន៍ទូទៅនៅក្នុងឃុំ សង្កាត់ ។

អ្វីដែលត្រូវធ្វើឱ្យបានសំរេចនៅក្នុងផ្នែកនេះ គឺពិភាក្សា និងព្រមព្រៀងគ្នា លើអ្វីខ្លះដែលជាចំណុចសំខាន់ជាក់លាក់នៃគំរោងឃុំ សង្កាត់ ឬការផ្តល់សេវាកម្ម ដែលនឹងត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ដើម្បីទទួលបាននូវពត៌មានដែលយើងចង់បាន ។ មូលដ្ឋានក្នុងការសំរេចថា អ្វីខ្លះដែលត្រូវតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺពិនិត្យមើលទៅលើគោលបំណង និងរបៀបរបបនៃការអនុវត្តគំរោង និងការផ្តល់សេវាកម្ម ។

ចំពោះគំរោងហេដ្ឋារចនាសម្ព័ន្ធ យើងអាចប្រមូលបានពត៌មានតាមដានត្រួតពិនិត្យ និងវាយតំលៃមួយចំនួនចេញពី "ទំរង់ពត៌មានគំរោង" និងទំរង់ពត៌មានបច្ចេកទេស (ដូចជា គំរោងអណ្តូងទឹក ផ្លូវ សាលារៀន និងគំរោងធារាសាស្ត្រ) ។ យើងអាចរកទំរង់ទាំងនេះបាន នៅក្នុងសៀវភៅណែនាំស្តីពី ការអនុវត្តគំរោងដែលប្រើប្រាស់មូលនិធិឃុំ សង្កាត់ (សៀវភៅភីម) ។

ផែនការការងាររបស់អ្នកទទួលការ គឺជាប្រភពពត៌មានដ៏សំខាន់មួយទៀត ស្តីពីការតាមដានត្រួតពិនិត្យលើធនធាន សកម្មភាព លទ្ធផលរបស់គំរោងមួយដែលអនុវត្តដោយអ្នកទទួលការ ។ ផែនការសកម្មភាពនេះ នឹងបង្ហាញពីសកម្មភាពដែលត្រូវអនុវត្ត ពេលចាប់ផ្តើម និងបញ្ចប់សកម្មភាពនីមួយៗ ។

ចំពោះគំរោងដែលមិនមែនជាហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពផ្តល់សេវាកម្ម (ដូចជាការផ្តល់ធនធានសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សកម្មភាពបណ្តុះបណ្តាល ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ឬកម្មវិធីវិនិយោគឃុំ សង្កាត់) អាចផ្តល់ពត៌មានជាមូលដ្ឋាន ថាតើគំរោងធ្វើទៅលើអ្វី ហេតុអ្វី នៅកន្លែងណា នៅពេលណា និងថាតើគំរោងត្រូវអនុវត្តយ៉ាងដូចម្តេច ដោយមានចំណាយប៉ុន្មាន ហើយមានស្ត្រី និងបុរសប៉ុន្មាននាក់ដែលជាអ្នកទទួលផល។

បើសិនពត៌មានខាងលើនេះមិនមាននៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និង ផែនការថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ទេនោះ ចាំបាច់ត្រូវតែគូសបញ្ជាក់អោយបានច្បាស់ថា តើត្រូវរៀបចំធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃនៅពេលណា កន្លែងណា... ។ល។

## គំរោងហេដ្ឋារចនាសម្ព័ន្ធរបស់ឃុំ សង្កាត់
## ទំរង់ព័ត៌មានគំរោង

| | |
|---|---|
| ខេត្ត ក្រុង : | ឃុំ សង្កាត់ : |
| ស្រុក ខណ្ឌ : | លេខកូដរបស់ឃុំ សង្កាត់ : |

### ផ្នែកទី១ : ព័ត៌មានទូទៅ

| | | |
|---|---|---|
| ឈ្មោះគំរោង : | | |
| ថ្ងៃបញ្ចប់ការសិក្សា | ឈ្មោះអ្នកជំនួយបច្ចេកទេស : | ឋានៈអ្នកជំនួយបច្ចេកទេស |
| **ទិសដៅរបស់គំរោង :** | | |
| វិស័យ : | ប្រភេទគំរោង : | |
| ការងារសាងសង់ | ការងារសេវាកម្ម | ការរៀបចំសហគមន៍ ☐ |
| លទ្ធផលគ្រោង (ចេញពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់) | លទ្ធផលគ្រោងក្រោយពីសិក្សា | |
| តំលៃប៉ាន់ស្មានក្នុងផែនការ : | តំលៃប៉ាន់ស្មានក្រោយពីសិក្សា : | |
| គំរោងថវិកានៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ | | |

| | | | | |
|---|---|---|---|---|
| ឆ្នាំ | | | | |
| ចំនួនប្រាក់ | | | | |

### អ្នកទទួលផលពីគំរោង

| លរ | ឈ្មោះភូមិ | ចំនួនអ្នកប្រើប្រាស់ | | ចំនួនគ្រួសារ |
|---|---|---|---|---|
| | | សរុប | ស្រ្តី | |
| | | | | |
| | | | | |
| សរុប | | | | |

## ផែនការការងាររបស់អ្នកទទួលការ

| | | | |
|---|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : | ឈ្មោះគំរោង : |
| ឈ្មោះអ្នកទទួលការ : | លេខទូរស័ព្ទ : | ឈ្មោះមេការ : | លេខទូរស័ព្ទ : |
| កាលបរិច្ឆេទចាប់ផ្ដើមកិច្ចសន្យា : | | កាលបរិច្ឆេទបញ្ចប់កិច្ចសន្យា : | |

| ការពិពណ៌នាអំពីការងារ | % ការងារគិតតាមសាច់ប្រាក់ | កាលបរិច្ឆេទចាប់ផ្ដើម | កាលបរិច្ឆេទបញ្ចប់ | ដំណាក់កាលសំខាន់ៗសំរាប់តាមដានបច្ចេកទេស | ឈ្មោះអ្នកទទួលការបន្ត | ការគ្រប់គ្រងបរិស្ថាន | |
|---|---|---|---|---|---|---|---|
| | | | | | | បញ្ហា | ដំណោះស្រាយ |
| | | | | | | | |

| | |
|---|---|
| ដាក់ជូនដោយអ្នកទទួលការ :<br>កាលបរិច្ឆេទ : | អនុម័តដោយមេឃុំ ចៅសង្កាត់ :<br>កាលបរិច្ឆេទ : |

ឧទាហរណ៍ បញ្ជាក់ពីផែនការការងាររបស់អ្នកទទួលការ

<table>
<tr><td colspan="2">ខេត្ត ក្រុង : ស្វាយរៀង</td><td colspan="2">ស្រុក ខណ្ឌ : រមាសហែក</td><td colspan="2">ឃុំ សង្កាត់ : ដូង</td><td colspan="3">ឈ្មោះគំរោង : គំរោងផ្លូវឃុំដូង</td></tr>
<tr><td colspan="2">ឈ្មោះអ្នកទទួលការ : នាគធាត់</td><td colspan="3">លេខទូរស័ព្ទ : ០១២ ៣៤៥ ៧៨៧</td><td colspan="2">ឈ្មោះមេការ : ជាងចាស់</td><td colspan="2">លេខទូរស័ព្ទ : ០១២ ៨៧៦ ៥៤៣</td></tr>
<tr><td colspan="5">កាលបរិច្ឆេទចាប់ផ្ដើមកិច្ចសន្យា : ២៥/០៣/០៣</td><td colspan="4">កាលបរិច្ឆេទបញ្ចប់កិច្ចសន្យា : ២៤/០៦/០៣</td></tr>
<tr><td rowspan="2">ការពិពណ៌នាអំពីការងារ</td><td rowspan="2">%ការងារគិតតាមសាច់ប្រាក់</td><td rowspan="2">កាលបរិច្ឆេទចាប់ផ្ដើម</td><td rowspan="2">កាលបរិច្ឆេទបញ្ចប់</td><td rowspan="2">ដំណាក់កាលសំខាន់ៗសំរាប់តាមដានបច្ចេកទេស</td><td rowspan="2">ឈ្មោះអ្នកទទួលការបន្ត</td><td colspan="2">ការគ្រប់គ្រងបរិស្ថាន</td></tr>
<tr><td>បញ្ហា</td><td>ដំណោះស្រាយ</td></tr>
<tr><td>លូមួយខ្សែមុខកាត់១ម៉ បណ្ដោយ៤០០ម៉</td><td>៦%</td><td>០១/០៤/០៣</td><td>១៥/០៤/០៣</td><td rowspan="5">១. បញ្ចប់ការជីករណ្ដៅចាក់គ្រឹះ<br><br>២. មុនពេលចាប់ផ្ដើមបំពេញដី ក្រោយពីសាងសង់</td><td rowspan="2">ជាតូច</td><td rowspan="5">ទឹកក្រខ្វក់ពីកាសាងសង់ ហូរចាក់ទៅប្រព័ន្ធធារាសាស្ត្រ ។<br><br>កាកសំណល់ផ្សេងៗរបស់អ្នកសាងសង់ ។</td><td rowspan="5">អ្នកទទួលការនឹងធ្វើប្រព័ន្ធរំដោះ ទឹកបណ្ដោះអាស័ន្ន<br><br>អ្នកទទួលការនឹងសំអាតទីធ្លាជុំវិញ យ៉ាងប្រុងប្រយ័ត្ន</td></tr>
<tr><td></td><td>៨%</td><td>០៦/០៤/០៣</td><td>២០/០៤/០៣</td></tr>
<tr><td></td><td>៦%</td><td>១១/០៤/០៣</td><td>២៥/០៤/០៣</td><td rowspan="3">អ្នកភូមិ</td></tr>
<tr><td></td><td>៤%</td><td>១៦/០៤/០៣</td><td>២៥/០៤/០៣</td></tr>
<tr><td></td><td>៤%</td><td>២០/០៤/០៣</td><td>៣០/០៤/០៣</td></tr>
<tr><td></td><td>២២%</td><td>០១/០៥/០៣</td><td>១៥/០៥/០៣</td><td rowspan="3">១. បង្ហាប់ដី មុនពេលចាក់គ្រោះក្រហម<br>២. បញ្ចប់ចាក់គ្រោះក្រហម</td><td rowspan="3"></td><td rowspan="3">ហៀរប្រេងឥន្ទនៈពីម៉ាស៊ីន<br><br>ក្រខ្វក់ដល់អ្នកធ្វើដំណើរតាមផ្លូវ</td><td rowspan="3">ប្រេងឥន្ទនៈដែលកំពុបនឹងត្រូវបានសំអាតយ៉ាងប្រុងប្រយ័ត្ន<br>អ្នកទទួលការនឹងបញ្ឈប់ការងារ នៅពេលផ្លូវរវល់ខ្លាំង ។</td></tr>
<tr><td></td><td>៥០%</td><td></td><td>១៥/០៥/០៣</td></tr>
<tr><td></td><td>៥០%</td><td>១៦/០៥/០៣</td><td>៣០/០៥/០៣</td></tr>
<tr><td colspan="4">ដាក់ជូនដោយអ្នកទទួលការ : នាគធាត់<br>កាលបរិច្ឆេទ : ១៥/០៣/០៣</td><td colspan="4">អនុម័តដោយមេឃុំ ចៅសង្កាត់ : ពូ ឃុំ<br>កាលបរិច្ឆេទ : ១៨/០៣/០៣</td></tr>
</table>

☞ ហិរញ្ញវត្ថុ និងពេលវេលាសមស្រប សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ

នៅពេលដែលយើងពិចារណាពីការតាមដានត្រួតពិនិត្យ និងវាយតំលៃ យើងគួរតែគិតផងដែរពីការចំណាយលើការងារនេះ ។ ការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺទាមទារឱ្យមានពេលវេលា និងប្រាក់កាសសមស្រប ។ អ្នកដែលធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃត្រូវចំណាយពេលវេលារបស់ខ្លួនដើម្បីបំពេញការងារនេះ ហើយបើសិនជាគេជួបជាមួយអ្នកដទៃនៅពេលធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ អ្នកទាំងអស់នោះក៏ចំណាយពេលដូចគ្នា ។ ក្នុងការអនុវត្តសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃ គួរមានការចំណាយផ្សេងៗ ដូចជាថ្លៃធ្វើដំណើរ ប៊ិច ក្រដាស ថតរូប និងអាហារសំរ៉ន់ (បើសិនជាចាំបាច់) ។

ការចំណាយនេះត្រូវរៀបចំនៅក្នុងខ្ទង់ថវិកាលេខកូដ **៦១** " ចំណាយរដ្ឋបាលទូទៅ " នៃគំរោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។ ប៉ុន្តែការរៀបចំថវិកាសំរាប់ការងារតាមដានត្រួតពិនិត្យ និងវាយតំលៃនេះ ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានជាក់លាក់ ។ នៅពេលក្រុមប្រឹក្សាឃុំ សង្កាត់រៀបចំថវិកាប្រចាំឆ្នាំ ឃុំ សង្កាត់ត្រូវគិតពីការបែងចែកធនធានអោយបានសមស្រប សំរាប់រ៉ាប់រងការចំណាយលើសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ចំនួនថវិកាសំរាប់ការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវតែច្បាស់លាស់ និងមានកំណត់សំរាប់តែសកម្មភាពណាដែលចាំបាច់តែប៉ុណ្ណោះ ។

## ៦.១.២. ការជ្រើសរើសសូចនាករ

នៅពេលដែលយើងយល់ច្បាស់ពីអ្វីដែលត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតំលៃហើយនោះ ដំណាក់កាលបន្ទាប់មកទៀត យើងត្រូវកំណត់ថាតើពត៌មានអ្វីខ្លះដែលយើងត្រូវការ ។ ពត៌មានទាំងនោះហៅថា <u>សូចនាករ</u>

☞ សូចនាករ គឺជាពត៌មានសំខាន់ៗ ដែលជួយអោយយើង :

- វាស់វែងសមិទ្ធផល
- ឆ្លុះបញ្ចាំងបំរែបំរួល.
- វាស់ស្ទង់គុណភាពការងារដែលបានអនុវត្ត

លើសពីនេះទៅទៀត សូចនាករ គឺជាពត៌មានដែលអាចអោយយើងសន្និដ្ឋានបានពីអ្វីមួយ ។ ឧទាហរណ៍ យើងឃើញមេឃមានពពកអាប់អួរច្រើន ក្តៅស្អុះ និងមានសត្វស្រមោចជាច្រើនចេញពីរន្ធ នោះយើងអាចសន្និដ្ឋានបានថា ថ្ងៃនេះមេឃនឹងភ្លៀង ។ សូចនាករ (ក្តៅស្អុះ ពពកអាប់អួរ មានស្រមោចច្រើនចេញពីរន្ធ) បានធ្វើអោយយើងអាចសន្និដ្ឋានថា មេឃប្រហែលជានឹងភ្លៀង ។ យើងអាចកំណត់ចំនួនសូចនាករច្រើន ឬ តិច គឺអាស្រ័យទៅតាមខ្លឹមសារនៃគោលបំណងរបស់ការតាមដានត្រួតពិនិត្យ និងវាយតំលៃដែលយើងបានកំណត់ ។ បើសិនជា

គោលបំណងនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃទូលំទូលាយ នោះសូចនាករក៏ត្រូវមានច្រើនដែរ តែបើសិនជាគោលបំណងតូច នោះសូចនាករក៏ត្រូវតិចតូចទៅតាមនោះដែរ ។

☞ ជាទូទៅសូចនាករមាន២ប្រភេទគឺ ÷

<u>សូចនាករបរិមាណ</u> : ជាសូចនាករដែលយើងអាចរាប់បាន ដូចជា ចំនួនទ្បានដឹកគ្រួសក្រហមដើម្បីជួសជុលផ្លូវ ឬ ចំនួនប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកអណ្តូង... ។ល។

<u>សូចនាករគុណភាព</u> : ជាសូចនាករដែលយើងមិនអាចរាប់បាន ដូចជា ការពេញចិត្តរបស់អ្នកប្រើប្រាស់ផ្លូវដែលទើបជួសជុលរួច ឬ គុណភាពទឹកដែលយកពីអណ្តូង... ។ល។

សូចនាករសំរាប់តាមដានត្រួតពិនិត្យធនធាន លទ្ធផល និងផលប៉ះពាល់ អាចជាសូចនាករបរិមាណ ឬ ជាសូចនាករគុណភាព ។ សូចនាករមួយដែលល្អ អាស្រ័យទៅលើប្រភេទនៃសកម្មភាពដែលបាននឹងកំពុងអនុវត្ត ។ តារាងខាងក្រោមនេះ នឹងបង្ហាញអោយឃើញពីសូចនាករធនធាន លទ្ធផល និងសូចនាករផលប៉ះពាល់របស់គំរោងមួយចំនួន ដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

| គំរោង | សូចនាករធនធាន | សូចនាករលទ្ធផល | សូចនាករផលប៉ះពាល់ |
|---|---|---|---|
| គំរោងជួសជុលផ្លូវ | - ចំនួនទ្បានដឹកគ្រួសក្រហម | - ប្រវែងផ្លូវដែលបានជួសជុល<br>- ប្រវែងផ្លូវដែលត្រូវជួសជុលក្រោយពីរដូវភ្លៀង (សូចនាករគុណភាព) | - ចំណាយលើការធ្វើដំណើរដោយរថយន្តឈ្នួល<br>- តំលៃកសិផល |
| គំរោងសាងសង់អណ្តូង | - ពេលវេលាសំរាប់ដឹកអណ្តូង | - ជំរៅអណ្តូង<br>- បរិមាណទឹកដែលអាចយកប្រចាំថ្ងៃ | - ពេលវេលាដែលស្ត្រីត្រូវយកទឹកប្រចាំថ្ងៃ<br>-ការផ្លាស់ប្តូរឥរិយាបថប្រើប្រាស់ទឹក |
| គ្រឿងសង្ហារឹមសំរាប់សាលារៀន | - បរិមាណទុនចូលរួមរបស់មូលដ្ឋាន | - ចំនួន និង គុណភាពសង្ហារឹមដែលបានទិញ | - អត្រាចូលរៀនរបស់កុមារ<br>- ចំនួនកុមារដែលបន្តការសិក្សាក្រោយបឋមសិក្សា |
| វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ | - ចំនួន និងរយៈពេលនៃវគ្គបណ្តុះបណ្តាល | - ចំនួនអ្នកចូលរួមដែលបានបញ្ចប់ការសិក្សា ហើយទទួលបានសញ្ញាប័ត្រ | -ចំនួនអ្នកចូលរួមដែលបានបង្កើតអាជីវកម្មខ្លួនឯង ដោយប្រើប្រាស់ជំនាញដែលបានរៀន |
| ថ្នាក់អក្ខរកម្ម | - ចំនួនថ្នាក់អក្ខរកម្ម | - ចំនួនបុរសស្ត្រីដែលអាចអានក្តាខៀនពត៌មានរបស់ឃុំនៅចុងឆ្នាំ | - ចំនួនបុរស ស្ត្រីដែលអាចអាន និងយល់លិខិតប័ណ្ណផ្សព្វផ្សាយកសិកម្ម និងសុខភាពបាន |

## ៦.១.៣. ការកំណត់សំណួរគន្លឹះ

នៅពេលដែលយើងបានជ្រើសរើសសូចនាកររួចហើយ យើងត្រូវកំណត់សំណួរគន្លឹះ ដែលត្រូវប្រើក្នុងការប្រមូលពត៌មាន សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ សំណួរគន្លឹះទាំងនោះ ភាគច្រើនចាប់ផ្តើមឡើងដូចខាងក្រោមនេះ :

- តើគំរោងសំរេចបានលទ្ធផលអ្វីខ្លះ ? តើលទ្ធផលទាំងនោះ ស្របទៅនឹងការសង្ឃឹមទុកដែរឬទេ?
- ហេតុអ្វីបានជាសកម្មភាព ឬគំរោងនោះ មានសារៈសំខាន់ចំពោះឃុំ សង្កាត់ ?
- តើកន្លែងណា (ភូមិអ្វី) ដែលសកម្មភាព ឬ គំរោងបានត្រូវអនុវត្ត ហើយហេតុអ្វីបានជាអនុវត្តនៅភូមិនោះ ហើយភូមិឯទៀតមិនមាន ?
- តើនៅពេលណាដែលសកម្មភាព ឬ គំរោងត្រូវបានអនុវត្ត ?
- តើសកម្មភាព ឬគំរោងត្រូវបានអនុវត្តយ៉ាងដូចម្តេច ? តើនីតិវិធីអនុវត្តគំរោងនេះ ទទួលបានលទ្ធផលល្អដែរឬទេ ?
- តើសកម្មភាព ឬគំរោងនោះ នឹងចំណាយអស់ប៉ុន្មាន ? តើការចំណាយនោះ សមស្របនឹងការគ្រោងទុកដែរឬទេ? តើមានទុនចូលរួមផ្សេងទៀតដែរឬទេ ?
- តើគោលបំណងរបស់គំរោង សំរេចបានកំរិតណា ?
- តើមានស្ត្រីប៉ុន្មាននាក់ និង បុរសប៉ុន្មាននាក់ដែលទទួលផលប្រយោជន៍ពីគំរោងនេះ ? តើក្នុងចំណោមពួកគេ មានប៉ុន្មាននាក់ដែលងាយរងគ្រោះបំផុត ?
- តើអ្នកណាជាអ្នកទទួលផល ? តើអ្នកដែលទទួលផលប្រយោជន៍ពីគំរោង គឺជាអ្នកដែលយើងសង្ឃឹមថានឹងទទួលឬ ? តើជាប្រយោជន៍អ្វីខ្លះ ? តើគំរោងនេះ ជាគំរោង ឬសកម្មភាពសំរាប់សាធារណៈ (ដែលផលប្រយោជន៍វា អាចផ្តល់បានដល់ក្រុមដែលមានមនុស្សច្រើន ឬក៏មនុស្សទាំងអស់ដែលរស់នៅក្នុងឃុំ សង្កាត់) ឬជាគំរោងដែលធ្វើឡើងដោយគ្រាន់តែផ្តល់សេវាអោយតែមនុស្ស២ឬ៣នាក់ ? ឧទាហរណ៍ អណ្តូងស្នប់នៅក្នុងទីធ្លាផ្ទះ របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយ គឺមិនមែនជា គំរោងសេវាសាធារណៈទេ បើសិនជាមានតែក្រុមគ្រួសារសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ ប្រើប្រាស់ ហើយអ្នកនៅក្បែរមិនមានសិទ្ធិប្រើប្រាស់នោះ ។

☞ ឧទាហរណ៍នៅទំព័របន្ទាប់ នឹងបង្ហាញពីសំណួរទាំងនេះ សំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធ ។

ឧទាហរណ៍ :

| គំរោងហេដ្ឋារចនាសម្ព័ន្ធរបស់ឃុំ សង្កាត់<br>ទំរង់ពត៌មានគំរោង | |
|---|---|
| ខេត្ត ក្រុង : ស្វាយរៀង | ឃុំ សង្កាត់ : ម្រាម |
| ស្រុក ខណ្ឌ : រមាសហែក | លេខកូដរបស់ឃុំ សង្កាត់ : ១២៣៤៥៦៧ |

**ផ្នែកទី១ : ពត៌មានទូទៅ**

| ឈ្មោះគំរោង : គំរោងផ្លូវទៅឃុំម្រាម | | |
|---|---|---|
| ថ្ងៃបញ្ចប់ការសិក្សា:<br>០១/៦/០៣ | ឈ្មោះអ្នកជំនួយបច្ចេកទេស :<br>មឿក សិលា | ឋានៈអ្នកជំនួយបច្ចេកទេស :<br>មន្ត្រីគាំទ្របច្ចេកទេស |
| ទិសដៅរបស់គំរោង : គ្រប់ភូមិទាំងអស់នឹងអាចធ្វើដំណើរបានយ៉ាងល្អនៅត្រឹមឆ្នាំ ២០០៥ | | |
| វិស័យ : សេដ្ឋកិច្ច | ប្រភេទគំរោង : គមនាគមន៍ជនបទ | |
| ការងារសាងសង់ ☑ | ការងារសេវាកម្ម ☐ | ការរៀបចំសហគមន៍ ☐ |
| លទ្ធផលគ្រោង (ចេញពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់)<br>ផ្លូវ៣គ.ម និងលូកាត់ផ្លូវចំនួន៤កន្លែង | លទ្ធផលគ្រោងក្រោយពីសិក្សា<br>ផ្លូវ៣គ.ម និងលូកាត់ផ្លូវចំនួន៥កន្លែង | |
| តំលៃប៉ាន់ស្មានក្នុងផែនការ :<br>៤០ ០០០ ០០០ រៀល | តំលៃប៉ាន់ស្មានក្រោយពីសិក្សា :<br>៥១ ០០០ ០០០ រៀល | |

| គំរោងថវិកានៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ | | | | |
|---|---|---|---|---|
| ឆ្នាំ | ២០០៣ | ២០០៤ | | |
| ចំនួនប្រាក់ | ២០ ០០០ ០០០ | ២០ ០០០ ០០០ | | |

**អ្នកទទួលផលពីគំរោង**

| លរ | ឈ្មោះភូមិ | ចំនួនអ្នកប្រើប្រាស់ | | ចំនួនគ្រួសារ |
|---|---|---|---|---|
| | | សរុប | ស្ត្រី | |
| ១ | ភូមិជើង | ៨០០ | ៤០០ | ១៤០ |
| ២ | ភូមិត្បូង | ៦០០ | ៣០០ | ១១០ |
| ៣ | ភូមិកណ្តាល | ៩០០ | ៤៥០ | ១៦៥ |
| ៤ | ភូមិខ្ពស់ | ៤០០ | ២០១ | ៧៥ |
| សរុប | | ២៧០០ | ១៣៥១ | ៤៩០ |

| | |
|---|---|
| អ្វីខ្លះ? | ការសាងសង់ផ្លូវគ្រួសក្រហមមួយខ្សែមាន ០៣ គីឡូម៉ែត្រ មានលូកាត់ផ្លូវចំនួន ០៥ ក្នុងរយៈពេល ០២ឆ្នាំ ។ ដូចនេះនៅក្នុងភូមិទាំងអស់ក្នុង*ឃុំព្រាម* អាចធ្វើដំណើរបានពេញមួយឆ្នាំៗ ។ អ្វីដែលត្រូវធ្វើការត្រួតពិនិត្យគឺថា តើការសាងសង់នេះពិតជាបាន ០៣ គីឡូម៉ែត្រ និងស្របតាមលក្ខខណ្ឌបច្ចេកទេសទាំងអស់ដែរឬទេ ។ |
| ហេតុអ្វី? | ប្រជាពលរដ្ឋមូលដ្ឋានអាចធ្វើដំណើរលើផ្លូវនេះបានយ៉ាងងាយស្រួល ។ ការធ្វើដំណើរដោយមធ្យោបាយផ្សេងៗ កាន់តែងាយស្រួល ហើយមានតំលៃថោកជាងមុន ។ ក្រោយពេលផ្លូវសាងសង់រួចរាល់ យើងគួរពិនិត្យមើលថា តើថ្លៃធ្វើដំណើរពិតជាបានថោកជាងមុនឬ ហើយបើសិនជាមានការធ្វើដំណើរកាន់តែច្រើនឡើង មានន័យថា ផ្លូវត្រូវបានកែលំអ ។ |
| នៅឯណា? | យើងត្រូវធ្វើការពិនិត្យនៅលើផែនទី ដើម្បីអោយប្រាកដថា ផ្លូវនេះត្រូវបានសាងសង់ នៅកន្លែងដែលបានកំណត់ ។ តែបើសិនជាគំរោងនេះ ជាការជួសជុលផ្លូវចាស់ដែលមានស្រាប់ នោះប្រាកដណាស់ផ្លូវដែលទើបជួសជុលរួច ពិតជានៅនឹងកន្លែងដើមជាមិនខាន លើកលែងតែមានករណីមួយចំនួន ដូចជា ទឹកជំនន់ ឬការបាក់ដី... ជាដើម ទើបអាចធ្វើអោយផ្លូវនោះត្រូវបាន កាត់បន្ថយចំងាយ ។ល។ |
| នៅពេលណា? | តារាងពតិមានគំរោងមិនបានផ្តល់ពតិមាននេះទេ ។ យើងត្រូវប្រមូលពតិមាននេះ ពីប្រភពផ្សេងៗទៀត ដូចជា ផែនការការងាររបស់អ្នកទទួលការ ។ អ្វីដែលយើងត្រូវដឹងគឺ តើគំរោងនឹងចាប់ផ្តើមនៅពេលណា បញ្ចប់នៅពេលណា ហើយតើការសាងសង់នេះ មានរយៈពេលប៉ុន្មានថ្ងៃ ។ ជាក់ស្តែង គំរោងនេះត្រូវចាប់ផ្តើមដំណើរការសាងសង់នៅរដូវប្រាំង ដើម្បីទទួលបានគុណភាពខ្ពស់ ។ |
| ដូចម្តេច? | សំរាប់គំរោងសាងសង់ និង គំរោងជួសជុលផ្លូវ កិច្ចសន្យាត្រូវបានធ្វើឡើង អោយអ្នកទទួលការធ្វើ ។ ការតាមដានត្រួតពិនិត្យផ្នែកបច្ចេកទេស នឹងត្រូវធ្វើឡើងដោយអ្នកត្រួតពិនិត្យបច្ចេកទេស ប៉ុន្តែគាត់មិនអាចធ្វើការតាមដានត្រួតពិនិត្យដល់ទីកន្លែង អោយបានរាល់ថ្ងៃនោះទេ ។ ដូចនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដានត្រួតពិនិត្យផ្នែកបច្ចេកទេសខ្លះៗដែរ ដូចជាពិនិត្យមើលថា តើផ្លូវត្រូវបានសាងសង់តាមទំហំ និងបណ្តោយ |

| | |
|---|---|
| | ដែលបានកំណត់ដែរឬទេ តើកំរាស់គ្រួសក្រហមត្រឹមត្រូវដែរឬទេ និង តើជើងទេផ្លូវត្រឹមត្រូវដែរឬទេ ។ |
| តំលៃប៉ុន្មាន? | ផ្អែកលើទំរង់ពតិមានគំរោង យើងឃើញថា គំរោងនេះនឹងចំណាយអស់ ២០លានរៀល ក្នុងឆ្នាំ ២០០៣ ហើយ ២០លានរៀលទៀតនៅឆ្នាំ ២០០៤ ។ ការទូទាត់នឹងត្រូវធ្វើឡើង អោយអ្នកទទួលការ បន្ទាប់ពីមានការបញ្ជាក់ពី អ្នកត្រួតពិនិត្យបច្ចេកទេស និងដែលមាន ការចុះហត្ថលេខារបស់មេឃុំ ចៅសង្កាត់ ។ |
| អ្នកទទួលផលប៉ុន្មាននាក់? | ផ្អែកលើទំរង់ពតិមានគំរោង យើងឃើញថា គំរោងនេះមានអ្នកទទួលផលសរុប ចំនួន ២៧០០នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ១៣៥១នាក់ ។ បន្ទាប់ពីគំរោងបានបញ្ចប់ យើង គួរតែធ្វើការពិនិត្យមើលថា តើប្រជាពលរដ្ឋមូលដ្ឋានយល់ថា ពួកគេពិតជាបានប្រយោជន៏ ពីផ្លូវនោះដែរឬទេ ហើយតើពួកគេទទួលបានក្នុងកំរិតណា ។ ប្រាកដណាស់ យើងនឹងមិនចុះ ទៅសាកសួរមនុស្សទាំង២៧០០នាក់ក្នុងឃុំនោះទេ ។ |

### ៦.១.៤. ការកំណត់វិធីសាស្ត្រសំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ

មានវិធីសាស្ត្រជាច្រើន សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ហើយវិធីសាស្ត្រខ្លះមានការលំបាក ឬចំណាយពេលវេលា និងធនធានច្រើនជាងវិធីសាស្ត្រឯទៀត ។ នៅក្នុងមេរៀននេះ យើងគ្រាន់តែលើកយក វិធីសាស្ត្រងាយៗមួយចំនួនតូចមកបញ្ជាក់ជូនតែប៉ុណ្ណោះ ។

**ការសង្កេតពិនិត្យ**

នេះជាឧបករណ៏សាមញ្ញបំផុតសំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ វិធីសាស្ត្រនេះ គឺ អ្នកដែលកំពុងធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវសួរខ្លួនឯងថា :

- តើខ្ញុំឃើញអ្វីខ្លះ ?
- តើប្រជាពលរដ្ឋធ្វើអ្វីខ្លះ ?
- តើសកម្មភាពគំរោងកំពុងចាប់ផ្តើមឬទេ ?

- តើវាបានអនុវត្តល្អ ដោយគ្មានឃើញកំហុស ឬវិបត្តិអ្វីឬទេ ?
- តើប្រជាពលរដ្ឋដែលគេគិតថា នឹងទទួលបានផលប្រយោជន៍ បានប្រើប្រាស់អ្វីដែលបានសាងសង់ឡើង ឬក៏ប្រើជំនាញ ឬចំណេះដឹងថ្មីដែលពួកគេបានទទួល ដែរឬទេ ?

## សំភាសន៍ផ្ទាល់ជាមួយមនុស្សសំខាន់ៗ

មនុស្សសំខាន់ គឺជាអ្នកដែលយល់ដឹងច្រើនជាងមនុស្សសាមញ្ញធម្មតា និង អាចពន្យល់បានអំពីអ្វីៗកំពុងកើតឡើង។ មនុស្សសំខាន់នៅទីនេះមិនមានន័យដល់អ្នកមានទ្រព្យសម្បត្តិ ឬបុណ្យសក្តិខ្ពង់ខ្ពស់នោះទេ។ ឧទាហរណ៍ : បើយើងចង់ដឹងពីការលំបាកនៅពេលស្រវឹងគ្រឿងញៀន នោះអ្នកដែលជក់គ្រឿងញៀន គឺជាមនុស្សសំខាន់ ព្រោះពួកគេជាមនុស្សដែលបានជួបប្រទះនូវការលំបាកទាំងនោះដោយខ្លួនឯង ។ ម្យ៉ាងទៀត បើយើងចង់ដឹង ពីរបៀបសំរាលកូន គឺមានតែឆ្មបទេ ដែលអាចផ្តល់ចំលើយត្រឹមត្រូវឱ្យយើងបានល្អជាងគេ ។

## ការសំភាសន៍ ឬការពិភាក្សាជាក្រុម

ជាធម្មតា ការពិភាក្សាក្រុមត្រូវចំណាយពេលប្រហែល ១ ទៅ ២ម៉ោង លើប្រធានបទជាក់លាក់ណាមួយជាមួយមនុស្សមួយក្រុមតូច ។ គុណសម្បត្តិមួយនៃការពិភាក្សាជាក្រុម គឺអាចទទួលបានគំនិតយោបល់អ្នកទាំងនោះរហ័សជាងការសំភាសន៍ជាមួយពួកគេម្នាក់ម្តងៗ ។ ការសំភាសន៍ ឬ ការពិភាក្សាជាក្រុមនេះអាចជំរុញអោយមានការផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ក្នុងចំណោមសមាជិកក្រុមពិភាក្សា ហើយយើងអាចទទួលបានពត៌មានច្រើន និងកាន់តែស៊ីជំរៅ ។ អ្នកសំរបសំរួលការពិភាក្សានេះ ជាធម្មតា ត្រូវរៀបចំសំណួរគន្លឹះមួយចំនួន សំរាប់បំផុសអោយមានការពិភាក្សា និង លើកសំណួរជជីកសួរបន្ត ដើម្បីទទួលបានពត៌មានលំអិត និងកាន់តែស៊ីជំរៅ ។

## បញ្ជីសំណួរ

បញ្ជីសំណួរគឺជាបញ្ជីមួយដែលមានសំណួរមួយចំនួន ដើម្បីប្រមូលពត៌មានពីអ្នកឆ្លើយតប។ វិធីសាស្ត្រនេះត្រូវប្រើប្រាស់សំណួរដូចៗគ្នា ដើម្បីសួរទៅកាន់មនុស្សជាច្រើន ហើយត្រូវសរសេរចំលើយរបស់ពួកគេទុក ។ ជួនកាលការប្រើបញ្ជីសំណួរដើម្បីប្រមូលពត៌មាន គឺគេហៅថាជា ការអង្កេត ។

*ឧទាហរណ៍ :* ការតាមដានត្រួតពិនិត្យ និងវាយតំលៃលើគំរោងទឹកស្អាត

ឃុំបានសំរេចចិត្តកសាងកន្លែងផលិតទឹកស្អាតមួយកន្លែងនៅក្បែរផ្សារ ។ ដូចនេះ អ្នកផ្សារនឹងមានការងាយស្រួល និងចំណាយកាន់តែតិចក្នុងការប្រើប្រាស់ទឹក ដោយមិនចាំបាច់ទិញទឹកពីអ្នកដឹកទឹកលក់ ទៀតនោះទេ ។ គំរោងនេះ ក៏អាចដោះស្រាយបញ្ហាអនាម័យនៅជុំវិញផ្សារផងដែរ ដោយសារមិនមានបង្គន់អនាម័យសំរាប់ប្រើ ។

ក្នុងអំឡុងពេលសាងសង់ សមាជិកនានានៃគណៈកម្មការគ្រប់គ្រងគំរោង បានរៀបចំកាលវិភាគចុះសង្កេត ការសាងសង់រៀងរាល់ថ្ងៃ ។ ពួកគេនឹងធ្វើការពិនិត្យមើលថាតើ អ្នកទទួលការពិតជាបានអនុវត្តស្របទៅតាមគំនូសប្លង់បច្ចេកទេសដែរឬទេ (ទំហំ កំពស់ជញ្ជាំង លូបង្ហូរទឹកស្អុយ ។ល។) ពួកគេក៏នឹងពិនិត្យផងដែរថា តើឧបករណ៍ដែលអ្នកទទួលការយកមកប្រើប្រាស់ សមស្របទៅតាមអ្វីដែលបានកំណត់ នៅក្នុងកិច្ចសន្យាដែរឬទេ និងថាតើការសាងសង់ត្រូវបានធ្វើឡើងត្រឹមត្រូវដែរឬទេ មិនលឿនពេក ឬ មិនយឺតពេក ។

នៅពេលចាប់ផ្តើមប្រើប្រាស់សមិទ្ធផល គណៈកម្មការគ្រប់គ្រងគំរោង បានសូមអោយអ្នកលក់ដូរនៅក្នុងផ្សារម្នាក់ ដែលមានស្តង់លក់ដូរនៅក្បែរកន្លែងទឹកស្អាតដែលទើបបានសាងសង់ថ្មីនោះឱ្យ ធ្វើការសង្កេតក្នុងខែដំបូង ដើម្បីចង់ដឹងថា តើឧបករណ៍ថ្មីនោះត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច ? តើមានមនុស្សប្រើប្រាស់ប៉ុន្មាននាក់ ? តើឧបករណ៍នោះនៅតែល្អ និងគ្មានក្លិនស្អុយទេឬ ? (ក្រុមប្រឹក្សាឃុំបានធ្វើកិច្ចសន្យាជាមួយអ្នកផ្សេងទៀតអោយសំអាតកន្លែងនេះ២ដង ក្នុង ១ថ្ងៃ) ។

មួយខែក្រោយមក គណៈកម្មការគ្រប់គ្រងគំរោងបានសំរេចចិត្តប្រមូលពត៌មានមួយចំនួន ថាតើសំភារៈនេះ ត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច ។ ពួកគេបានសំរេចចិត្ត ធ្វើការសំភាសន៍ជាមួយមនុស្សសំខាន់ ២នាក់ (អ្នកសំអាតកន្លែងឧបករណ៍ និង អ្នកលក់ដូរដែលបានធ្វើការតាមដានត្រួតពិនិត្យការប្រើប្រាស់ឧបករណ៍នេះ ក្នុងមួយខែដំបូង) ។

ពួកគេក៏បានសំរេចចិត្ត ធ្វើការអង្កេតចំនួន២ផងដែរ ។ ការអង្កេតទី១ ត្រូវធ្វើជាមួយអ្នកលក់ដូរក្នុងផ្សារ ដោយប្រើសំណួរចំនួន៣ ដូច១គ្នា ÷

១. តើអ្នកទទួលបានប្រយោជន៍ពីឧបករណ៍ថ្មីនេះដែរឬទេ ? បើសិនជាមិនបាន តើហេតុអ្វី?

២. តើអ្នកមានការពេញចិត្តនឹងឧបករណ៍នេះកំរិតណា ? សូមជ្រើសរើសលំដាប់ដែលអ្នកយល់

ថាត្រឹមត្រូវពី លេខ ១ ដល់លេខ ៥ ( លេខ ១ មានន័យថា មិនពេញចិត្ត ហើយ លេខ ៥ មានន័យថា ពេញចិត្តខ្លាំង ) ។

៣. តើយើងគួរធ្វើអ្វីខ្លះ ដើម្បីកែលំអចំណុចដែលមិនពេញចិត្តទាំងនោះ ?

ការអង្កេតលើកទី២ ត្រូវធ្វើទៅលើក្រុមអ្នកប្រើប្រាស់ ។ គណៈកម្មការគ្រប់គ្រងគំរោង ត្រូវធ្វើការសំភាសន៍ជាមួយអ្នកប្រើប្រាស់ ដោយប្រើសំណួរមួយចំនួន ÷

១. តើអ្នកមានការពេញចិត្តនឹងឧបករណ៍នេះក៏រិតណា ? សូមជ្រើសរើសលំដាប់ដែលអ្នកយល់ថាត្រឹមត្រូវ ពីលេខ ១ ដល់លេខ ៥ ( លេខ ១ មានន័យថា មិនពេញចិត្ត ហើយ លេខ ៥ មានន័យថា ពេញចិត្តខ្លាំង ) ។

២. តើមានអ្វីខ្លះដែលចាំបាច់ត្រូវធ្វើការកែលំអ ? ហើយត្រូវកែលំអយ៉ាងដូចម្តេច ?

☞ អ្នកសំភាសន៍ ក៏ត្រូវកត់ត្រាផងដែរ ពីភេទរបស់អ្នកឆ្លើយតបការសំភាសន៍ និងតើអ្នកឆ្លើយតបរូបនោះជាអ្នកលក់ដូរក្នុងផ្សារ ឬជាអ្នកមកទិញទំនិញក្នុងផ្សារ ។

បន្ទាប់ពីការវាយតំលៃខាងលើ គណៈកម្មការគ្រប់គ្រងគំរោងបានពិភាក្សាគ្នាថា តើគួរធ្វើការតាមដានត្រួតពិនិត្យ ចំនួន២ដង ក្នុងមួយខែ សំរាប់រយៈពេលមួយឆ្នាំដែរឬទេ ?

១. សមាជិកម្នាក់ត្រូវចុះទស្សនកិច្ចតាមដានត្រួតពិនិត្យ ទៅដល់កន្លែងឧបករណ៍នោះ ម្តងក្នុង ១ខែ ដើម្បីពិនិត្យមើលថា តើឧបករណ៍នេះ នៅរក្សាបាននូវអនាម័យ និងទ្រង់ទ្រាយល្អដូចដើមដែរឬទេ (បំពង់ លូដំណើរការល្អ មិនមានជង្ហុកទឹកដក់ និងមិនមានក្លិនស្អុយ) ។ សមាជិកនោះត្រូវធ្វើរបាយការណ៍ខ្លីមួយ ស្តីពីការចុះពិនិត្យរបស់គំរោងនេះ ។

២. ជារៀងរាល់ខែ គណៈកម្មការគ្រប់គ្រងគំរោង ត្រូវធ្វើការសំភាសន៍ ដោយចៃដន្យជាមួយនឹងអ្នកលក់ដូរក្នុងផ្សារចំនួន២០នាក់ ដើម្បីចង់ដឹងមើលថាតើ អ្នកទាំងនោះបានប្រើប្រាស់ឧបករណ៍នោះដែរឬទេ ( បើសិនមិនបាន ហេតុអ្វី ? ) ហើយថាតើពួកគេយល់ថាឧបករណ៍នេះនៅរក្សាបានលក្ខណៈដើម ឬ មានការខូចខាតខ្លះហើយ ។

## ៦.១.៥. ការរៀបចំផែនការសកម្មភាព

រហូតដល់ពេលនេះ យើងបានដឹងពីពត៌មានដែលត្រូវប្រមូល វិធីសាស្រ្តប្រមូលពត៌មាន និងសំណួរសំខាន់ៗ ដែលយើងត្រូវសួរ ។ ដូចនេះយើងត្រូវសំរេចចិត្តថាតើត្រូវចាប់ផ្តើមសកម្មភាពឬការងារ នៅពេលណា ហើយអ្នកណាធ្វើអ្វីខ្លះ ។

ឧបករណ៍មួយដែលយើងអាចប្រើបាន និងដែលអាចអោយយើងបង្ហាញនូវរាល់ពត៌មានដែលពាក់ព័ន្ធ គឺតារាងម៉ាទ្រិកផែនការសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ផែនការសកម្មភាពនេះ អាចមានទំរង់ដូចខាងក្រោម :

| សូចនាករ | សំណួរគន្លឹះ | វិធីសាស្ត្រ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

យើងអាចកែតំរូវតារាងម៉ាទ្រិកផែនការសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃនេះ ដោយបន្ថែមកូឡោន ឬផ្លាស់ប្តូរទីតាំងកូឡោននីមួយៗក៏បាន ទៅតាមតំរូវការជាក់ស្តែង ។ ខាងក្រោមនេះ គឺជាឧទាហរណ៍បញ្ជាក់ពីការរៀបចំតារាងម៉ាទ្រិកផែនការសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃ ។

*តារាងម៉ាទ្រិកផែនការសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃលើគំរោងកែលំអផ្លូវ*

| សូចនាករ | សំណួរគន្លឹះ | វិធីសាស្ត្រ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ទីតាំងពិតប្រាកដរបស់ផ្លូវ | តើអ្នកទទួលការបានសាងសង់ផ្លូវ ទៅតាមទីកន្លែងដែលបានកំណត់ ដែរឬទេ? | ការសង្កេតពិនិត្យ | -ពេលចាប់ផ្តើមគំរោង<br>-ក្រោយពេលចាក់គ្រឹះ | -អ្នកត្រួតពិនិត្យបច្ចេកទេស (លោក ក)<br>-គណៈកម្មការគ្រប់គ្រងគំរោង (លោក ខ លោក គ ...) |
| ទំហំផ្លូវ | តើផ្លូវមានបណ្តោយ ទទឹង និង កំរាស់ផ្លូវ ត្រឹមត្រូវដែរឬទេ? | -ការសង្កេតពិនិត្យ<br>-វាស់វែង | ២ដងក្នុង១សប្តាហ៍ ដោយចៃដន្យ | |
| លូបង្ហូរ | តើនៅសងខាងផ្លូវមានលូបង្ហូរ ដែរឬទេ? កំពស់ និង ទំហំសមស្រប ដែរឬទេ? តើទឹកភ្លៀង អាចហូរបានដោយស្រួលដែរឬទេ? | -ការសង្កេតពិនិត្យ<br>-វាស់វែង | ការត្រួតពិនិត្យជាទូទៅមុនពេលអនុម័ត បើកប្រាក់បន្ទាប់ពីភ្លៀងខ្លាំង ចុះពិនិត្យថា តើលូបង្ហូរអាចទ្រាំទ្រ ដែរឬទេ? | |

| សូចនាករ | សំណួរគន្លឹះ | វិធីសាស្ត្រ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពេលវេលា និងការចំណាយលើការធ្វើដំណើរ | ក្រោយពីផ្លូវត្រូវបានកែលំអ តើរយៈពេល និងការចំណាយលើការធ្វើដំណើរ ត្រូវបានកាត់បន្ថយដែរឬទេ ? | ការអង្កេតលើអ្នកបើកតាក់ស៊ី ៥នាក់ ដោយសួរថាតើត្រូវចំណាយពេល និងតំលៃប៉ុន្មាន សំរាប់ការធ្វើដំណើរម្តង ។ | រៀងរាល់៣ខែម្តង ក្រោយពីផ្លូវបានសាងសង់បញ្ចប់ | -ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់ |
| ការធ្វើចរាចរលើផ្លូវ | -តើមានការធ្វើចរាចរច្រើនជាងមុនឬ?<br>-តើការធ្វើចរាចរលើផ្លូវនេះមានរូបភាពអ្វីខ្លះ ? (ឡានធំៗ ...) | រាប់រទេះគោ កង់ ម៉ូតូ រថយន្ត និង រថយន្តធំៗ ។ | - ធ្វើម្តងមុនពេលគំរោងផ្លូវចាប់ផ្តើម<br>- រៀងរាល់បីខែម្តង បន្ទាប់ពី គំរោងផ្លូវបានបញ្ចប់ ។ | គណៈកម្មការគ្រប់គ្រងគំរោង (លោក ខ លោក គ ..) |
| កំណើនសេវាកម្មក្នុងឃុំ | -តើមានសេវាកម្មច្រើនជាងមុនដែលត្រូវ បានបញ្ជូនទៅឃុំឬ ?<br>-តើគុណភាពរបស់វា ល្អជាងមុនឬ ? | -សង្កេតមើលនៅក្នុងសាលាឃុំ<br>-រៀបចំសំនួរ សំរាប់សួរប្រជាពលរដ្ឋមួយចំនួន | -ជាប្រចាំ<br>-មួយខែម្តង ឬ ៣ខែម្តង | -មេឃុំ<br>-ក្រុមប្រឹក្សា<br>-ស្មៀន |
| កំណើនប្រាក់ចំណូលរបស់កសិករ | -តើប្រាក់ចំណូលរបស់កសិករកើនឡើងឬ ?<br>-បើសិនជាកើន តើវាកើនក្នុងចំណោមកសិករប្រភេទណា ហើយកើនបានប៉ុន្មាន ? | អង្កេតលើកសិករ១០ នាក់ ក្នុង ១ភូមិៗ ដើម្បីពិនិត្យមើលថាតើពួកគេលក់ផលិតផល បានក្នុងតំលៃប៉ុន្មាន។ | មួយខែ ក្រោយពីប្រមូលផល | -ជនបង្គោលតាមដាន និងវាយតំលៃ<br>-សមាជិក គ.ផ.ថ |

| សូចនាករ | សំណួរគន្លឹះ | វិធីសាស្ត្រ | ពេលវេលា | អ្នកទទួលខុសត្រូវ |
| --- | --- | --- | --- | --- |
| ការប្រើប្រាស់ផ្លូវ | -តើផ្លូវនេះ អាចប្រើប្រាស់បានយូរអង្វែងឬទេ ?<br>-តើផ្លូវពេលនេះមានស្ថានភាពយ៉ាងណាដែរ ? | -សង្កេតមើលផ្លូវ<br>-សួរអ្នកធ្វើដំណើរ | រៀងរាល់បីខែម្តង បន្ទាប់ពី គំរោងផ្លូវបានបញ្ចប់ ។ | គណៈកម្មការគ្រប់គ្រងគំរោង (លោក ខ លោក គ ..) |
| តំរូវការថែទាំ និងជួសជុលផ្លូវ | -តើមានផ្នែកណាខ្លះនៃផ្លូវដែលត្រូវជួសជុល ?<br>-បើសិនជាមាន នៅកន្លែងណា ចំណាយប៉ុន្មាន ហើយត្រូវជួសជុលអ្វីខ្លះ ? | -សង្កេតលើផ្នែកដែលខូចខាត ដោយរាប់ប៉ុន្មានកន្លែង និង ត្រូវជួសជុលក៏រិតណា ? | ពិនិត្យជារៀងរាល់ខែ | គណៈកម្មការគ្រប់គ្រងគំរោង (លោក ខ លោក គ ..) |

## ៦.២. ការប្រមូលពត៌មាន

### ៦.២.១. ប្រភពនៃពត៌មាន

ដើម្បីធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ យើងត្រូវការពត៌មានជាមូលដ្ឋាន ។ មុនចាប់ផ្តើមប្រមូលពត៌មាន យើងត្រូវពិនិត្យមើល <u>ពត៌មានដែលមានស្រាប់</u> ។ ពត៌មានដែលមានស្រាប់នេះ គឺជាពត៌មានដែលត្រូវបានប្រមូលដោយអ្នកដទៃ ។ ដូច្នេះជាការសំខាន់ យើងត្រូវមានប្រព័ន្ធរក្សាពត៌មាន និងឯកសារមួយដ៏ល្អ ។ ដូច្នេះការប្រមូលពត៌មានរបស់យើងកន្លងមក អាចជួយយើងនាពេលអនាគត ។

ប្រភពទិន្នន័យមួយ ដែលមានទិន្នន័យសំរាប់គ្រប់ឃុំ សង្កាត់ទាំងអស់ ហើយដែលត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ គឺ **ប្រព័ន្ធទិន្នន័យឃុំ សង្កាត់** ។ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចរកបានពត៌មានមួយចំនួន សំរាប់ភូមិនីមួយៗ ចេញពីប្រព័ន្ធទិន្នន័យឃុំ សង្កាត់នេះផងដែរ ។

បើសិនជាពត៌មានដែលយើងត្រូវការ តែមិនទាន់មាននៅឡើយ ដូចនេះយើងត្រូវពិចារណាថា តើត្រូវប្រមូលពត៌មានទាំងនោះយ៉ាងដូចម្តេច ។ ពត៌មាននេះហៅថា <u>ពត៌មានថ្មី ដែលត្រូវប្រមូល</u> ។ ពត៌មានបែបនេះគឺជាពត៌មានដែលយើងត្រូវចុះប្រមូល ជាពិសេសសំរាប់គោលបំណងរបស់យើង ។ ជាការសំខាន់ យើងត្រូវប្រុង

ប្រយ័ត្នអោយបានខ្ពស់ ថាតើត្រូវប្រមូលពត៌មានអ្វីខ្លះសំរាប់គោលបំណងរបស់យើង ដោយជៀសវាងការប្រមូលពត៌មានដែលមិនសូវចាំបាច់ ។

☞ ពេលប្រមូលពត៌មានស្តីពីការអនុវត្តគំរោង មានទិដ្ឋភាព ២ យ៉ាងត្រូវយកចិត្តទុកដាក់ជាពិសេសគឺ ÷

- **ផលប៉ះពាល់ទៅលើស្ត្រី** : ជារឿយៗគំរោងមួយ មិនបានផ្តល់ផលប្រយោជន៏ដល់បុរស និង ស្ត្រីស្មើគ្នានោះទេ ។ ជួនកាលបុរសបានទទួលផលប្រយោជន៏ពីគំរោងច្រើនជាងស្ត្រី ហើយលើសពីនេះទៀត ស្ត្រីមានស្ថានភាពកាន់តែអាក្រក់ជាងមុន ។ ដូចនេះ ជាការសំខាន់មិនគ្រាន់តែប្រមូលពត៌មានអំពី " **ប្រជាពលរដ្ឋដែលទទួលផលប្រយោជន៏** " ប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រមូលពត៌មានអំពី " **ស្ត្រីដែលទទួលផលប្រយោជន៏** " និង " **បុរសដែលទទួលផលប្រយោជន៏** " ដោយឡែកពីគ្នា ។
- **ផលប៉ះពាល់ទៅលើអ្នកក្រីក្រ ឬជនងាយរងគ្រោះ** : ប្រសិនបើយើងមិនបានប្រុងប្រយ័ត្នទេ គំរោងមួយអាចបំរើផលប្រយោជន៏ អោយតែប្រជាពលរដ្ឋដែលមានជីវភាពធូរធារ នៅក្នុងឃុំ សង្កាត់ប៉ុណ្ណោះ ដោយមិនបានផ្តល់ផលប្រយោជន៏ដល់ប្រជាពលរដ្ឋដែលក្រីក្រ ឬជនងាយទទួលរងគ្រោះនោះទេ ។ យើងត្រូវធ្វើការសង្កេតថា តើប្រជាពលរដ្ឋក្រីក្រ ឬជនងាយទទួលរងគ្រោះ បានទទួល ឬមិនបានទទួលផលប្រយោជន៏ ហើយប្រសិនបើពួកគេបានទទួលផលប្រយោជន៏ តើទំហំ នៃផលប្រយោជន៏ដែលពួកគេបានទទួល មានទំហំប៉ុន្មាន ប្រៀបធៀបជាមួយប្រជាពលរដ្ឋដទៃទៀត ដែលទទួលផលប្រយោជន៏ពីគំរោងដូចគ្នានោះ ?

## ៦.២.២. ឧបករណ៍សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ

ដើម្បីជាជំនួយក្នុងការប្រមូលពត៌មាន យើងមានវិធីសាស្ត្រ និងឧបករណ៍ជាច្រើនដែលយើងអាចប្រើបាន ។ ឃុំ សង្កាត់នីមួយៗអាចបង្កើតឧបករណ៍ផ្សេងៗ សំរាប់គោលបំណងនេះ អាស្រ័យទៅតាមការចាំបាច់ និងភាពងាយស្រួលរបស់ខ្លួន។ សៀវភៅមេរៀននេះ នឹងបង្ហាញដោយសង្ខេបនូវឧបករណ៍ចំនួន៦ ដូចខាងក្រោម ÷

ក- តារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៏នៅក្នុងឃុំ សង្កាត់

ខ- ទំរង់តាមដានត្រួតពិនិត្យការអនុវត្តគំរោង

គ- ទំរង់វាយតំលៃគំរោង

ឃ- សៀវភៅកំណត់ហេតុ

ង-　បញ្ជីត្រួតពិនិត្យ

ច-　កាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ

☞ ឧបករណ៍ទាំងនេះ គឺប្រើប្រាស់សំរាប់ ផ្ទៃក្នុង របស់ឃុំ សង្កាត់ ។ ចំណែករបាយការណ៍ឃុំ សង្កាត់ត្រូវប្រើគំរូរបាយការណ៍មួយផ្សេងទៀត សំរាប់រាយការណ៍ជូនទៅថ្នាក់លើ ។

## ក. តារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់

ប្រភពពត៌មានមួយដ៏សំខាន់ សំរាប់ការអនុវត្តគំរោងឃុំ សង្កាត់ និងការផ្តល់សេវាកម្មនោះ គឺ កម្មវិធីវិនិយោគឃុំ សង្កាត់៣ឆ្នាំរំកិល (តារាង ៣.ក) ។ ពត៌មានពីកម្មវិធីវិនិយោគឃុំ សង្កាត់៣ឆ្នាំរំកិលនេះ គឺត្រូវបានប្រើសំរាប់រៀបចំតារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់ (សូមមើលនៅទំព័រទី៤២) ដែលត្រូវប្រើប្រាស់ពេញមួយឆ្នាំ។ ក្រុមប្រឹក្សាឃុំ សង្កាត់ គួរតែពិនិត្យលើតារាងតាមដាន ត្រួតពិនិត្យ គំរោងអភិវឌ្ឍន៍នៅក្នុងឃុំសង្កាត់នេះអោយបានទៀងទាត់រៀងរាល់បីខែម្តង ដើម្បីវាយតំលៃលើស្ថានភាពបច្ចុប្បន្នរបស់គំរោងនីមួយៗ ដែលបានចុះកិច្ចព្រមព្រៀង និងកំណត់ថា តើគំរោងណាខ្លះត្រូវបានអនុវត្ត និងមិនបានអនុវត្ត ។ គំរោងដែលត្រូវចុះក្នុងតារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់ ÷

- គំរោង ឬ សកម្មភាពដែល កំពុងដំណើរការអនុវត្ត ឬ គំរោង ឬសកម្មភាពដែលមានការគាំទ្រដែលមាននៅក្នុង កូឡោនឆ្នាំទី១ នៃ ចំនួនលទ្ធផល (កូឡោនទី៤) នៅក្នុងតារាងកម្មវិធីវិនិយោគឃុំ សង្កាត់ ។
- គំរោង ឬ សកម្មភាពផ្សេងៗទៀតដែលអនុវត្តដោយអ្នកដទៃ និង ដែលមិនមាននៅក្នុងតារាងកម្មវិធីវិនិយោគ ។

## តារាង ៣.គ : តារាងវិនិយោគឃុំ សង្កាត់៣ឆ្នាំរំកិល

| លរ | ឈ្មោះគំរោង | ទីតាំង | ចំនួនលទ្ធផល | | | តំលៃចាន់ស្មាន (គិតជាដុល្លារ) | អ្នកទទួលផល | | អ្នកសិក្សាគំរោង | ប្រភពគាំទ្រថវិកា | អ្នកទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០០៤ | ២០០៥ | ២០០៦ | | សរុប | ស្រី | | | |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **គំរោងកំពុងដំណើរការ (បើមាន)** | | | | | | | | | | | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| **គំរោងវិនិយោគដែលមានការគាំទ្រ** | | | | | | | | | | | |
| ក). ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| សរុបតំលៃចាន់ស្មានផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| ខ). ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| សរុបតំលៃចាន់ស្មានផ្នែកសង្គមកិច្ច | | | | | | | | | | | |
| គ). ផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| សរុបតំលៃចាន់ស្មានផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | | |
| ឃ). ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| សរុបតំលៃចាន់ស្មានផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | | |
| ង). ផ្នែកយេនឌ័រ | | | | | | | | | | | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| សរុបតំលៃចាន់ស្មានផ្នែកយេនឌ័រ | | | | | | | | | | | |
| សរុបរួមតំលៃចាន់ស្មានគំរោងមានការគាំទ្រ | | | | | | | | | | | |

# តារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់

ឃុំ សង្កាត់ : .......................... ស្រុក ខណ្ឌ.............................. ខេត្ត ក្រុង .......................... ឆ្នាំ ២០០_

| ល.រ | គំរោង | ទីតាំងគំរោង | អ្នកអនុវត្ត / អ្នកទទួលការ | គំរោងអនុវត្តក្នុងឆ្នាំ ២០០_ | | ចំនួនភាគរយដែលគំរោងបានបញ្ចប់ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មាន កិ.ប | គ្មាន កិ.ប | ត្រីមាស ទី១ | | ត្រីមាស ទី២ | | ត្រីមាស ទី៣ | | ត្រីមាស ទី៤ | |
| | | | | | | ចាប់ផ្តើម | %បញ្ចប់ | ចាប់ផ្តើម | %បញ្ចប់ | ចាប់ផ្តើម | %បញ្ចប់ | ចាប់ផ្តើម | %បញ្ចប់ |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

**ឧទាហរណ៍ :**

*ឃុំ សង្កាត់ : .......................... ស្រុក ខណ្ឌ.............................. ខេត្ត ក្រុង .......................... ឆ្នាំ ២០០_*

| ល.រ | គំរោង | ទីតាំងគំរោង | អ្នកអនុវត្ត / អ្នកទទួលការ | គំរោងអនុវត្តក្នុងឆ្នាំ ២០០_ | | ចំនួនភាគរយដែលគំរោងបានបញ្ចប់ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មាន កិ.ប | គ្មាន កិ.ប | ត្រីមាស ទី១ | | ត្រីមាស ទី២ | | ត្រីមាស ទី៣ | | ត្រីមាស ទី៤ | |
| | | | | | | បាន់ចប់ ឬមិន | %បញ្ចប់ | បាន់ចប់ ឬមិន | %បញ្ចប់ | បាន់ចប់ ឬមិន | %បញ្ចប់ | បាន់ចប់ ឬមិន | %បញ្ចប់ |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ |
| ១ | កែលំអផ្លូវគ្រួសក្រហម | ភូមិ ក ទៅភូមិ ខ | ឃុំ | | √ | មិន | 0 | បាន | ២0 | បាន | ៨0 | បាន | ១00 |
| ២ | វគ្គបណ្តុះបណ្តាលពីយេនឌ័រ | ជនបង្គោល២នាក់ | មន្ទីរកិច្ចការនារី | √ | | មិន | 0 | បាន | ១00 | | | | |
| ៣ | ម៉ាស៊ីនបូមទឹក | ភូមិ គ. | មន្ទីរអភិវឌ្ឍន៍ | √ | | មិន | 0 | មិន | 0 | មិន | 0 | មិន | 0 |
| ៤ | វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ | ស្ត្រី១០នាក់ | អង្គការ កខគ | | √ | បាន | ១00 | | | | | | |
| ៥ | អណ្តូងទឹក | ភូមិ ក និងភូមិ គ | លោក ជ. | | √ | | | | | បាន | ៧៥ | បាន | ១00 |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

### តើត្រូវបំពេញតារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់យ៉ាងដូចម្តេច ?

១. នៅពេលចាប់ផ្តើមបំពេញតារាងនេះជាលើកដំបូង យើងត្រូវដកស្រង់យកពត៌មានគំរោង ឬសកម្មភាព ដែលមាននៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ពាឆ្នាំរំកិល (តារាង ៣.ក) ហើយដែលបានចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន ចុះក្នុងកូឡោនទី១ ដល់កូឡោនទី៤ ហើយសូមក្បៀស (√) នៅក្នុងកូឡោនទី៥។

២. សំរាប់ការវាយតំលៃនៅត្រីមាសទី១ (មករាដល់មិនា) ត្រូវពិនិត្យលើបញ្ជីសកម្មភាពទាំងអស់ និងពិនិត្យមើលថាតើសកម្មភាពណាខ្លះដែលបានចាប់ផ្តើមដំណើរការ និងភាគរយដែលបានបញ្ចប់ ។ ពត៌មាននេះត្រូវចុះនៅក្នុងកូឡោនទី៧ និងកូឡោនទី៨។

៣. ចំពោះសកម្មភាព ឬគំរោងមួយចំនួននៅក្នុងកម្មវិធីវិនិយោគឃុំសង្កាត់ពាឆ្នាំរំកិល(តារាង ៣.ក) ដែលបានអនុវត្តនៅក្នុងឃុំសង្កាត់ ហើយដែលគ្មានកិច្ចព្រមព្រៀងបណ្តោះអាសន្ន សូមបញ្ចូលសកម្មភាព ឬគំរោងទាំងនេះនៅក្នុងតារាងតាមដានត្រួតពិនិត្យការអនុវត្តគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់នេះ នៅពីខាងក្រោមសកម្មភាពដែលមានស្រាប់ ហើយត្រូវបំពេញពត៌មានផ្សេងៗទៀត ដូចគ្នានឹងសកម្មភាពនានាដែលមាននៅក្នុងតារាង៣.កដែរ ហើយសូមក្បៀស (√) នៅក្នុង កូឡោនទី៦។

៤. សំរាប់ត្រីមាសទី២ ទី៣ និងទី៤ ត្រូវធ្វើដូចត្រីមាសទី១ដែរ ហើយត្រូវបំពេញពត៌មាន ស្របទៅតាមត្រីមាសនីមួយៗ ។

៥. បញ្ជូនតារាងដែលបានធ្វើបច្ចុប្បន្នភាពហើយទៅថ្នាក់ខេត្ត-ក្រុង ជាមួយនឹងរបាយការណ៍ប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅរៀងរាល់ខែទី៣នៃត្រីមាស (ខែមីនា ខែមិថុនា ខែកញ្ញា និងខែធ្នូ)។

☞ នៅពេលណាដែលឃុំ សង្កាត់ពិនិត្យឃើញថា មានសកម្មភាពណាមួយមិនត្រូវបានអនុវត្តទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ គួរតែសាកសួរមន្ទីរ ឬ អង្គការមិនមែនរដ្ឋាភិបាលដែលព្រមព្រៀងផ្តល់ការគាំទ្រ ថាតើហេតុអ្វីបានជាមិនទាន់ចាប់ផ្តើមអនុវត្តតាមការសន្យា ហើយតើត្រូវអនុវត្តនៅពេលណា ។

☞ ក្នុងការសំរេចចិត្តថាតើត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃលើអ្វីខ្លះ ជាការសំខាន់ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវពិចារណាគ្រប់ផ្នែកទាំងអស់របស់ឃុំ សង្កាត់ ។ ករណីខ្លះ អាចមានភូមិមួយចំនួនដែលមាន ឬ មិនមានសកម្មភាពអភិវឌ្ឍន៍ឃុំ សង្កាត់ តែទោះជាភូមិណាមួយគ្មានសកម្មភាពអភិវឌ្ឍន៍ក៏ដោយ ក៏ត្រូវបានតាមដានត្រួតពិនិត្យ និងវាយតំលៃផងដែរ ។

## ខ. ទំរង់តាមដានត្រួតពិនិត្យការអនុវត្តគំរោង

ទំរង់តាមដានត្រួតពិនិត្យការអនុវត្តគំរោង គឺជាទំរង់ទូទៅមួយ សំរាប់ប្រមូល និងកត់ត្រាពត៌មានដែលបានមកពីការតាមដានត្រួតពិនិត្យលើប្រភេទសកម្មភាព ឬគំរោងផ្សេងៗគ្នា ។ ទំរង់នេះ ក៏អាចជួយអោយយើងប្រមូលបាននូវពត៌មាន និងកត់ត្រាយ៉ាងត្រឹមត្រូវ សំរាប់គ្រប់ប្រភេទនៃសកម្មភាព ឬគំរោងទាំងអស់ ។

### ទំរង់តាមដានត្រួតពិនិត្យការអនុវត្តគំរោង

**ពត៌មានទូទៅ**

| | | |
|---|---|---|
| ឈ្មោះឃុំ សង្កាត់ : | លេខកូដគំរោងឬកិច្ចសន្យា : | ឈ្មោះគំរោង : |
| ឈ្មោះភូមិ :<br>–<br>–<br>– | ការចុះតាមដានលើកទី : | ឈ្មោះភ្នាក់ងារ ឬអ្នកអនុវត្តគំរោង : |
| | កាលបរិច្ឆេទចុះតាមដាន : | ឈ្មោះអ្នកចុះតាមដាន : |

**ពត៌មានតាមដាន ត្រួតពិនិត្យ**

១. តើគំរោងបានចាប់ផ្តើមអនុវត្តជាក់ស្តែងនៅពេលណា ? ☐

២. ចំនួនភាគរយ (%) នៃការងារដែលបានបញ្ចប់ជាក់ស្តែង ☐ %

៣. តើចំនួនភាគរយនេះ ដូចគ្នានឹងការគ្រោងទុកដែរឬទេ ?

☐ ដូច

☐ មិនដូច

បើមិនដូច ចូរបញ្ជាក់មូលហេតុ :

៤. តើគំរោងត្រូវបានអនុវត្តនៅទីតាំងដូចដែលបានកំណត់ក្នុងផែនការដែរឬទេ ?

☐ ដូច

☐ មិនដូច

បើមិនដូច ចូរបញ្ជាក់មូលហេតុ :

៥. តើអ្នកបានជួបមេការ ឬអ្នកអនុវត្តគំរោង (គំរោងសេវាកម្ម) នៅកន្លែងទីតាំងគំរោងដែរឬទេ ?

☐ បាន (ចូរសរសេរយោបល់ ឬការតវ៉ារបស់មេការ ឬអ្នកអនុវត្តជុំវិញការអនុវត្តគំរោង)--------

------------------------------------------------------------------------

------------------------------------------------------------------------

☐ មិនបាន (ចូរបញ្ជាក់មូលហេតុ)------------------------------------------------

------------------------------------------------------------------------

៦. តើអ្នកបានជួបតំណាងម្ចាស់គំរោង (ចំពោះគំរោងមូលនិធិឃុំ សង្កាត់) នៅទីតាំងគំរោងដែរឬទេ?

☐ បាន (ចូរសរសេរយោបល់របស់តំណាងម្ចាស់គំរោង ជុំវិញការអនុវត្តគំរោង)---------------

------------------------------------------------------------------------

------------------------------------------------------------------------

------------------------------------------------------------------------

☐ មិនបាន (ចូរបញ្ជាក់មូលហេតុ)------------------------------------------------

------------------------------------------------------------------------

៧. តើប្រជាពលរដ្ឋមូលដ្ឋានមានយោបល់អ្វីខ្លះជុំវិញការអនុវត្តគំរោង ? ចូររៀបរាប់--------------

------------------------------------------------------------------------

------------------------------------------------------------------------

------------------------------------------------------------------------

៨. តើអ្នកបានសង្កេតឃើញអ្វីខ្លះ ? ចូររៀបរាប់---------------------------------------

---------(លទ្ធផលជាក់ស្តែង : បរិមាណ និងគុណភាព)---------------------------------

--------(បញ្ហានានា)-----------------------------------------------------------

------------------------------------------------------------------------

៩. អនុសាសន៍

------------(យោបល់ដើម្បីកែលំអទៅលើចំណុចខ្វះខាត)-----------------------------

------------------------------------------------------------------------

------------------------------------------------------------------------

------------------------------------------------------------------------

## គ. ទំរង់វាយតំលៃគំរោង

ទំរង់វាយតំលៃគំរោង គឺជាទំរង់ទូទៅមួយ ដែលត្រូវបានគេប្រើប្រាស់សំរាប់ប្រមូលនិងកត់ត្រាពត៌មានសំរាប់ប្រភេទសកម្មភាព ឬគំរោងផ្សេងៗគ្នា ។ ទំរង់នេះ អាចជួយអោយយើងប្រមូលបាន និងរក្សាទុកនូវពត៌មានយ៉ាងត្រឹមត្រូវ ។ មានទំរង់ពីរប្រភេទ សំរាប់វាយតំលៃគំរោង ។ ទំរង់ខាងក្រោមនេះ គឺសំរាប់វាយតំលៃគំរោងដែលបានបញ្ចប់ភ្លាមៗ និងទំរង់ទី២ ( នៅទំព័រទី ៥៨ ) សំរាប់វាយតំលៃគំរោងដែលបានបញ្ចប់មួយរយៈពេលក្រោយមក ។

### ទំរង់វាយតំលៃគំរោង

( នៅពេលបញ្ចប់គំរោង )

**ពត៌មានទូទៅ**

| | | |
|---|---|---|
| ឈ្មោះឃុំ សង្កាត់ : | លេខកូដគំរោងឬកិច្ចសន្យា : | ឈ្មោះគំរោង : |
| ឈ្មោះភូមិ :<br>–<br>–<br>– | ការចុះវាយតំលៃលើកទី : | ឈ្មោះភ្នាក់ងារ ឬអ្នកអនុវត្តគំរោង : |
| | កាលបរិច្ឆេទចុះវាយតំលៃ : | ឈ្មោះអ្នកចុះវាយតំលៃ : |

**ពត៌មានវាយតំលៃ**

១. កាលបរិច្ឆេទបញ្ចប់គំរោងជាក់ស្តែង

២. លទ្ធផលគំរោង

| លទ្ធផលគ្រោងទុក | លទ្ធផលជាក់ស្តែង |
|---|---|
| | |

ក្នុងករណីលទ្ធផលគំរោងជាក់ស្តែង ខុសពីលទ្ធផលគ្រោងទុក ចូរបញ្ជាក់មូលហេតុ...............

..........................................................................................

..........................................................................................

៣. អ្នកទទួលផលពីគំរោង

| ចំនួនអ្នកទទួលផលគ្រោងទុក | ចំនួនអ្នកទទួលផលជាក់ស្តែង |
|---|---|
| | |

ក្នុងករណីចំនួនអ្នកទទួលផលគំរោងជាក់ស្តែងខុសពីចំនួនអ្នកផលគ្រោងទុក ចូរបញ្ជាក់មូលហេតុ

..........................................................................................

..........................................................................................

៤. តើប្រជាពលរដ្ឋមូលដ្ឋានយល់យ៉ាងដូចម្តេច ចំពោះគុណភាពគំរោង?

☐ អាចទទួលយកបាន

☐ មិនអាចទទួលយកបាន

☐ គ្មានយោបល់

បើមិនអាចទទួលយកបាន ចូរបញ្ជាក់មូលហេតុ :

៥. តើសហគមន៍យល់ថា លទ្ធផលគំរោងមានសារៈប្រយោជន៍ដល់ពួកគាត់ដែរឬទេ ?

☐ មាន ចូររៀបរាប់..........................................................................

..........................................................................................

..........................................................................................

☐ មិនមាន ចូរសរសេរយោបល់..........................................................

..........................................................................................

..........................................................................................

៦. តើអ្នកយល់ថាគំរោងសំរេចបានតាមគោលបំណងដែរឬទេ ?

☐ បាន

☐ មិនបាន

បើមិនបាន ចូរបញ្ជាក់មូលហេតុ :

៧. អនុសាសន៍

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

# ទម្រង់វាយតម្លៃគម្រោង

( ក្រោយរយៈពេលធានា )

## ព័ត៌មានទូទៅ

| | | |
|---|---|---|
| ឈ្មោះឃុំ សង្កាត់ : | លេខកូដគម្រោងឬកិច្ចសន្យា : | ឈ្មោះគម្រោង : |
| ឈ្មោះភូមិ :<br>–<br>–<br>– | ការចុះវាយតម្លៃលើកទី : | ឈ្មោះភ្នាក់ងារ ឬអ្នកអនុវត្តគម្រោង : |
| | កាលបរិច្ឆេទចុះវាយតម្លៃ : | ឈ្មោះអ្នកចុះវាយតម្លៃ : |

## ព័ត៌មានវាយតម្លៃ

១. តើលទ្ធផលរបស់គម្រោងនៅដំណើរការបានដែរឬទេ?

☐ បាន

☐ មិនបាន

បើមិនបាន ចូរបញ្ជាក់មូលហេតុ :

២. តើសហគមន៍(ឬគណៈកម្មការ)មានថវិកាសំរាប់ជួសជុល និងថែទាំដែរឬទេ?

☐ មាន ចំនួន :............. ប្រភព : ..................................................

☐ មិនមាន សូមបញ្ជាក់មូលហេតុ : ..................................................

..........................................................................................

៣. បន្ទាប់ពីអនុវត្តគម្រោង តើប្រជាពលរដ្ឋមូលដ្ឋានមានការប្រែប្រួលដែរឬទេ?

☐ មាន ចូររៀបរាប់ : ..................................................

..........................................................................................

☐ មិនមាន សូមបញ្ជាក់មូលហេតុ : ..................................................

..........................................................................................

៤. អនុសាសន៍

..........................................................................................

..........................................................................................

..........................................................................................

## ឃ. សៀវភៅកំណត់ហេតុ

សៀវភៅកំណត់ហេតុ គឺជាសៀវភៅមួយ សំរាប់កត់ត្រានូវការសង្កេតសំខាន់ៗដែលបានកើតឡើង ទៅតាមលំដាប់លំដោយនៃពេលវេលាក្នុងការអនុវត្តគំរោង ។ ជាទូទៅ ចំណុចសំខាន់ៗទាំងនេះ គឺជាការបរិយាយនូវកិច្ចការដែលបានធ្វើ ធ្វើនៅពេលណា នរណាជាអ្នកធ្វើ និង លទ្ធផល ឬការរកឃើញអ្វីខ្លះ នៅក្នុងពេលធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។

ចំពោះគំរោងហេដ្ឋារចនាសម្ព័ន្ធ មេឃុំ ចៅសង្កាត់ មេការ និង ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវមានសៀវភៅកំណត់ហេតុការងារនៅការដ្ឋានមួយក្បាលម្នាក់ ។ ជាពិសេស សៀវភៅកំណត់ហេតុនេះនឹងអាចជួយដល់ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់ ក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃ ដើម្បីកត់ត្រាអំពីការសង្កេត ការរកឃើញ និងយោបល់ផ្សេងៗរបស់ពួកគេ ឬការកំណត់ចំណាំនានា ដើម្បីរំលឹកនូវចំណុចសំខាន់ៗដែលពួកគេត្រូវធ្វើបន្ត ។ ពត៌មានដែលត្រូវកត់ត្រាចូលក្នុង សៀវភៅកំណត់ហេតុសំរាប់ការចុះតាមដានត្រួតពិនិត្យ និងវាយតំលៃនីមួយៗរួមមាន ÷

- កាលបរិច្ឆេទ និងពេលវេលានៃការចុះពិនិត្យ
- ការបរិយាយសកម្មភាពសង្ខេប : ឧទាហរណ៍ ប្រជុំជាមួយអ្នកភូមិដើម្បីទទួលចំលើយឆ្លើយតប ការប្រជុំ ជាមួយមន្ត្រីថ្នាក់ស្រុក និងខេត្ត ការប្រជុំជាមួយអ្នកទទួលការ ។ល។
- បញ្ហាដែលបានពិនិត្យឃើញ : ជាពិសេសបញ្ហាដែលអាចបណ្តាលអោយមាន ផលប៉ះពាល់រយៈពេលវែង ។
- សំណើដំណោះស្រាយបញ្ហា
- ការងារដែលត្រូវធ្វើបន្ត និងការទទួលខុសត្រូវ : ប្រសិនបើមានការសំរេចនៅក្នុងការប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ អំពីការងារដែលត្រូវធ្វើបន្ត សូមសរសេរនៅទីនេះ ដោយសរសេរឈ្មោះអ្នកទទួលខុសត្រូវសំរាប់ធ្វើការងារនេះ ឬសំរាប់សំរបសំរួលការងារនេះ ។

**ឧទាហរណ៍ :**

ការចុះពត៌មាននៃការពិនិត្យលើគំរោងផ្លូវមួយខ្សែក្នុងឃុំម្រាម ក្នុងឆ្នាំ២០០៣ នៅក្នុងសៀវភៅកំណត់ហេតុ :

កាលបរិច្ឆេទ និងពេលវេលានៃការចុះពិនិត្យ : ថ្ងៃសុក្រ ទី២៥ ខែកក្កដា ឆ្នាំ ២០០៣ : ពេលព្រឹក

ការបរិយាយសកម្មភាពសង្ខេប : ការចុះពិនិត្យមើលផ្នែកមួយនៃផ្លូវនៅភូមិត្បូង ជាប់នឹងត្រពាំងទឹក ជាមួយ *លោកលាង* ដែលជាសមាជិកនៃគណៈកម្មការគ្រប់គ្រងគំរោង បានពិនិត្យឃើញថា ពេលទៅដល់កន្លែងសាងសង់ មានមនុស្សតែ៣នាក់ប៉ុណ្ណោះ ពីព្រោះអ្នកដ៏ទៃទៀត ជាប់រវល់ទៅបោះឆ្នោតថ្នាក់ជាតិ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ហើយពួកគេនឹងត្រលប់មកធ្វើការជាធម្មតាវិញ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៣ ។

បញ្ហាដែលបានពិនិត្យឃើញ : ការចាក់គ្រឹះផ្លូវត្រូវបានធ្វើរួចរាល់អស់ហើយ ប៉ុន្តែមាន ០៣កន្លែង ដែលទទឹងមានតែ ៤,៥ម៉ែត្រ តែប៉ុណ្ណោះ មិនមែន៦ម៉ែត្រនោះទេ ហើយផ្ទៃលើនៃផ្លូវក៏មិនសូវបានសំប៉ែតល្អដែរ ។

សំណើដំណោះស្រាយបញ្ហា : នៅពេលជួបពិភាក្សានៅការដ្ឋាន មេការបានសន្យាថា :

១). គ្រឹះផ្លូវនេះ នឹងមានទំហំ៦ម៉ែត្រគ្រប់កន្លែងទាំងអស់

២). ផ្ទៃកលើនឹងរាបស្មើ ដោយមិនមានជង្ហុក ឬ កំពឹកកំពកឡើយ ។

ការងារដែលត្រូវធ្វើបន្ត និងការទទួលខុសត្រូវ : *លោកលាង* នឹងចុះពិនិត្យម្តងទៀត នៅថ្ងៃទី៣០មុនពេលចាក់គ្រួសក្រហម និងត្រូវរាយការណ៍ជូនទៅមេឃុំ នូវអ្វីដែលគាត់បានពិនិត្យឃើញ ។

## ង. បញ្ជីត្រួតពិនិត្យ

បញ្ជីត្រួតពិនិត្យ គឺជាបញ្ជីសំណួរសាមញ្ញមួយ សំរាប់ធ្វើការពិចារណា នៅពេលធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ បញ្ជីនេះ ត្រូវរៀបចំឡើងមុនការចាប់ផ្តើមសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ បញ្ជីត្រួតពិនិត្យនឹងជួយយើងកុំអោយភ្លេចនូវចំណុចនានាដែលត្រូវធ្វើការពិនិត្យមើល ឬសួរសំណួរអំពីចំណុចសំខាន់ៗនៃសកម្មភាពដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ យកល្អគួរតែសរសេរបញ្ជីត្រួតពិនិត្យនេះ នៅក្នុងសៀវភៅកំណត់ហេតុ ។ អ្នកចុះតាមដានត្រួតពិនិត្យការអនុវត្តគំរោង ត្រូវតែយកបញ្ជីត្រួតពិនិត្យនេះ ទៅជាមួយ ពេលគាត់ចុះទៅធ្វើការតាមដានត្រួតពិនិត្យគំរោងដល់ការដ្ឋាន ។

ឧទាហរណ៍ ស្ដីពីបញ្ជីត្រួតពិនិត្យ សំរាប់ការពិនិត្យលើគំរោងអណ្ដូងទឹកមួយ

សូមគូស(✓)សំរាប់សកម្មភាពណាដែលបានពិនិត្យហើយ

ទិដ្ឋភាពទូទៅ

- ប្រភេទអណ្ដូង ☐
- អនាម័យជុំវិញអណ្ដូង ☐
- បំពង់បង្ហូរទឹកស្អុយ ☐
- សុវត្ថិភាពជុំវិញអណ្ដូង ☐
- បរិមាណទឹក ☐
- ប្រភពទឹកជិតបំផុត ដែលជាជំរើសមួយផ្សេងទៀត ☐

ការប្រើប្រាស់ និងប្រតិបត្តិការ

- មនុស្សគ្រប់រូបមានលទ្ធភាពប្រើប្រាស់ទឹកអណ្ដូងទាំងអស់គ្នា ☐
- តើទឹកនេះ ត្រូវបានប្រើសំរាប់ធ្វើអ្វីខ្លះ? ☐
- ការបង្កើតអោយមានការថែទាំអណ្ដូង ☐

## ច. កាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ

កាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺជាឧបករណ៍មួយដ៏មានសារៈសំខាន់ សំរាប់រៀបចំផែនការការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ នៅរៀងរាល់ដើមឆ្នាំ ដោយបញ្ជាក់ពីគំរោង ឬ សកម្មភាព ពេលវេលា និងអ្នកទទួលខុសត្រូវ សំរាប់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ក្នុងរយៈពេលមួយឆ្នាំ ។

# កាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ ឆ្នាំ២០០...

លេខកូដឃុំ សង្កាត់ :.................... ឃុំ សង្កាត់ :.......................... ស្រុក ខណ្ឌ :............................ ខេត្ត ក្រុង :........................

| ការបរិយាយ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | អ្នកទទួល ខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

ថ្ងៃទី.........ខែ..........ឆ្នាំ ២០០.......

ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ

ឧទាហរណ៍ : របៀបបំពេញកាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់

## កាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ ឆ្នាំ២០០៤

លេខកូដឃុំ សង្កាត់ : *១២៣៤៥៦៧* ឃុំ សង្កាត់ : *ម្រាម* ស្រុក ខណ្ឌ : *រមាសហែក* ខេត្ត ក្រុង : *ស្វាយរៀង*

| | ការបរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | អ្នកទទួល ខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | គំរោងផ្លូវលំនៅឃុំម្រាម | | | | | | | | | | | | | លោកស្រី ក និងលោក ខ |
| ២ | គំរោងសាងសង់អណ្តូងទឹកស្អាត | | | | | | | | | | | | | លោក ខ |
| ៣ | អប់រំយេនឌ័រ | | | | | | | | | | | | | លោកស្រី ក |
| ៤ | ភូមិត្បូង | | | | | | | | | | | | | លោក ខ |
| ៥ | ភូមិជើង | | | | | | | | | | | | | លោកស្រី ក |
| ៦ | ភូមិកណ្តាល | | | | | | | | | | | | | លោក ខ |
| ៧ | ភូមិខ្ពស់ | | | | | | | | | | | | | លោកស្រី ក |
| | | | | | | | | | | | | | | |

*ការវាយតំលៃក្រោយរយៈពេលជានា*

ថ្ងៃទី .... ខែ ....ឆ្នាំ ២០០_

ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ

លោកស្រី ក និងលោក ខ

ចំណាំ : សកម្មភាពចុងក្រោយ មានន័យថា

ជាការវាយតំលៃពេលបញ្ចប់គំរោង

☞ ចំពោះគំរោងអភិវឌ្ឍន៍ និង សេវាកម្មនានា ដែលប្រើប្រាស់មូលនិធិឃុំ សង្កាត់ សូមចុះឈ្មោះគំរោងនោះនៅក្នុងកូឡោនទី២ ហើយបញ្ជាក់ពីពេលវេលា ( ផ្អែកលើផែនការការងាររបស់អ្នកទទួលការ និងមូលដ្ឋានចាំបាច់ផ្សេងៗទៀត ) ដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ ឬ វាយតំលៃ ។

☞ ចំពោះគំរោងអភិវឌ្ឍន៍ និង សេវាកម្មផ្សេងៗទៀត ដែលមិនប្រើប្រាស់មូលនិធិឃុំ សង្កាត់ សូមចុះឈ្មោះភូមិដែលត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។

ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃទាំងពីររូប គួរតែធ្វើការបែងចែកភារកិច្ចគ្នាថាតើជនបង្គោល ណាមួយទទួលខុសត្រូវលើគំរោងអ្វីខ្លះ (សំរាប់គំរោងដែលប្រើប្រាស់មូលនិធិឃុំ សង្កាត់) និងភូមិណាខ្លះ (សំរាប់គំរោង ផ្សេងៗ) តែត្រូវធ្វើការងារសហការគ្នា ។

យើងត្រូវពិនិត្យកាលវិភាគនេះរៀងរាល់ ១ ខែ ឬ ២ខែម្តង ផ្អែកតាមតំរូវការជាក់ស្តែង ដើម្បីចង់ដឹងថាតើសកម្មភាព ឬ គំរោងដែលយើងគ្រោងនឹងធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវបានអនុវត្តដែរឬទេ និងដើម្បីធ្វើការកែសំរួល បើសិនជាចាំបាច់ ។ ជាការពិត មានសកម្មភាពមួយចំនួននៅក្នុងកាលវិភាគនេះ ត្រូវបានលុបចេញ ឬត្រូវបានពន្យាពេលការអនុវត្ត ឬជួនកាលអាចមានសកម្មភាពថ្មីៗមួយចំនួន ដែលយើងមិនបានគិតដល់កាលពីដើមឆ្នាំ ត្រូវបានបង្កើតឡើង ។ ផ្អែកលើចំណុចទាំងអស់នេះហើយ ដែលយើងត្រូវធ្វើការកែសំរួលកាលវិភាគតាមដានត្រួតពិនិត្យ និង វាយតំលៃជាប្រចាំ ដើម្បីអនុវត្តការងារអោយមានប្រសិទ្ធភាពខ្ពស់ ។

ដូចដែលបានលើកឡើងខាងលើ ជាការសំខាន់ណាស់ដែលត្រូវអោយប្រាកដថា មិនមានចន្លោះប្រហោងណាមួយ ( ឧទាហរណ៍ : ភូមិណាមួយដែលមិនមានការអនុវត្តគំរោង ឬការផ្តល់សេវាកម្ម ) នៅក្នុងឃុំ សង្កាត់ដែលមិនត្រូវបានធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ នៅពេលរៀបចំកាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ ចាំបាច់ត្រូវអោយប្រាកដថា គ្រប់ភូមិទាំងអស់ ក្នុងឃុំសង្កាត់ ត្រូវបានបញ្ចូលនៅក្នុងកាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ ។

*ចូរចងចាំ !*

ការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺជាការងារមួយដ៏ចាំបាច់ និងមានសារៈសំខាន់ ប៉ុន្តែមិនមានន័យថា ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃកាន់តែច្រើន កាន់តែល្អនោះទេ ។ ជាការប្រសើរ យើងត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃក្នុងរូបភាពមួយតូច តែច្បាស់លាស់ ត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ គឺប្រសើរជាងយើងធ្វើច្រើន តែមិនបានច្បាស់លាស់ និងមិនគ្រប់ជ្រុងជ្រោយ ។

## ៦.៣. ការវិភាគពត៌មាន

បន្ទាប់ពីពតិមានត្រូវបានប្រមូលរួចហើយ ប្រការសំខាន់ ត្រូវពិនិត្យពតិមានទាំងនេះអោយបានដិតដល់ ដើម្បីបញ្ជាក់ថាពតិមាននេះអាចប្រាប់យើងពីអ្វីខ្លះ ។ តាមរយៈការវិភាគពតិមាន យើងអាចធ្វើសេចក្តីសន្និដ្ឋាន និងអាចវិនិច្ឆ័យការរីកចំរើន និងគុណភាពការងារ ។ ជាការប្រសើរ ការវិភាគពតិមាននេះ មិនគួរធ្វើឡើងដោយមនុស្សម្នាក់ ឬ ២នាក់នោះទេ ប៉ុន្តែត្រូវធ្វើជាមួយមនុស្សជាច្រើនគ្នា ( ឧទាហរណ៍ : នៅក្នុងគណៈកម្មាធិការកសាងផែនការ និងថវិកា ឬជាមួយគណៈកម្មការគ្រប់គ្រងគំរោង ) ។

នៅពេលយើងវិភាគពតិមាន យើងត្រូវពិនិត្យមើលថា តើការអនុវត្តគំរោងមានការប្រែប្រួលអ្វីខ្លះ ( ដូចជាការរីកចំរើន ឬ ការធ្លាក់ចុះដែលយើងសង្កេតឃើញ ឬការប្រែប្រួលណាមួយដែលយើងពិនិត្យឃើញ ក្នុងអំឡុងពេលណាមួយ ឬទីកន្លែងណាមួយ ) ។ ការវិភាគពតិមាន ក៏ត្រូវពិនិត្យផងដែរទៅលើ ភាពដូចគ្នា ឬភាពខុសគ្នាពីអ្វីដែលយើងបានសង្ឃឹមទុកជាមុន ។

តើយើងមានពិនិត្យឃើញការប្រែប្រួលអ្វីដែរឬទេ រវាងភូមិនីមួយៗក្នុងឃុំ សង្កាត់ ? តើអ្វីដែលយើងសង្កេតឃើញថា ដូចគ្នាទៅនឹងអ្វីដែលអ្នកឆ្លើយតបនឹងការសំភាសន៍របស់យើងឬទេ ? តើការរីកចំរើននៃការអនុវត្តគំរោង ដែលអ្នកទទួលការបានរាយការណ៍អោយយើង ដូចគ្នាទៅនឹងអ្វីដែលយើងបានចុះទៅពិនិត្យគំរោងផ្ទាល់ដែរឬទេ? តើពតិមានដែលយើងបានប្រមូល គ្រប់គ្រាន់ដែរឬទេ ? តើយើងអាចពិនិត្យឃើញគំរុយអ្វីខ្លះដែរឬទេ ពីពតិមានដែលយើងបានប្រមូល ? ( ដូចជាការអនុវត្តគំរោងផ្តោតទៅតែមួយភូមិ ឬ ៩០%នៃគំរោងមួយត្រូវបានអនុវត្តយឺត និងខ្ជីខ្ជា ដោយអ្នកទទួលការ ) ។

ប្រសិនបើ ប្រភពពតិមាន និងវិធីសាស្ត្រនៃការវិភាគពតិមានផ្សេងៗគ្នា តែផ្តល់អោយយើងនូវការសន្និដ្ឋានប្រហាក់ប្រហែលគ្នា នោះយើងប្រហែលជាអាចជឿលើការរកឃើញ និង ការសន្និដ្ឋានរបស់យើង ។ ប៉ុន្តែបើមានភាពផ្ទុយគ្នាជាមួយនឹងលទ្ធផលនៃការវិភាគរបស់យើង យើងត្រូវព្យាយាមស្វែងយល់ថា តើមូលហេតុអ្វីបានជាវាខុសគ្នា ។ ករណីនេះ យើងត្រូវប្រមូល និងវិភាគពតិមានមួយចំនួនបន្ថែមទៀត ។

ការវិភាគពតិមាន គួរតែធ្វើឡើងដោយប្រើប្រាស់ ដ្យាក្រាម ក្រាភិច និងតារាង ដើម្បីអោយប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធងាយយល់ ។

## ឧទាហរណ៍

មួយឆ្នាំក្រោយពីគំរោងកសាងផ្លូវមួយខ្សែនៅក្នុងឃុំប្រមាម ត្រូវបានសាងសង់ហើយ ការអង្កេតមួយត្រូវបានធ្វើឡើងនៅក្នុងភូមិចំនួន៤ ដើម្បីវាយតំលៃពីចំនួនអ្នកទទួលផលពីគំរោងនេះ ។ ខាងក្រោមនេះ គឺជាលទ្ធផលនៃការអង្កេត ។

| ល.រ | ឈ្មោះភូមិ | ចំនួនអ្នកទទួលផល ក្នុងផែនការ | | ចំនួនអ្នកទទួលផល ជាក់ស្តែង | |
|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី |
| ១ | ភូមិជើង | ៨០០ | ៤០០ | ៨០០ | ៤០០ |
| ២ | ភូមិត្បូង | ៦០០ | ៣០០ | ៥០០ | ២៥០ |
| ៣ | ភូមិកណ្តាល | ៩០០ | ៤៥០ | ៣០០ | ១៥០ |
| ៤ | ភូមិខ្ពស់ | ៤០០ | ២០១ | ៤០០ | ២០១ |




តារាង និងក្រាហ្វិកខាងលើបានបង្ហាញថា មានភូមិ២ក្នុងឃុំ (ភូមិជើង និងភូមិខ្ពស់) ចំនួនអ្នកទទួលផលពីគំរោង ដូចគ្នាទៅនឹងចំនួនដែលមាននៅក្នុងផែនការ ។ ប៉ុន្តែនៅក្នុងភូមិត្បូងចំនួនអ្នកទទួលផលមានចំនួនតិចជាងផែនការ ហើយភូមិកណ្តាល មានអ្នកទទួលផលកាន់តែតិចទៅទៀត ធៀបនឹងផែនការ គឺស្មើនឹង ១/៣ នៃចំនួនដែលមាននៅក្នុងផែនការតែប៉ុណ្ណោះ ។

តាមរយៈពត៌មានដែលយើងទទួលបានពីការអង្កេតនេះ យើងបានពិនិត្យឃើញថា មូលហេតុសំខាន់ដែលធ្វើឱ្យមានភាពខុសគ្នារវាងចំនួនអ្នកទទួលផលក្នុងផែនការ និងចំនួនជាក់ស្តែង ព្រោះផ្លូវនោះមិនត្រូវបានសាងសង់អោយបានត្រឹមត្រូវតាមការកំណត់នៅក្នុងគំរោង ដែលមានប្រវែង៣គីឡូម៉ែត្រ ហើយលូបង្ហូរ១ក្នុងចំណោមលូបង្ហូរ ទាំង៥ ត្រូវបានខូចខាតក្នុងរដូវវស្សា ។ ដូចនេះហើយ ទើបធ្វើអោយមានប្រជាជនប្រមាណជា ១/៣ តែប៉ុណ្ណោះ ក្នុងភូមិកណ្តាលបានទទួលប្រយោជន៍ពីផ្លូវនោះ ។

## ៦.៤. ការប្រើប្រាស់សេចក្តីសន្និដ្ឋាន

ដំណាក់កាលចុងក្រោយនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺការប្រើប្រាស់សេចក្តីសន្និដ្ឋាននៃការវិភាគពតិមាន ។

☞ សេចក្តីសន្និដ្ឋាន ត្រូវបានប្រើប្រាស់ដើម្បី ÷

- ធានានូវគណនេយ្យភាព (ការទទួលខុសត្រូវខ្ពស់)
- កែលំអការគ្រប់គ្រង និងការធ្វើសេចក្តីសំរេចចិត្ត
- ជំរុញ ឬលើកទឹកចិត្តអោយមានការរៀនសូត្រ
- ធានាគុណភាព និរន្តភាព និងប្រសិទ្ធភាពនៃគំរោង

❖ **គណនេយ្យភាព មាន២គឺ ÷**

➲ ទី១ : គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះប្រជាពលរដ្ឋដែលបានបោះឆ្នោតជ្រើសរើសពួកគេ ។ ពតិមានដែលទទួលបានពីការតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវផ្សព្វផ្សាយជាសាធារណៈ និង ចែកជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ ។ ទន្ទឹមនឹងនេះ ឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយរបាយការណ៍សង្ខេបមួយទំព័រ ស្តីពីការអនុវត្តគំរោង និងការងារគ្រប់គ្រងឃុំ សង្កាត់ជូនសាធារណៈជន រៀងរាល់ខែ ។

➲ ទី២ : គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះអាជ្ញាធរថ្នាក់លើ ព្រោះថា ជាទូទៅអាជ្ញាធរថ្នាក់លើតែងតែចង់ដឹងថា តើឃុំ សង្កាត់បានអនុវត្តការងារដូចបានរំពឹងទុកដែរឬទេ ?

❖ **កែលំអការគ្រប់គ្រង និងការធ្វើសេចក្តីសំរេចចិត្ត**

➲ ប្រសិនបើការតាមដានត្រួតពិនិត្យ ពុំបានបង្ហាញថា មានបញ្ហាអ្វីចំពោះការអនុវត្តគំរោងទេនោះ ឃុំ សង្កាត់ ប្រហែលជាពុំចាំបាច់ធ្វើអ្វីទេ លើកលែងតែចង់ធ្វើការផ្លាស់ប្តូរ ដើម្បីអោយទទួលលទ្ធផលកាន់តែប្រសើរឡើងថែមទៀតប៉ុណ្ណោះ ។ ប្រសិនបើការតាមដានត្រួតពិនិត្យ បានបង្ហាញថាមានបញ្ហានោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យមើលថាតើបញ្ហាទាំងនេះ នឹងអាចធ្វើអោយមានផលប៉ះពាល់អ្វីខ្លះ ហើយត្រូវពិនិត្យមើលថា តើត្រូវធ្វើអ្វីខ្លះបាន ដើម្បីដោះស្រាយបញ្ហាទាំងនោះ ឬដើម្បីធ្វើអោយបញ្ហាទាំងនោះប្រសើរជាងមុន ។

➲ ប្រសិនបើឃុំ សង្កាត់ អាចដោះស្រាយបញ្ហាដោយខ្លួនឯង ពួកគេត្រូវចាត់វិធានការភ្លាមៗ។ កិច្ចការនេះអាចមានការពាក់ព័ន្ធទៅនឹងការកែសំរួលនូវរបៀបអនុវត្តសកម្មភាព ទីកន្លែង និងពេលវេលា ឬកែប្រែទំហំសកម្មភាព។ ប្រសិនបើឃុំ សង្កាត់ ពុំអាចដោះស្រាយដោយខ្លួនឯងបានទេ ឃុំ សង្កាត់

ត្រូវជូនដំណឹងដល់ខេត្ត ក្រុង អំពីបញ្ហាទាំងនោះ ហើយបើសិនជាមានលទ្ធភាព សូមបញ្ជាក់ផងដែរ អំពីមធ្យោបាយដែលអាចដោះស្រាយបញ្ហាទាំងនោះបាន ។

❖ ជំរុញ ឬលើកទឹកចិត្តអោយមានការរៀនសូត្រ

- អ្វីដែលទទួលបានពីការតាមដានត្រួតពិនិត្យ និងវាយតំលៃ ជាពត៌មានដែលមានសារៈប្រយោជន៍ នៅពេលធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ឆ្នាំក្រោយ ។ ប្រសិនបើមានកិច្ចការអ្វីដែលអនុវត្តទៅមិនបានល្អនៅក្នុងឆ្នាំនេះ ឃុំ សង្កាត់គួរតែធ្វើការកែសំរួលវិធីសាស្ត្រអនុវត្តនៅឆ្នាំបន្ទាប់ ។

❖ ធានាគុណភាព និរន្តភាព និងប្រសិទ្ធភាពនៃគំរោង

- បើសិនជាឃុំ សង្កាត់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃកាន់តែសកម្ម អ្នកអនុវត្តគំរោង ឬសកម្មភាព ប្រាកដជាខិតខំអនុវត្តការងារបានយ៉ាងត្រឹមត្រូវជាមិនខាន ដើម្បីធានាអោយបានគុណភាពល្អ ។ លទ្ធផលដែលល្អ និងមានគុណភាព គឺអាចធានាអោយមានការប្រើប្រាស់យូរអង្វែង ព្រមទាំងចំណាយប្រតិបត្តិការ និងចំណាយថែទាំតិច ។ ក្នុងន័យនេះ ការតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់លើគំរោងអភិវឌ្ឍន៍នានា ដែលបាននឹងកំពុងអនុវត្តនៅក្នុងឃុំ សង្កាត់របស់ខ្លួន នឹងអាចធ្វើអោយការអនុវត្តគំរោងមានប្រសិទ្ធភាព និងធានាបាននូវនិរន្តភាព ។

# តើយើងត្រូវរាយការណ៍ និងប្រើប្រាស់លទ្ធផល តាមដានត្រួតពិនិត្យ និងវាយតំលៃយ៉ាងដូចម្តេច ?

## ៧. ការប្រើប្រាស់លទ្ធផលតាមដានត្រួតពិនិត្យ និងវាយតំលៃ

### ៧.១. សំរាប់ការរៀបចំរបាយការណ៍ឃុំ សង្កាត់

ពត៌មានដែលទទួលបានពីការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺជាពត៌មានមួយដ៏សំខាន់ សំរាប់ធ្វើការពិភាក្សានៅក្នុងការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយនឹងជួយអោយក្រុមប្រឹក្សាឃុំ សង្កាត់មានការងាយស្រួល ក្នុងការរៀបចំរបាយការណ៍ ដើម្បីដាក់ជូនទៅអាជ្ញាធរខេត្ត ក្រុង ។ តារាងខាងក្រោម នឹងបង្ហាញពីទំនាក់ទំនងរវាងការអនុវត្តគំរោង និងការផ្តល់សេវាកម្ម ការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ ការប្រជុំទៀងទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការរៀបចំរបាយការណ៍ ។



ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការពិភាក្សាលើពត៌មានដែលទទួលបានពីការតាមដានត្រួតពិនិត្យ និងវាយតំលៃ នៃការអនុវត្តគំរោង ក្នុងកិច្ចប្រជុំប្រចាំខែទៀងទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ពត៌មានទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ សំរាប់ការរៀបចំរបាយការណ៍ប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដាក់ជូនទៅអាជ្ញាធរខេត្ត ក្រុង និងស្រុក ខណ្ឌ ។ លើសពីនេះទៅទៀត ពត៌មានដែលទទួលបានពីកិច្ចប្រជុំប្រចាំខែទៀងទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់នេះ ក៏ជាពត៌មានមួយផ្នែកសំរាប់បំពេញក្នុងរបាយការណ៍សង្ខេបប្រចាំខែមួយទំព័រសំរាប់ផ្សព្វផ្សាយជាសាធារណៈផងដែរ ។

## ៧.២. ជាមូលដ្ឋានមួយសំរាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់

ពត៌មានដែលទទួលបានពីការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺជាមូលដ្ឋានមួយដ៏សំខាន់ សំរាប់រៀបចំការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ ចំណុចនេះ ពាក់ព័ន្ធទៅនឹងគោលបំណងទី៣ របស់ការតាមដានត្រួតពិនិត្យ និងវាយតំលៃ គឺជំរុញអោយមានការសិក្សារៀនសូត្រពីអ្វីដែលយើង និងអ្នកដទៃបានធ្វើកាលពីពេលកន្លងមក ដើម្បីអោយក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តការងារបានប្រសើរ នាពេលអនាគត ។



ការតាមដានត្រួតពិនិត្យ និងវាយតំលៃ ជួយអោយក្រុមប្រឹក្សាឃុំ សង្កាត់ដឹងពីតំរូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សង្កាត់ និងអាចកំណត់អាទិភាពគំរោង ឬការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់ នាពេលអនាគត ។

តាមរយៈការតាមដានត្រួតពិនិត្យ និងវាយតំលៃលើការអនុវត្តគំរោង ឬការផ្តល់សេវាកម្មណាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់អាចដឹងថាតើ យុទ្ធសាស្ត្រណាខ្លះ ដែលអនុវត្តទៅបានល្អ និងថាតើយុទ្ធសាស្ត្រណាខ្លះ ដែលអនុវត្តទៅមិនបានល្អ ។ ការតាមដានត្រួតពិនិត្យ និងវាយតំលៃក៏បានផ្តល់អោយក្រុមប្រឹក្សាឃុំ សង្កាត់នូវពត៌មានមួយចំនួនដែលពាក់ព័ន្ធទៅនឹង គំរោង ។ តើក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលអ្វីខ្លះ លើការអនុវត្តគំរោងដើម្បីទទួលបាន ជោគជ័យកាន់តែល្អប្រសើរ ឬដើម្បីកាត់បន្ថយចំណាយ ដោយអាចទទួលបានលទ្ធផលដូចដើម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃផងដែរ លើកិច្ចព្រមព្រៀងបណ្តោះអាសន្ន ដែលបានព្រមព្រៀងជាមួយមន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីចង់ដឹងថាតើអ្នកទាំងនោះបានអនុវត្តគំរោង ឬសេវាកម្ម ទៅតាមអ្វីដែលបានព្រមព្រៀងដែរឬទេ ហើយប្រសិនបើបានអនុវត្តតើទទួលបានលទ្ធផលដូចនឹងការរំពឹងទុកដែរឬទេ តែប្រសិនបើពួកគេមិនបានអនុវត្តតាមការព្រមព្រៀងទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទៅសួរនាំអ្នកទាំងនោះ ថាតើមូលហេតុអ្វីមិនបានអនុវត្តគំរោងតាមកិច្ចព្រមព្រៀង ក្នុងរយៈពេលមួយខែក្រោយពីកាលបរិច្ឆេទអនុវត្ត ( បើសិនកិច្ចព្រមព្រៀងបណ្តោះអាសន្នមានបញ្ជាក់ពីកាលបរិច្ឆេទចាប់ផ្តើមអនុវត្ត ) នៅតែមិនឃើញមានសកម្មភាពអ្វីកើតឡើង ។

ការតាមដានត្រួតពិនិត្យ និងវាយតំលៃក៏បានផ្តល់អោយក្រុមប្រឹក្សាឃុំ សង្កាត់នូវពត៌មានមួយចំនួនដ៏មានសារៈប្រយោជន៍ផងដែរសំរាប់ការកែលំអការរៀបចំកម្មវិធីវិនិយោគឃុំសង្កាត់។ តាមរយៈការតាមដានត្រួតពិនិត្យ និងវាយតំលៃ និងការវិភាគពត៌មាន ក្រុមប្រឹក្សាឃុំ សង្កាត់អាចដឹងបានថា ការអនុវត្តគំរោងជាច្រើនរួមគ្នា អាចអោយយើងទទួលបានលទ្ធផលប្រសើរជាង ការអនុវត្តគំរោងតែមួយ ។

*ឧទាហរណ៍ :* ឆ្នាំនេះក្រុមប្រឹក្សាឃុំ សង្កាត់មានគំរោងកសាងផ្លូវលំមួយខ្សែដែលមានប្រវែង ៦ គីឡូម៉ែត្រ ហើយឆ្នាំក្រោយក្រុមប្រឹក្សាគ្រោងនឹងពង្រីកប្រព័ន្ធធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីស្រែបាន ១០ ហិកតា ។ ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់បានសំរេចកសាងផ្លូវលំប្រវែងតែ ៣ គីឡូម៉ែត្រ និងកសាងប្រព័ន្ធធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីស្រែបានតែ ៥ ហិកតាសិនសំរាប់ឆ្នាំនេះ ហើយឆ្នាំក្រោយក្រុមប្រឹក្សានឹងធ្វើបន្ត ដើម្បីបង្គ្រប់តាមផែនការ ។ ដូចនេះ ក្រុមប្រឹក្សាឃុំ សង្កាត់នឹងអាចទទួលបានផលប្រយោជន៍ប្រសើរជាងការអនុវត្តគំរោងទាំងពីរដាច់ដោយឡែកពីគ្នា។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាក៏អាចអនុវត្តដូចគ្នានេះដែរ សំរាប់ការសំរបសំរួលក្នុងការកសាងផែនការអភិវឌ្ឍន៍ និងសហប្រតិបត្តិការ ក្នុងការអនុវត្តគំរោងរវាងឃុំ សង្កាត់ដែលនៅជាប់គ្នា ។

# តើយើងត្រូវរៀបចំ និងចាត់ចែង ការតាមដានត្រួតពិនិត្យ និងវាយតំលៃយ៉ាងដូចម្តេច ?

## ៨. ការរៀបចំ និងការចាត់ចែងការតាមដានត្រួតពិនិត្យ និងវាយតំលៃ

នៅផ្នែកខាងដើម យើងបានដឹងរួចមកហើយនូវទិដ្ឋភាពផ្សេងៗនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ នៅក្នុងផ្នែកនេះ យើងនឹងពិនិត្យមើលថាតើយើងត្រូវរៀបចំនិងចាត់ចែងការងារតាមដានត្រួតពិនិត្យ និងវាយតំលៃយ៉ាងដូចម្តេច ? គំនូសបំព្រួញនៅទំព័របន្ទាប់ នឹងបង្ហាញពីតារាង និងទំរង់ផ្សេងៗគ្នា ដែលបានលើកឡើងនៅផ្នែកខាងដើម ។

ខាងក្រោមនេះ ជាដំណាក់កាលនៃការរៀបចំ និងចាត់ចែងការងារតាមដានត្រួតពិនិត្យ និងវាយតំលៃ ÷

១. បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តលើកម្មវិធីវិនិយោគ និងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួនហើយ ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃឃុំ សង្កាត់ ត្រូវធ្វើការសិក្សាលើឯកសារទាំងនេះ ដើម្បីដឹងថាតើសកម្មភាពណាខ្លះដែលត្រូវអនុវត្តនៅឆ្នាំខាងមុខ និងបន្ទាប់មកត្រូវរៀបចំកាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ ព្រមទាំងផែនការសកម្មភាពរបស់ខ្លួន ។

២. ក្រោយពីបានរៀបចំសេចក្តីព្រាងកាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃរួចហើយ ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃត្រូវធ្វើការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការផ្សេងៗទៀត ( ដូចជា គណៈកម្មាធិការកសាងផែនការនិងថវិកា គណៈកម្មការគ្រប់គ្រងគំរោង ឬ ក្រុមអ្នកប្រើប្រាស់ ) ។

៣. ក្រោយពីការពិភាក្សា ប្រសិនបើមានការចាំបាច់ ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវធ្វើកា កែសំរួលតារាងទាំងពីរនេះ ហើយដាក់ជូនអោយក្រុមប្រឹក្សាឃុំ សង្កាត់អនុម័ត ។

៤. ចំពោះគំរោងដែលកំពុងអនុវត្ត និងគំរោងថ្មី ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់តារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៏ឃុំ សង្កាត់ សំរាប់ការងារតាមដានត្រួតពិនិត្យគំរោងទាំងនោះ ។ នៅពេលវាយតំលៃបញ្ចប់គំរោង ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែប្រើទំរង់វាយតំលៃគំរោង ។

៥. រៀងរាល់ខែក្នុងអំឡុងការប្រជុំប្រចាំខែទៀងទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវរាយការណ៍ជូនអង្គប្រជុំពីលទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការពិភាក្សាថាតើ គួរតែមានសកម្មភាពតាមដានបន្តអ្វីខ្លះទៀតដែលចាំបាច់ ដើម្បីធានាអោយការអនុវត្តគំរោងអភិវឌ្ឍន៏ក្នុងឃុំ សង្កាត់ទទួលបានលទ្ធផលប្រសើរឡើង ។

៦. រៀងរាល់ចុងត្រីមាស ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវវាយតំលៃអំពីស្ថានភាព នៃការអនុវត្តកិច្ចព្រម-ព្រៀងបណ្ដោះអាសន្ន និងសកម្មភាពអភិវឌ្ឍន៍នានា ដោយប្រើតារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៍ក្នុងឃុំ សង្កាត់ ។

៧. ផ្អែកលើពតិមានដែលបានប្រមូល ដោយប្រើតារាងតាមដានត្រួតពិនិត្យគំរោងអភិវឌ្ឍន៍ នៅក្នុងឃុំ សង្កាត់នេះ កាលវិភាគតាមដានត្រួតពិនិត្យ និងវាយតំលៃ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីធានាថា សកម្មភាព អភិវឌ្ឍន៍ដែលបានអនុវត្តនៅក្នុងឃុំ សង្កាត់ ត្រូវបានតាមដានត្រួតពិនិត្យ និងវាយតំលៃយ៉ាងត្រឹមត្រូវ ។

៨. នៅចុងឆ្នាំ ពតិមានពីការតាមដានត្រួតពិនិត្យ និងវាយតំលៃ ត្រូវបានប្រើដើម្បីរៀបចំរបាយការណ៍ ប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដើម្បីដាក់ជូនទៅអាជ្ញាធរខេត្ត ក្រុង ។

# គំនូសបំព្រួញនៃការតាមដានត្រួតពិនិត្យ និងវាយតំលៃ



## តើត្រូវធ្វើអ្វីជាបន្តទៀត ?

### ៩. ការងារបន្ត

សៀវភៅនេះ បានផ្តល់គំនិតយោបល់ និងការណែនាំមួយចំនួន អំពីរបៀបធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃផ្ទៃក្នុងរបស់ឃុំ សង្កាត់ ។ មានសំណួរជាច្រើនដែលមិនទាន់មានចំលើយនៅឡើយ និងប្រធានបទមួយចំនួនមិនទាន់បានបកស្រាយលំអិតនៅឡើយដែរ ពីព្រោះសៀវភៅនេះជាឯសារណែនាំលើកដំបូង ស្តីពីសេចក្តីផ្តើមទូទៅ សំរាប់អោយក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការតាមដានត្រួតពិនិត្យ និងវាយតំលៃលើការងារអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ដូចបានរៀបរាប់នៅក្នុងផ្នែកទី៥ ឃុំ សង្កាត់នីមួយៗ ត្រូវជ្រើសរើសស្ត្រីម្នាក់ និងបុរសម្នាក់ (ម្នាក់ក្នុងចំណោមនោះ គឺជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងម្នាក់ទៀត គឺជាសមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកា) ដើម្បីបំពេញតួនាទី ជាជនបង្គោលតាមដានត្រួតពិនិត្យ និង វាយតំលៃ ។ ជនបង្គោលទាំង២នាក់នេះត្រូវទទួលនូវការបណ្តុះបណ្តាលបច្ចេកទេសអំពី ការតាមដានត្រួតពិនិត្យ និងវាយតំលៃគំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ ដើម្បីអោយពួកគេមានការយល់ដឹង និងមានលទ្ធភាពអនុវត្តការងារតាមដានត្រួតពិនិត្យ និងវាយតំលៃជាក់ស្តែងអោយកាន់តែប្រសើរឡើង ។

នៅឆ្នាំ ២០០៦ មុននឹងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើកទី១ត្រូវបានបញ្ចប់ ឃុំ សង្កាត់ទាំងអស់នឹងធ្វើការវាយតំលៃលទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។ ក្រសួងមហាផ្ទៃ និង ក្រសួងផែនការនឹងសហការរៀបចំសេចក្តីណែនាំលំអិតអំពីទំហំ (វិសាលភាព) និងរបៀបនៃការវាយតំលៃនេះ ។

## បញ្ជីសៀវភៅយោង

សំរាប់ការរៀបចំសៀវភៅណែនាំអំពីការតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់ យើងបានប្រើប្រាស់ឯកសារជាច្រើន ។ ឯកសារខាងក្រោមនេះ គឺជាឯកសារដែលបានប្រើប្រាស់ ក្នុងការដកស្រង់ខ្លឹមសារ ហើយតំរៀបតាមលំដាប់លំដោយ នៃតួអក្សរអង់គ្លេស ÷


១. មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍន៏កសិកម្ម **(IFAD)** ឆ្នាំ ២០០២ **ការតាមដានត្រួតពិនិត្យផលប៉ះពាល់នៅក្នុងការអភិវឌ្ឍន៍ជនបទ : គោលការណ៍ណែនាំ សំរាប់ការតាមដានត្រួតពិនិត្យ និងវាយតំលៃគំរោង** ។ ការិយាល័យតាមដាមត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវមូលនិធិអន្តរជាតិ សំរាប់ការអភិវឌ្ឍន៍កសិកម្ម **(IFAD)** ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី ។

២. **OECD/DAC** ឆ្នាំ ២០០២ **សន្ទានុក្រមនៃពាក្យសំខាន់ៗនៅក្នុងការវាយតំលៃ និងលទ្ធផលនៃការគ្រប់គ្រង** ។ ការវាយតំលៃ និងប្រសិទ្ធភាពនៃការផ្តល់ជំនួយសេរីលេខ៦ **OECD** ទីក្រុងប៉ារីស ប្រទេសបារាំង ។

៣. **Van Oosterhout, Fon** ឆ្នាំ ២០០២ **ការផ្លាស់ប្តូរក្រុមគោលដៅ : ឆ្ពោះទៅកាន់ការតាមដានត្រួតពិនិត្យវិសហមជ្ឈការប្រជាធិបតេយ្យ** ។ ទស្សនាវដ្តីលេខ៣៤៩ វិទ្យាស្ថាន **Royal Tropical** ទីក្រុងអាំស្តែដាំ ប្រទេសហូឡង់ ។

៤. **W.K Kellogg Foundation, 2001 គោលការណ៍ស្តីពីគំរូអភិវឌ្ឍន៍ដ៏សមហេតុសមផល** ។ មីស៊ីហ្គេន សហរដ្ឋអាមេរិក www.wkkf.org ។

៥. Woodhill, Jim and Lisa Robins, 1998, **ការវាយតំលៃដោយមានការចូលរួម សំរាប់ក្រុមថែទាំដីធ្លី និងចាប់យកដីធ្លី : គោលការណ៍ណែនាំសំរាប់អ្នកសំរបសំរួល** ។ Greening Australia, Yarralumlam, ប្រទេសអូស្ត្រាលី ។